ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤៥**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក អាឡាញ ប្រៃអត (Aline BRIOT)

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក សេង ប៊ុនឃាង

លោក វិលៀម ស្មីត *(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**មេធាវីជំនួយការរបស់សាក្សី ម៉ម ណៃ៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ម៉ម ណៃ ហៅ ចាន់


សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី.............................................................. ទំព័រ ៤

សួរដោយ លោក វីលៀម ស្មីត ផ្ដើមពី.............................................................. ទំព័រ ១០

សួរដោយ លោក ហុង គីមសួន ផ្ដើមពី.............................................................. ទំព័រ ១៨

សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្ដើមពី ..................................................ទំព័រ ២១

សួរដោយ លោកស្រី ស៊ីលឃីស្ទួត ហ្សៀនស្កី ផ្ដើមពី ............................................ទំព័រ ២៧

សួរដោយ លោកស្រី អាឡាំង វ៉ែនណឺ ផ្ដើមពី ......................................................ទំព័រ ៣៤

សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី..............................................................ទំព័រ ៤០

សួរដោយ លោក ហ្វ្រង់ស្វ័រ រ៉ូ ផ្ដើមពី..............................................................ទំព័រ ៤៤


### លោក ហ៊ីម ហ៊ុយ ហៅ ហ៊ឹម ហ៊ុយ


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី.............................................................. ទំព័រ ៥៧

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ម ណៃ | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការដេញដោលស្តាប់សក្ខីកម្មរបស់សាក្សី ឈ្មោះ ម៉ម ណៃ តទៅទៀត ។ ហើយតាមដំណើរការសវនាការកាលពីម្សិលមិញ បានចប់នូវការតាំងសំណួរដែលសួរដោយអង្គជំនុំជម្រះហើយ ។ ហើយកិច្ចបន្ត គឺនឹងប្រគល់វេទិកាទៅភាគី ប៉ុន្តែមុននឹងប្រគល់វេទិកាទៅភាគី ឲ្យក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញឲ្យមកចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរព លោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯ សាក្សី ម៉ម ណៃ មានវត្តមានក្នុងបន្ទប់សវនាការ ហើយសាក្សី KW-09 ដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី ម៉ម ណៃ នេះ នឹងមានវត្តមាននៅម៉ោងដប់ នៅក្នុងបន្ទប់សវនាការ ។ សាក្សីរូបនេះបានស្បថរួចហើយ ហើយខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណរួចហើយ មិនមានចំណងញាតិលោហិតជាមួយនឹងជនជាប់ចោទ ឬភាគីរដ្ឋប្បវេណីនោះទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចមានឱកាសនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ ។ ហើយសូមជម្រាបតំណាងសហព្រះរាជអាជ្ញា ថា តំណាងសហព្រះរាជអាជ្ញានៅក្នុងរឿងក្តីនេះមានពេលវេលាសម្រាប់សួរនេះ គឺមួយម៉ោង គឺស្មើនឹងហុកសិបនាទី ។ សូមអញ្ជើញ ។

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណ លោកប្រធានអង្គជំនុំជម្រះ ។ សុំជម្រាបសួរលោក ម៉ម ណៃ ។

ជាដំបូង មុននឹងតំណាងសហព្រះរាជអាជ្ញាធ្វើការចោទសួរទៅដល់លោក ម៉ម ណៃ ខ្ញុំតំណាង

សហព្រះរាជអាជ្ញា សូមរំឭកនិងជម្រាបជូនលោក ម៉ម ណៃ ឲ្យបានជ្រាបផងដែរថា ដូចអង្គជំនុំជម្រះ លោកប្រធានអង្គជំនុំជម្រះ បានជម្រាបលោកកាលពីលោកអញ្ជើញមកឆ្លើយបំភ្លឺនៅសវនាការនេះដែរ ហើយ ចំពោះវិធាន២៨នៃវិធានផ្ទៃក្នុង ស្តីពីសាក្សីមានសិទ្ធិមិនឆ្លើយដើម្បីធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះ ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាក៏សូមលើកទឹកចិត្តដល់សាក្សីដែលមានលោក ម៉ម ណៃ វត្តមាននៅទីនេះថា លោកអាចឆ្លើយនូវអ្វីៗគ្រប់យ៉ាងដែលលោកបានដឹង បានឮ និងបានឃើញដោយផ្ទាល់ ទោះបីជាសក្ខីកម្មនោះ វាជាប់ពាក់ព័ន្ធនឹងរូបលោកក៏ដោយ ព្រោះបើតាមយោងតាមមាត្រា១ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.កនិងកិច្ចព្រមព្រៀង បានបញ្ជាក់យ៉ាងច្បាស់លាស់ហើយថាមានតែជនពីរប្រភេទប៉ុណ្ណោះដែលត្រូវជ្រើសរើសយកមកផ្តន្ទាទោស នោះគឺ មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះនេះដែរ ។

[០៩:០៨:២២]

ម៉្យាងវិញទៀត បើពិនិត្យទៅលើសាក្សីដែលបានប្រព្រឹត្តនាអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ គិតមកទល់ថ្ងៃនេះឃើញថា វាមានរយៈពេលជាងសាមសិបឆ្នាំមកហើយដែរ ។ ដូច្នេះ បើគិតពីអាជ្ញាយុកាលដែលយុត្តាធិការរបស់អង្គជំនុំជម្រះថ្នាក់ជាតិ ចំពោះបទល្មើសឧក្រិដ្ឋទាំងនេះគឺវាហួសអាជ្ញាយុកាលទៅហើយ ដូច្នេះមិនអាចយកមកផ្តន្ទាទោសបានទេ ។

ហើយជាបន្ត ខ្ញុំសូមអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីឲ្យខាងសោតទស្សន៍បង្ហាញនូវរូបផែនទីសារមន្ទីរទួលស្លែង ដែលបានថតពីអាកាសដែលមានលេខ ERN00189135 ស្ថិតនៅក្នុងឧបសម្ព័ន្ធ D45/1 និង /8 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្ហាញឯកសារតាមសំណូមពររបស់តំណាងសហព្រះរាជអាជ្ញាជាតិ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ម៉ម ណៃ នេះគឺជារូបភាពដែលបានថតពីលើអាកាសនៅទីតាំងរួមរបស់សារមន្ទីរទួលស្លែងដែលមានក្នុងនោះអគារអក្សរ “A”, “B”, “C”, “D” និងអក្សរ “E” ដែលលោកចេះភាសាលោកអាចយល់ហើយថាមាន “ក”, “ខ”, “គ”, “ឃ” និង “ង” ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា នេះគឺជាទីតាំងសារមន្ទីរទួលស្លែង ហើយទីកន្លែងណាដែលលោកធ្លាប់បានធ្វើការសួរចម្លើយក្នុងរយៈកាលដែលលោកបានធ្វើជាបុគ្គលិករបស់មន្ទីរស-២១ហ្នឹងលោក?

[០៩:១០:៣៥]

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ខ្ញុំយល់ថាហ្នឹងជាមន្ទីរគុកទួលស្លែងហើយ ហើយកន្លែងខ្ញុំសួរនៅខាងកើតគុកឯណោះទេ នៅខាងកើតគុកជាប់នឹងអូរទឹកស្អុយ ។

**ស៖** អរគុណលោក ។ នៅក្នុងអគារទាំង៥ របស់សារមន្ទីរទួលស្លែងនេះ តើមានអគារណាមួយដែលធ្លាប់លោកបានមកសួរចម្លើយនៅទីនេះដែរទេ?

**ឆ៖** *...* តែគ្រាន់តែថាបានទៅជួប ។

**ស៖** *(ឮមិនច្បាស់)* សូមលោកនិយាយម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

លោក ម៉ម ណៃ ចាំរំឭកឡើងវិញ ចាំៗដល់ឃើញអាភ្លើងក្រហមនៅក្បាលមេក្រូ សឹមចាប់ផ្តើមនិយាយ ខំកាលណានិយាយទៅអត់បាន អត់មានការបកប្រែទេ ហើយព័ត៌មាននេះគឺសូម្បីតែជាតិក៏ស្តាប់មិនបានដែរ អ៊ីចឹងអន្តរជាតិអត់មានអីបកប្រែទេ ហើយប្រតិចារឹកនៅក្នុងកត់ត្រាក៏អត់បាន អត់មានការកត់ត្រាដែរ ។ ហើយរំឭកដល់តំណាងសហព្រះរាជអាជ្ញាជាតិក៏ដូចគ្នាដែរ អំមិញលោកដល់ទៅម៉ម ណៃ ថាឲ្យនិយាយក្បាលមីក្រូ តែខ្លួនឯងអត់បើកទេ ។

**លោក តាន់ សេណារ៉ុង៖**

សូមអញ្ជើញលោក ។

**ឆ៖** សូមជម្រាបលោក ។ ខ្ញុំបានចូលទៅម្តងទៅសួរ កូនសិស្សខ្ញុំដែលចាប់មកខ្ញុំសុំអនុញ្ញាតពីមិត្តឌុច ទៅៗសួរខ្ញុំមិនដឹងអាណា ខាងណា “ក” ខាងណា “ខ” ខ្ញុំគ្រាន់តែដឹងថា នៅខាងត្បូងហ្នឹងខ្ញុំឡើងទៅមានកន្លែងមួយទំនេរ គេនាំកូនសិស្សខ្ញុំហ្នឹងមកជួបនៅកន្លែងនុំង ។ ហើយជួប គ្រាន់តែសួរសុខទុក្ខចប់ហើយ ខ្ញុំក៏ត្រលប់មកវិញមក ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ តំណាងសហព្រះរាជអាជ្ញាសុំការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញរូបភាពមួយទៀត ដែលមាន ERN លេខ 00153573 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ សុំបង្ហាញនៅលើកញ្ចក់អេក្រង់ទូរទស្សន៍នូវឯកសារដែលលោកព្រះរាជអាជ្ញាបានលើកឡើងអំមិញ ។

**លោក តាន់ សេណារ៉ុង៖**

លោក ម៉ម ណៃ តើលោកអាចធ្វើការកត់សម្គាល់ទៅតាមផែនទីគំនូសតាងនេះបានទេ ថានេះគឺជាគំនូសតាងដែលគូរឡើងដោយជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ អក្សរ “B” នេះគឺជាសារមន្ទីរទួលស្លែង ។ ហើយលេខ១ នេះគឺជាការិយាល័យធ្វើការ និងផ្ទះនៅពេលឃុំខ្លួន និងការសួរចម្លើយ។ លេខ២ មានផ្កាយហ្នឹង គឺជាការិយាល័យ និងផ្ទះនៅពេលដែលមានការឃុំខ្លួន និងការសួរចម្លើយនៅក្នុងអតីតអគ្គនាយកដ្ឋាននគរបាលជាតិ ។ លេខ៣ និង ៣ព្រីម ហ្នឹងការិយាល័យនិងផ្ទះនៅពេលដែលការឃុំខ្លួននិងការសួរចម្លើយប្រព្រឹត្តក្នុង “A” ជាលើកទីពីរ ។ ៤,៥,៦ និង ៧ ជាការិយាល័យបន្តបន្ទាប់នៅពេលដែលការឃុំខ្លួន បន្ទាប់មកមានការសួរចម្លើយប្រព្រឹត្តនៅក្នុង “B” នៅក្នុង “B” ហ្នឹងបានន័យថាសារមន្ទីរទួលស្លែងទាំងមូល ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ចង់មានបញ្ហាអីទៅ?

[០៩:១៥:00]

*(អ្នកបកប្រែ៖ សូមអនុញ្ញាតពីលោកប្រធានឲ្យមេធាវីបើកមីក្រូហ្វូន)*

**មេធាវី គង់ សំអុន៖**

ដូចខ្ញុំសូមបញ្ជាក់ម្តងទៀតថា លេខដែលសរសេរក្នុងតារាងនេះវាតូចៗ ហើយវាអត់សូវច្បាស់ គាត់មិនអាចមើលឃើញព្រោះលេខវាច្រើនណាស់ មិនមែនមានតែមួយលេខទេដល់ ៦ ទៅ ៧ លេខ ។ សូមដាក់ពណ៌ឲ្យច្បាស់លេខ១ លេខ២ លេខ៣ ដល់លេខ៧ ដែលមាននៅក្នុងហ្នឹង ដើម្បីឲ្យគាត់ចង្អុលបង្ហាញ វាមានភាពងាយស្រួល ។ សូមអរគុណ ។

**លោក តាន់ សេណារ៉ុង៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីសុំឲ្យលោកក្រឡាបញ្ជើយករូបភាព ដែលមាននៅដៃខ្ញុំនេះទៅជូនលោក ម៉ម ណៃ ដើម្បីនឹងធ្វើការពិនិត្យផ្ទាល់ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** តើលោកចាំបានទេថាកន្លែងណាដែលលោក-- ព្រោះលេខ៦ គឺជាផ្ទះរបស់-- លេខ៤ លេខ៥ លេខ៦ លេខ៧ ហើយខាងលើផ្នែកខាងជើង ហើយលោកអាចចង្អុលបង្ហាញពីកន្លែងណាដែលលោកធ្លាប់បានសួរចម្លើយអ្នកទោសនោះ?

**ឆ៖** សូមជម្រាបលោក ខ្ញុំមើលមិនសូវយល់ទេ បើសិនជាមានអូរទឹកស្អុយនោះ ខ្ញុំអាចបង្ហាញច្បាស់លាស់ ។ ក៏ប៉ុន្តែ នេះខ្ញុំមើលមិនឃើញមានដាក់ថាអូរទឹកស្អុយនោះផង ពីព្រោះផ្ទះខ្ញុំស្នូរចម្លើយនៅជាប់នឹងអាអូរទឹកស្អុយហ្នឹង ។

**លោក តាន់ សេណារ៉ុង៖**

អ៊ីចឹងអរគុណលោក ។ បើលោកមិនទាន់ (ស្តាប់មិនច្បាស់) ផែនទីដែលមានគំនូសតាងដែលមានអូរទឹកស្អុយ អ៊ីចឹងខ្ញុំបន្តសំណួរដល់លោកទៀត សូមលោក-- សូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញរូបភាពមួយទៀត ដែលមានលេខ ERN 00181427 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ដាក់រូបភាពលើអេក្រង់ទូរទស្សន៍ តាមសំណើរបស់តំណាងព្រះរាជអាជ្ញាជាតិ ។

[០៩:១៩:២០]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ម៉ម ណៃ លោកបានឃើញរូបថតនេះហើយឬនៅ? តើលោកចាំបានទេ? លោកអាចបង្ហាញជូនអង្គជំនុំជម្រះបានទេថា រូបណាមួយជារូបលោក?

**ឆ៖** សូមជម្រាបលោកខ្ញុំមើលឃើញមិនសូវច្បាស់ ប៉ុន្តែខ្ញុំគ្រាន់ប្រហែលថានៅពីក្រោយស្រីពកូននេះប្រហែលគឺរូបខ្ញុំ ហើយស្រីពកូននេះប្រហែលជាប្រពន្ធខ្ញុំហើយ ។

**ស៖** លោកអាចរៀបរាប់បន្តបន្ទាប់ទេបានទេថា អ្នកបន្តនៅខាង មើលពីមុខចំខាងស្តាំដៃលោកស្រីហ្នឹងជាអ្នកណា? ប្រុសខាងក្រោយជាឈ្មោះអី? បន្តបន្ទាប់ហូរហែមករហូតដល់ចុងខាងស្តាំ ។

**ឆ៖** នេះគឺថាស្រីនេះខ្ញុំភ្លេចឈ្មោះហើយ ប្រុសនេះប្រហែលជាឈ្មោះ ម៉ុន ហើយបន្ទាប់មកទៀតស្រីនេះគឺភរិយាមិត្ត ឌុច ប្រហែលជា តាមខ្ញុំចាំប្រហែលជាឈ្មោះ រុំ ហើយនេះគឺមិត្តឌុច ។ ឯស្រីនេះខ្ញុំក្តាប់មិនបានទេ ហើយប្រុសនេះក៏ខ្ញុំក្តាប់មិនបានដែរ ។ សូមជម្រាបលោកជ្រាប ។

**ស៖** អរគុណលោក ។ តើរូបថតនេះលោកថតនៅទីណាដែរលោក?

**ឆ៖** សូមជម្រាបលោកខ្ញុំក្តាប់មិនបានដែរ ។ វាចាំមិនបានមិនដឹងនៅកន្លែងណា ។

**ស៖** អរគុណលោក ។ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញរូបភាពមួយទៀតគឺលេខ 00005254 ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតតាមការសុំនេះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោកបានឃើញរូបនេះទេ? លោកស្គាល់ទេអ្នកដែលថតរូបទាំងអស់គ្នានេះថាតើអ្នកណា? ចាប់ពីឆ្វេងដៃទៅ ។ សូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីឲ្យក្រឡាបញ្ជីយករូបភាពមួយនេះជូនគាត់ ដើម្បីឲ្យបានច្បាស់ ។

**ឆ៖** សូមជម្រាបលោក! ខ្ញុំមើលរូបទាំងនេះខ្ញុំមិនអាចចាំបានទេ មិនដឹងអ្នកណាជាអ្នកណាទេ ។

**ស៖** អ៊ីចឹងអរគុណលោក ។ ខ្ញុំបន្តសំណួរទៅទៀត សំណួរបន្ទាប់ នៅពេលដែលលោក កាំង ហ្គេកអ៊ាវ នាសម័យកាលនោះជាប្រធានមន្ទីរស-២១ តើលោកមានអារម្មណ៍ភ័យខ្លាចគាត់ដែរឬទេពេលនោះ?

[០៩:២៣:៤៣]

**ឆ៖** ជម្រាបប្រសាសន៍លោក! ក្រោយពីថ្ងៃគាត់ប្រាប់ខ្ញុំថាខ្លាំងឆ្លើយដាក់ខ្ញុំ ហើយគាត់វាយកាណ៍ទៅលើ ហើយបញ្ឈប់ខ្ញុំលែងឲ្យសួរចម្លើយនោះ ខ្ញុំភ័យដែរៗ ភ័យមែនទែនពេលគាត់ប្រើចេញក្រៅម្តងៗ ខ្ញុំខ្លាចតែគាត់ប្រើឧបាយកលឲ្យគេចាប់ខ្ញុំ ។ រហូតមកថ្ងៃយើងត្រូវកងទ័ពយួនចូលនេះបានខ្ញុំឈប់ភ័យទៅ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ សំណួរបន្ទាប់ ពាក់ព័ន្ធនឹងចម្លើយសារភាពរបស់អតីតសាស្ត្រាចារ្យមួយឈ្មោះ ភីង តុន ។ សូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារលេខ 000188839 ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ម៉ម ណៃ ថាតើសំណេរនៅលើចម្លើយសារភាព របស់អតីតសាស្ត្រាចារ្យនេះគឺជាសំណេររបស់ទេ មែនទេ?

**ឆ៖** អក្សរនេះគឺថា តាមខ្ញុំមើលគឺប្រហាក់ប្រហែលខ្ញុំ អក្សរខ្ញុំ ក៏ប៉ុន្តែខ្ញុំវាក្តាប់មិនបាន តើខ្ញុំបានសួរលោក ភីង តុន ឬអត់? អាហ្នឹងខ្ញុំភ្លេចហើយ ក៏ប៉ុន្តែអក្សរនេះគឺ វាប្រហាក់ប្រហែលនឹងអក្សរខ្ញុំណាស់ ។

**ស៖** បើសិនជាអក្សរនេះប្រហាក់ប្រហែលជារបស់លោក តើលោកចាំអាចរំឭកឡើងវិញបានទេថាលោកពិតជាបានសួរចម្លើយអ្នកទោសរូបនេះ?

**ឆ៖** ខ្ញុំមិនអាចនឹកឃើញទេ ក៏ប៉ុន្តែអក្សរហ្នឹងវាអក្សរខ្ញុំហើយ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ សំណួរបន្ទាប់ សូមអង្គជំនុំជម្រះឲ្យខាងសោតទស្សន៍ បង្ហាញលេខ ERN 00226555 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ បង្ហាញនូវឯកសារលើអេក្រង់ទូរទស្សន៍ តាមសំណូមពររបស់តំណាងសហព្រះរាជអាជ្ញាជាតិ ។

[០៩:២៧:០៦]

*(អ្នកបកប្រែ៖ លោកចៅក្រមប្រធាន! សូមលោកជួយឲ្យលោកសហព្រះរាជអាជ្ញាលោកអាន ERN Number ឡើងវិញបន្តិចទាន ព្រោះអ្នកបកប្រែ បកមិនទាន់)*

**លោក តាន់ សេណារ៉ុង៖**

លេខ ERN 00226555 ។ សូមអធ្យាស្រ័យដោយមានការភាន់ច្រឡំ ERN Number បាទ ។ សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីជូនឯកសារមួយនេះទៅដល់លោកសាក្សី ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** តើលោកអាចសម្គាល់បានទេនូវសំណេរចុងក្រោយរបស់លោក ដែលលោកបានស្នើថាសុំដោះលែងនៅទំព័រចុងក្រោយ? ហើយឯកសារនេះលោកចៅក្រម ហ្សង់ម៉ាក បានបង្ហាញពីម្សិលមិញនៅទំព័រដើម ក៏ប៉ុន្តែថ្ងៃនេះខ្ញុំបង្ហាញទំព័រចុង ។ ក៏ប៉ុន្តែនៅក្នុង ERN ខាងសហព្រះរាជអាជ្ញាវាអត់ចេញអាទំព័រចុងរបស់ឈ្មោះ ឈៀវ ស៊ុនហេង ហ្នឹង ។ តើលោកចាំបានទេលោក?

**ឆ៖** សូមជម្រាបលោក! ឯកសារនៅនឹងដៃខ្ញុំនេះ គឺថាវាអក្សរខ្ញុំ ហើយបានចារថាសុំដោះលែងមែន ។

**ស៖** តើក្នុងនោះរូបជនជាប់ចោទហ្នឹង ត្រូវបានដោះលែងតាមការស្នើសុំរបស់លោកទេ?

**ឆ៖** បញ្ហានេះ ខ្ញុំអត់ដឹងទេ ។ ខ្ញុំគ្រាន់តែមានភារកិច្ចសរសេរថា សុំដោះលែងតែប៉ុណ្ណឹង ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់ទៀត ទៅលើ ERN លេខ 00026082 ទៅលើអ្នកទោសឈ្មោះ វ៉ាន់ ពីនី នៅក្នុងទំព័រលេខ 00026177 ។ តើលោកអាចមើលឃើញទេ នៅក្នុងអេក្រង់ទូរទស្សន៍នេះ ថាសំណេរទៅលើកំណត់ហេតុចម្លើយសារភាពនេះ គឺជារបស់លោក?

**ឆ៖** សូមជម្រាបលោក អក្សរហ្នឹង គឺអក្សរខ្ញុំហើយ ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់ ទៅលើឈ្មោះ គ្រិន លាន ហៅ សំ ដែលមាន-- នៅត្រង់ទំព័រលេខ 00081842 ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។ ដក ចាំដកម៉ោង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំរីករាយណាស់ ប្រសិនបើសាក្សីបង្ហាញឯកសារជាភាសាខ្មែរ ។ ខ្ញុំខ្លួនឯងមិននិយាយភាសាខ្មែរនោះទេ ទោះបីយ៉ាងនេះក៏ដោយ ។ ប៉ុន្តែខ្ញុំចង់ដឹងថា តើឯកសារទាំងអស់នោះ វានិយាយអំពីអ្វី? ឯកសារចុងក្រោយ ទើបតែបង្ហាញនេះ អត់មានការបកប្រែនោះទេ ។ ដូច្នេះហើយយើងក៏មិនទាន់បានទទួលការបកប្រែ-- ទទួលបានឯកសារបកប្រែដែរ ។ ដូច្នេះហើយខ្ញុំមិនដឹងថាវាលើកឡើងអំពីអ្វីនោះទេ ។ ដូច្នេះខ្ញុំ យ៉ាងហោចណាស់ក៏ចង់ឲ្យជម្រាបខ្ញុំដែរ ថាតើឯកសារនេះនិយាយអំពីអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង តំណាងសហព្រះរាជអាជ្ញាក៏មិនមានការចាប់អារម្មណ៍លើបញ្ហាពីរចំណុច ។ ទីមួយ គឺរាល់ការបង្ហាញឯកសាររបៀបនេះ សូមថតចម្លងបញ្ជូនទៅឲ្យសាក្សីដើម្បីពិនិត្យផ្ទាល់ ជាជាងគាត់ពិនិត្យមើលនៅក្នុងអេក្រង់ទូរទស្សន៍ ដោយសារគាត់វ័យចំណាស់ហើយ ហើយគាត់អាចមើលក្រៅហ្នឹងច្បាស់ជាង ។ បញ្ហាពីរ សូមធ្វើការបង្ហាញនូវខ្លឹមសារ គោលបំណងនៃការសួរដល់សាក្សីរូបនេះអំពីខ្លឹមសារនៃលិខិត ដែលនាំឲ្យមានការសួរដេញដោលនោះ ។ ខ្លឹមសារ រូបភាព ឬក៏យ៉ាងម៉េច ដើម្បីឲ្យមានការភាគីទាំងអស់បានស្តាប់បាននូវបញ្ហានោះ ហើយកត់ត្រាចូលទៅក្នុងប្រតិចារឹកបានត្រឹមត្រូវផង ។

[០៩:៣៥:១៦]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធាន ។ ហើយឯកសារទាំងអស់នេះ គ្រាន់ គឺតំណាងសហព្រះរាជអាជ្ញា គឺចង់បង្ហាញថា លោក ម៉ម ណៃ នៅសម័យកាលនោះ គាត់បានសួរចម្លើយនូវអ្នកទោសដ៏ច្រើន ដើម្បីឱ្យគាត់នឹកឃើញនូវអត្តសញ្ញាណអក្សររបស់គាត់ ដែលគាត់បានសួរចម្លើយទៅលើជនជាប់ចោទនាពេលនោះទេ ។ មិនមានអ្វីជាសំខាន់លើសពីការដែលសហព្រះរាជអាជ្ញានឹងចង់បានទេ ។ គឺចង់បានឱ្យគាត់សម្គាល់ថា គាត់ពិតជាបានសួរចម្លើយទៅលើអ្នកទោសទាំងអស់នោះប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

នោះ គឺការយល់របស់លោកទេ ប៉ុន្តែភាគីដទៃទៀតអត់យល់ទេ ។ អ៊ីចឹងហើយបានជាឱ្យបញ្ជាក់នូវខ្លឹមសារនូវលក្ខណៈនៃប្រភេទលិខិត ឬក៏ខ្លឹមសារលិខិតដែលបង្ហាញនេះ ដើម្បីឱ្យប្រតិចារឹកមានការយល់ទូទៅទាំងអស់គ្នា និងអ្នកចូលរួមនីតិវិធីនេះ ។ លោកនិយាយអំមិញ គឺយល់ម្នាក់ឯង អ្នកផ្សេងទៀតអត់បានយល់ទេ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ អ្វីដែលតំណាងសហព្រះរាជអាជ្ញាបានបង្ហាញជូន និងលើកពេលនេះ គឺជាចំណារ មានចំណាររបស់លោក ម៉ម ណៃ ហៅ ចាន់ នៅក្នុង-- លើចម្លើយសារភាពរបស់អ្នកទោសទាំងនោះ ។ ហើយពេលខ្លះគាត់បានសរសេរចម្លើយសារភាពនោះ ទាំងស្រុងរបស់អ្នកទោសទ្ទុំងផងដែរ ។ ឧទាហរណ៍ដែលគាត់បានសរសេរ ដែលគាត់ថា ប្រហែលជាចំណាំបានថា អក្សររបស់គាត់ទៅលើអតីតសាស្ត្រាចារ្យមួយ ឈ្មោះ ភឹង តុន ។ គ្រាន់តែជាលើក ជាចំណុចមួយដែលសហព្រះរាជអាជ្ញាចង់ជម្រាបជូនប៉ុណ្ណោះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួរបន្ទាប់ ដែលសហព្រះរាជអាជ្ញាចង់សួរបន្តទៀត ទៅលើការសួរចម្លើយជន-- អ្នកទោសរបស់ជនជាតិអឺរ៉ុប ក្នុងនោះមាននិយាយជនបរទេសនោះមិននិយាយយោងទៅលើជនជាតិវៀតណាមទេ ។ ចម្លើយសារភាពរបស់លោក *ជេម វីលៀម ខ្លាក* ដែលមាននៅក្នុងលេខ ERN លេខ 00006979 ។ តំណាងសហព្រះរាជអាជ្ញាចង់សួរថា តើលោកពិតជាបានសួរចម្លើយទៅលើជនបរទេសឈ្មោះ *វីលៀម ខ្លាក* ហ្នឹង មែនទេ? តើលោកអាចមើលឃើញទេ?

**ឆ៖** ខ្ញុំសុំមិននិយាយ ។

**លោក គាន់ សេណារ៉ុង៖**

អរគុណលោក ម៉ម ណៃ ។ ដោយពេលវេលាខ្ញុំអស់ហើយ ខ្ញុំសូមជូននាទីបន្ទាប់ទៅសហការី របស់ខ្ញុំ ដើម្បីសាកសួរបន្ត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

[០៩:៣៩:៤៨]

**សួរដោយ លោក វីលៀម ស្មីត៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី និងភាគីទាំងអស់ ហើយនិងលោក ម៉ម ណៃ ។

**ស៖** លោក ម៉ម ណៃ នៅពេលនេះ ខ្ញុំចង់និយាយទៅលោកមិនមែនអំពីប្រភេទនៃមនុស្សដែល លោកសួរចម្លើយនោះទេ ប៉ុន្តែខ្ញុំនិយាយអំពីចំនួនអ្នកដែលលោកសួរចម្លើយ ។ កាលពីម្សិលមិញលោក បានលើកឡើងនៅក្នុងតុលាការថា លោកបានសួរចម្លើយវាពិបាក-- លោកថាពិបាកណាស់ លោកដែល ថាលោកសួរប្រហែលជាម្ភៃទៅម្ភៃនាក់ទេ សួរទាហានវៀតណាម ។ ហើយនៅក្នុងការសម្ភាសន៍របស់ លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ D22/16 លោកបានលើកឡើងថា លោក សួរទាហានវៀតណាមតិចជាងហាសិប ។ ដូច្នេះកាលពីម្សិលមិញ លោកបាននិយាយថាដប់នាក់ ហើយ កាលពីឆ្នាំទៅលោកនិយាយថា តិចជាងហាសិបនាក់ ។ ដោយយើងចាំថា លោកបានជម្រាបជាមួយនឹង អង្គជំនុំជម្រះ ហើយដោយសូមរំឭកថា លោកត្រូវបង្ហាញអំពីការពិតនៅក្នុងរឿងក្តីនេះ ។

ខ្ញុំសូមសួរសំណួរមួយចំនួនទៅកាន់លោក ដើម្បីឲ្យលោកធ្វើការវាយតម្លៃសាជាថ្មី ដើម្បីគិតឡើង វិញអំពីចំនួនមនុស្សដែលលោកបានសួរចម្លើយនៅស-២១ ។ នៅក្នុងវិធីនេះ ខ្ញុំធ្វើយ៉ាងណាសុំឲ្យលោក ធ្វើការរំឭក ឬក៏ធ្វើយ៉ាងណាឲ្យចងចាំទៅលើអារម្មណ៍របស់លោកឡើងវិញ ។ ទាក់ទងទៅនឹងទាហាន វៀតណាម នៅពេលនេះខ្ញុំនិយាយអំពីទាហានវៀតណាម ។ លោក គឺជាបុគ្គលអ្នកសួរចម្លើយចម្បង នៅស-២១ ដែលសួរទៅលើទាហានវៀតណាម ដោយសារតែលោកចេះភាសា ។

**ឆ៖** សូមជម្រាបប្រសាសន៍លោក! តាមខ្ញុំចាំម្សិលមិញ ដូចខ្ញុំនិយាយថា ប្រហែលម្ភៃទៅសាម សិបនាក់ ។ អានេះខ្ញុំនិយាយម្សិលមិញ នេះតាមខ្ញុំចាំ មិនមែនដប់ដូចលោកលើកឡើងនោះទេ នេះ

ម្យ៉ាង ។ ម្យ៉ាងទៀត កាលអ្នកអង្កេតការណ៍ទៅ-- អ្នកអង្កេតទៅស៊ើបសួរខ្ញុំ ខ្ញុំថាក្រោមហាសិប ។ ដូច្នេះ ម្ភៃនិងសាមសិប វាត្រូវក្រោមហាសិប ហើយវាអត់មាននៅលើទេ វានៅក្រោមហាសិប នេះសូមលោកជ្រាប ។

**ស៖** សូមអរគុណ ។ សំណួរចុងក្រោយរបស់ខ្ញុំនោះ គឺថាតើលោកយល់ស្របដែរឬទេ? ថា លោក គឺអ្នកសួរចម្លើយចម្បង ជាពិសេសសួរជនជាតិវៀតណាមនៅ ស-២១ ។

**ឆ៖** ជម្រាបលោក នៅស-២១ ខ្ញុំជាអ្នកសួរចម្លើយយួនមែន ដោយមានឈ្មោះ ចាន់ មកពីហាណូយ ជាអ្នកជួយបកប្រែ ។

**ស៖** ហើយ ជា សេង ក៏បានជួយលោកដែលនៅក្នុងការងារនុ៎ង ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សុំលោកបញ្ជាក់ឈ្មោះម្តងទៀត ខ្ញុំស្តាប់មិនទាន់ ។

**ស៖** ឈ្មោះនោះ គឺ ជា សេងៗ ។

**ឆ៖** ខ្ញុំដូចជាមិនដែលឮថា ជា សេង ផង ។ ខ្ញុំ បើម្នាក់ឈ្មោះ ម៉េង នោះធ្លាប់ចូលរួមសួរម្តង ហើយបើ ពូហ៊ី ម្តងម្កាល គាត់ជាអនុប្រធានគាត់ចូលទៅសួរពីរបីម៉ាត់ទៅ គាត់ចេញបាត់ទៅ ។

**ស៖** សូមអរគុណ ។ ចំណុចនេះ គឺជនជាប់ចោទបានលើកឡើងនៅក្នុងចម្លើយរបស់គាត់ ថា មានអ្នកសួរចម្លើយបីនាក់ដែលសួរវៀតណាម ហើយមានបង ម៉ម ណៃ ដែលគាត់ធ្វើការងារហ្នឹង ហើយនិង ផា ថាចាន់ ដែលជាអ្នកបកប្រែមកពីហាណូយ ថាជាប់ឃុំនៅស-២១ ។ ហើយនិង ចៅ សេង ដែលគាត់ហ្នឹងកៀកណាស់ជាមួយនឹង ម៉ម ណៃ ហើយគាត់-- បុគ្គលនោះគោរពគាត់ណាស់ ។ គឺចម្លើយនេះបានលើកឡើងនៅថ្ងៃទី10 ខែមិថុនា នៅក្នុងទំព័រទីប្រាំបួន ។ តើលោកបានចាំទេ នៅពេលដែលខ្ញុំលើកឡើងដូច្នេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប្រសិនបើសហព្រះរាជអាជ្ញាទូលាយនោះ គឺសូមឲ្យគាត់ធ្វើលេខ-- បង្ហាញលេខយោងផង ដោយសារតែគាត់បានបង្ហាញតែថ្ងៃ10 ខែមិថុនា ទំព័រប្រាំបួននោះទេ ។ អ៊ីចឹង សូមឲ្យគាត់បង្ហាញអំពីលេខយោងផងដែរ ដើម្បីកត់ក្នុងប្រតិចារឹក ។ សូមអរគុណ ។

**លោក វីលៀម ស្មីត៖**

គឺឯកសារយោងដូចខ្ញុំបញ្ជាក់ ថាចុះថ្ងៃ១០ ខែមិថុនា ទំព័រទីប្រាំបួន ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** លោក ម៉ម ណៃ តើលោកចាំទេ ដែលបើ-- នៅពេលដែលខ្ញុំលើកឡើងដូច្នេះ គឺថា ចៅ សេង នេះ គាត់បានជួយលោកក្នុងការសួរចម្លើយ?

**ឆ៖** សូមជម្រាបលោកព្រះរាជអាជ្ញា ខ្ញុំមិនចាំទេ ក៏ប៉ុន្តែ ចៅ សេង បើថា ចៅ សេង មានតែគ្រូខ្ញុំៗ ដែលគេចាប់ទៅ ហើយមិត្ត ឌុច ឲ្យខ្ញុំទៅសួរគាត់ប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជំនួយសាក្សី ។

**លោក គង់ សំអុន៖**

អំមិញខ្ញុំស្តាប់តាមរយៈការបកប្រែ មិនដឹងជាច្រឡំ ឬមួយយ៉ាងម៉េច ព្រោះឮឈ្មោះម្តងថា ជា សេង ហើយក្រោយមកបានទៅសួរថា ចៅ សេង ។ ហើយសូមខាងព្រះរាជអាជ្ញា មេត្តាបញ្ជាក់ទៅសាក្សីឲ្យបានច្បាស់ផង ថា ជា សេង ឬមួយក៏ ចៅ សេង?

សូមអរគុណ ។

[០៩:៤៧:៣៤]

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ឈ្មោះនោះ គឺ ចៅ សេង ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** ប្រហែលយើងអាចធ្វើការបន្តទៀតលោក ម៉ម ណៃ លោកបាននិយាយថា លោកគឺជាអ្នកសួរចម្លើយតែម្នាក់ប៉ុណ្ណោះ ដែលសួរវៀតណាម ហើយទាក់ទងទៅនឹងចម្លើយ ដែលអង្គជំនុំជម្រះបានឮនោះ គឺមានអ្នកជាប់ឃុំ១២២នាក់ នៅក្នុងស-២១ ដែលជាទាហានវៀតណាម ។ ហើយគឺនេះ គឺមានឯកសារលេខ E28.2 យើងឃើញថា មានយុទ្ធជនវៀតណាម១២២នាក់ ដែលជាប់ឃុំនៅស-២១ ។ តើលោកសួរចម្លើយអ្នកទាំងអស់នោះទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំបានសួរតែប្រហែលក្រោមហាសិបនាក់ប៉ុណ្ណឹងទេ ។ ឯមួយចំនួនជាពួកមក-- ពួកហ្នុលរ៉ូអាហ្នឹងខ្ញុំសួរចម្លើយ គឺពួកចារាយ ហើយនិងរដែ ដល់សួរទៅក្រោយមក មិត្តឌុច បានទទួលសេចក្តី

មកពីលើប្រាប់ថា ពួកនេះជាអ្នកមកសុំជំនួយពីយើងទៅវាយយួនទេ ហើយឲ្យដោះលែងទៅ ។ ហ្នឹងពួកហ្នឹងមានច្រើនដែរ ក៏ប៉ុន្តែខ្ញុំមិនដឹងប៉ុន្មាន ។ នេះខ្ញុំសូមជម្រាបលោកតាមត្រង់ប៉ុណ្ណឹង ។

**ស៖** លោកកាលពីម្សិលមិញបាននិយាយថា សួរចារកម្មវៀតណាមម្នាក់ ឬក៏ពីរនាក់ ហើយខ្ញុំចង់លើកឡើងចម្លើយរបស់ជនជាប់ចោទដែលគាត់បានលើកឡើង គឺនៅក្នុងទំព័រទី១០ ថ្ងៃទី១០ ខែមិថុនា ជនជាប់ចោទត្រូវបានសួរថា នៅពេលដែលចារកម្មនោះត្រូវបានចាប់ចូលទៅស-២១ តើជនជាប់ចោទមានការរៀបចំឲ្យសួរចម្លើយដែរឬទេ? ជនជាប់ចោទ បានបញ្ជាក់ថា ខ្ញុំចង់បញ្ជាក់ថា នៅពេលដែលពួកចារកម្មបានបញ្ជូនទៅចូលស-២១ ខ្ញុំបង្គាប់បញ្ជាឲ្យបង ម៉ម ណៃ ធ្វើការសួរចម្លើយ គ្មានអ្នកណាផ្សេងជាអ្នកសួរទេ ដោយសារតែបង ម៉ម ណៃ គាត់អាចនិយាយភាសាបាន ។ ហើយគាត់ គឺជាអ្នកដែលមានលទ្ធភាព ហើយមានសមត្ថភាពក្នុងការសួរអ្នកទាំងអស់នោះ ។

លោក ម៉ម ណៃ តើលោកមានយោបល់យ៉ាងម៉េចទៅលើចំណុចនេះ? ចំពោះភាពត្រឹមត្រូវយ៉ាងម៉េច ដែលជនជាប់ចោទបានលើកឡើងទាក់ទងនឹងចម្លើយនេះ?

[០៩:៥០:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំសុំមិនឆ្លើយ ។

**ស៖** សូមអរគុណ ។ ហើយអង្គជំនុំជម្រះបានឮចម្លើយថា មានចំនួន១៤៤នាក់ជាចារកម្មនៅក្នុងឯកសារ ស-២១ គឺលេខឯកសារលេខ E68/2 ។ ថាតើលោកបានសួរចម្លើយអ្នកចារកម្ម ដែលមានចំនួនដូចខ្ញុំបានលើកឡើងអម្បាញ់មិញដែរឬទេ ដែលគេបានបញ្ជូនមកស-២១ នោះ?

**ឆ៖** អម្បាញ់មិញខ្ញុំបានឆ្លើយជាមួយលោកថា ខ្ញុំមិនឆ្លើយទេ ។

**ស៖** សូមអរគុណលោក ម៉ម ណៃ ខ្ញុំនឹងមិនបន្តសួរអំពីការសួរចម្លើយរបស់លោកលើជនជាតិវៀតណាមនោះទេ ។ ខ្ញុំចង់សួរលោកមួយទៀតអំពីការដឹង អំពីការរៀបចំ ការសួរចម្លើយនៅស-២១ ហើយប្រហែលខ្ញុំនៅពេលនេះ អាចលើកឡើងចម្លើយរបស់លោក ដែលលោកបានឆ្លើយជូនលោកចៅក្រម ធូ មណី ម្សិលមិញ ។ លោកចៅក្រមសួរថា តើលោកដឹងយ៉ាងម៉េចអំពីអង្គភាពផ្សេងៗនៅ ស-២១? លោកមិនដឹងទេ ប៉ុន្តែលោកដឹងអំពីអង្គភាពការពារ អង្គភាពស្រែ និងអង្គភាពសួរចម្លើយ ។ ហើយលោកក៏បានលើកឡើងបន្តទៀតថា ទាក់ទងទៅនឹងអង្គភាពសួរចម្លើយភារកិច្ចនោះ គឺសួរចម្លើយ។ ប៉ុន្តែ លោកមិនដឹងពិស្តារ ឬល្អិតល្អន់អំពីរចនាសម្ព័ន្ធស-២១ នោះទេ ។ ខ្ញុំចង់បង្ហាញឯកសារមួយនៅលើអេក្រង់ យើងមានឯកសាររឹងសម្រាប់លោកផងដែរ លេខ D64 លេខខ្មែរ ERN គឺ 00071150 និង

ក្នុងភាសាអង់គ្លេស គឺលេខ 00178176 ។ ហើយខ្ញុំអត់ដឹង ថាតើវាមានឯកសារជាភាសាបារាំងទេនៅទីនេះ គឺឯកសារនេះចុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៧ ។ ហើយខ្ញុំឲ្យសូមមន្ត្រីតុលាការយកឯកសាររឹងនេះជូនសាក្សី ។

ឯកសារនេះ គឺមានចំណងជើងថា “ផែនការសួរចម្លើយ” ដែលមានរយៈពេលបីខែ ជាឯកសារស-២១ ។ លោក ម៉ម ណៃ តើនេះជាសំណេររបស់លោកមែនឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះគឺជាចំណាររបស់ខ្ញុំ ពិតមែន ។

**ស៖** ប្រហែលខ្ញុំអាចធ្វើការសង្ខេបឯកសារនេះបាន ឯកសារនេះជាមូលដ្ឋាន គឺទាក់ទងទៅនឹងផែនការ ។ ថាតើអ្នកសួរចម្លើយជួបគ្នាញឹកញយប៉ុនណា? ហើយនិងការបែងចែកការងាររបស់អ្នកសួរចម្លើយនិងការទទួលខុសត្រូវទៅលើការងារ ។ ប្រសិនបើយើងមើលទៅលើឯកសារទាំងអស់នេះ នៅក្នុងវាក្យខណ្ឌមួយ ឬក៏ពីរនៅក្នុងភាសាអង់គ្លេស លោកត្រូវបានចាត់តាំងឲ្យធ្វើការគ្រប់គ្រងក្តោបឯកសារអ្នកថ្មី និងចាស់ ហើយ ម៉េង គឺទទួលខុសត្រូវលើឯកសារចេញចូល ។ តើលោកឃើញទៅលើចំណុចនេះដែរឬទេ? ម៉េង ក្តាប់យកឯកសារ-- ក្តាប់ឯកសារប្រចាំថ្ងៃរាយការណ៍ចេញចូលឲ្យបានហើយលោកក្តាប់មនុស្សចូលថ្មី និងសល់ឲ្យអស់ ។ នេះ គឺជាឯកសារ លោកឃើញហើយ វាអាចបង្ហាញជូនលោកបានហើយនៅពេលនេះ ។

[០៩:៥៦:១៣]

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ខ្ញុំឃើញឯកសារនេះ តែខ្ញុំនឹកមិនឃើញពេលនោះទេឃើញចារឲ្យក្តាប់មនុស្សថ្មី នែមនុស្សចូលថ្មី ហើយនៅសល់ឲ្យអស់ ហើយដាក់ឈ្មោះខ្ញុំ ។ ខ្ញុំឃើញក៏ប៉ុន្តែ ខ្ញុំនឹកមិនឃើញទេ កាលនៅពេលនេះ ។

**ស៖** ប្រសិនបើខ្ញុំធ្វើការសង្ខេបឯកសារនេះខ្លីៗ ឯកសារនេះ គឺបានបែងចែកអ្នកសួរចម្លើយជាដប់មួយក្រុម ហើយបំបែកជាបីក្រុមធំៗ ដែលមានប្រធាន ស្ពួន ដែលទទួលខុសត្រូវ ប្រាំ ប្រាំមួយ និងប្រាំបី នៅក្នុងឯកសារនេះ នៅក្នុងចំណុចចុងក្រោយ ។ ហើយមានបុរសមួយទៀត គឺទទួលខុសត្រូវប្រាំពីរ ប្រាំបួន ដប់មួយ ហើយ ប៉ុន ទទួលខុសត្រូវ មួយ ពីរ និង បី ។ ហើយឯកសារនេះក៏បានពន្យល់ថា តើអ្នកសួរចម្លើយជួបគ្នាញឹកញយប៉ុនណា? ហើយបង្ហាញថាជួបគ្នាក្នុងរយៈពេលបីថ្ងៃម្តងហើយចំពោះបទពិសោធការងារមួយខែម្តង ហើយប្រជុំជីវភាព មួយខែម្តង ។ ហើយអាទិត្យទីមួយទទួល-- ពិនិត្យមើលទៅជីវប្រវត្តិ និងចម្លើយសារភាពផ្សេង ហើយមួយខែម្តង គឺធ្វើការចូលរួមបណ្តុះ

បណ្តាលនៅក្នុងបញ្ហាបច្ចេកទេសការងារផ្សេងៗ ។ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ? ដោយថា យើងចាំ ថាលោកបានសរសេរឯកសារនេះ ។

នៅពេលដែលលោកសរសេរឯកសារនេះនៅស-២១ លោកដឹងទាំងស្រុងតែម្តងអំពីការចាត់តាំង និងរចនាសម្ព័ន្ធអង្គភាពសួរចម្លើយ ។ ហើយលោកជាអ្នកសម្របសម្រួលចម្បងមួយចំពោះផ្នែកស៊ើប សួរ សួរចម្លើយ ។ មិនមែនជាបុគ្គល ដែលនៅដាច់នៅក្នុងផ្ទះមួយតែឯងនោះទេ ដែលទទួលខុសត្រូវតែ សួរចម្លើយដប់-- ទាហានវៀតណាមដប់ ឬក៏ខ្មែរនាក់ ក្នុងរយៈពេលបីឆ្នាំជាងនោះទេ ។

តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ ថាលោកទទួលការងារនេះជាមួយនឹង ប៉ុន នៅ ស-២១?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោក! ខ្ញុំអត់យល់ស្របទេ ។

**ស៖** ទោះបីជាលោកសរសេរឯកសារនេះក៏ដោយ ហើយលោកពន្យល់ ថាតើគេរៀបចំអង្គភាព នេះយ៉ាងម៉េច ជាក្រុមផ្សេងៗ? ហើយតើគេជួបគ្នាយ៉ាងម៉េច ញឹកញយប៉ុនណា? ទោះបីជាយ៉ាងនេះក៏ ដោយ លោកមិនយល់ស្របជាមួយអ្វី ដែលខ្ញុំលើកឡើងនេះទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំមិនយល់ស្រប ព្រោះថានេះជាពួកសម្ព័ន្ធយុវកក ។ ដូច្នេះ ប្រហែលជាការប្រជុំជីវភាព សម្ព័ន្ធយុវកកនៅទីនោះទេ ។

[១០:០០:០០]

**ស៖** សូមអរគុណ ហើយលោកយល់ស្របជាមួយខ្ញុំថា ឯកសារនេះមានចំណងជើងថា ផែនការ ការងារចំពោះអ្នកសួរចម្លើយសម្រាប់រយៈពេលបីខែ ។ តើលោកយល់ស្របជាមួយខ្ញុំស្តីអំពីចំណងជើង ឯកសារនេះដែរឬទេ?

**ឆ៖** ខ្ញុំយល់ថា ការសរសេរឯកសារនេះគឺថា ជាអក្សរខ្ញុំប៉ុណ្ណោះ ។

**ស៖** សូមអរគុណលោកម៉ម ណៃ ។ ពីម្សិលមិញលោកបានប្រាប់ទៅតុលាការហើយបានផ្តល់ ឯកសារមួយសំណុំហើយយើងបានជូនទៅតុលាការពីសៀវភៅចំណារផ្ទាល់ដៃ ជាសៀវភៅកំណត់ហេតុ ផ្ទាល់ដៃ៣៩៦ទំព័រ ហើយជាឯកសារនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៧ គឺនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើប សួរនោះគឺឯកសារ C14/3 លេខERNជាភាសាខ្មែរនោះគឺមាននៅក្នុង 00189100– 00184579 រហូតទៅដល់ 00184118 (*លោកប្រធានឲ្យគាត់ហៅលេខ ERN ឡើងវិញ ខ្ញុំអ្នកបកប្រែតាមមិនទាន់*) ហើយនៅក្នុង---

**ប្រធានអង្គជំនុំ៖**

និយាយពីលេខ ERN ឡើងវិញដើម្បីមានការបកប្រែទាន់ហើយប្រតិចារឹក អាចកត់ត្រាបាន ។ ហើយសូមនិយាយយឺតជាងនេះបន្តិច ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ នៅក្នុងសំណុំឯកសារនេះគឺច្បាប់ចម្លងនៃកំណត់សរសេរផ្ទាល់ដៃ នៅក្នុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ក្នុងស-២១។

**ប្រធានអង្គជំនុំ៖**

សូមបង្ហាញលេខ ERN ម្តងទៀត ពីព្រោះអ្នកបកប្រែបកអត់បានទេ ហើយអត់អាចនាំឱ្យមានការកត់ប្រតិចារឹកបានទេ លេខ ERN ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ ហើយERN ជាភាសាខ្មែរ 00077661 រហូតដល់ 00078056 អត្ថបទបកអង់គ្លេសជាមួយផ្នែកហ្នឹងគឺ ERN 00184596 រហូតទៅដល់ 00184618 ក្នុងអត្ថបទភាសាអង់គ្លេសនោះគឺ 00242259 រហូតដល់ 00242263។

**សួរដោយលោក វីលៀម ស្មីត៖**

លោក ម៉ម ណៃ តើលោកឯកភាពទេ ច្បាប់ចម្លងនៃ កំណត់ផ្ទាល់ដៃរបស់លោក ដែលលោកបានរៀបចំនៅក្នុងដំណាក់កាល ស-២១ នៅពេលនោះ?

[១០:០៤:១៣]

**ឆ៖** សូមជម្រាបលោក! ឯកសារដែលថតចម្លងនេះគឺអក្សរខ្ញុំ ។ ខ្ញុំមិនមែនជាអ្នករៀបរៀងទេ ខ្ញុំគ្រាន់តែជាអ្នកសរសេរតាមបទឧទ្ទេសនាមរបស់ មិត្តឌុច តែប៉ុណ្ណោះ ។

**ស៖** នៅក្នុងឯកសារនេះ យើងបានពិនិត្យមើល គឺថាយើងឃើញមានប្រហែលជាកាលបរិច្ឆេទសែសិបប្រាំ ក្នុងដំណាក់កាលនោះ ។ កាលណាមានកាលបរិច្ឆេទថ្មី គឺមានការប្រជុំថ្មី បទឧទ្ទេសនាមថ្មី ដែល លោកកត់ត្រាអំពីកិច្ចប្រជុំមួយៗ។ កាលណាមានកាលបរិច្ឆេទថ្មី គឺជាកិច្ចប្រជុំថ្មី ខ្លឹមសារថ្មី តើមែនឬទេ?

**ឆ៖** សូមជម្រាបលោកបើកាលបរិច្ឆេទវាខុសគ្នា អាហ្នឹងប្រាកដជារឿងក៏ខុសគ្នាដែរ ។

**ស៖** លោកប្រធានខ្ញុំមានប្រាំមីនុតទៀត ។ លោកម៉ម ណៃ នៅក្នុងឯកសារនោះគឺថាមានសេចក្តីយោងជាច្រើនទាក់ទងទៅនឹងការប្រើប្រាស់ទារុណកម្មនៅស-២១ ។ ពីម្សិលមិញនេះ នៅចំពោះមុខតុលាការចៅក្រម ធូ មណី បានសួរលោកថាតើ ឌុច បានណែនាំលោកឲ្យសួរចម្លើយដោយមានធ្វើទារុណកម្មដែរឬទេ? លោកបានឆ្លើយថា នៅពេលដែលខ្ញុំសួរអ្នកទោសខ្មែរ ឬវៀតណាម ខ្ញុំមិនទទួលការណែនាំអំពីវិធីសាស្ត្រធ្វើទារុណកម្ម ឬក៏សួរចម្លើយនោះទេ ។ ថាតើអ្នកផ្សេងទៀតដែល ឌុច បានបង្រៀននោះ? ហើយលោកឆ្លើយថា ខ្ញុំប្រុងប្រយ័ត្នតែការងាររបស់ខ្លួនរីឯការងាររបស់គេ គឺគេជា អ្នកដឹង ។ តាមដែលខ្ញុំដឹងគឺអ៊ីចឹង ។ លោក ម៉ម ណៃ លោកបានបញ្ជាក់ថា លោកមិនបានដឹងអំពីទារុណ-កម្មនៅ ស-២១ ទេ ហើយឯកសារនេះដែលបានផ្តល់លេខយោងទៅដល់អង្គជំនុំជម្រះពេល ក្រោយគឺថាមានខ្លឹមសារយោងជាច្រើនទាក់ទងទៅនឹងអំពើទារុណកម្មនៅស-២១ ។ អ៊ីចឹង តាមពិត លោកបានដឹងអំពីការធ្វើទារុណកម្មហ្នឹងនៅស-២១។ ដោយហេតុថា លោកនិងអ្នកផ្សេងៗទៀតទទួល ការណែនាំឲ្យអនុវត្តការសួរចម្លើយ និងទារុណកម្មនោះ ។ តើលោកឯកភាពជាមួយហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញា ។ ខទីមួយចំពោះខ្លួនខ្ញុំផ្ទាល់គឺថា គាត់មិនដែលណែនាំពីរឿងធ្វើទារុណកម្មទេ ។ ក៏ប៉ុន្តែ នៅក្នុងខទីពីរ នៅក្នុងចំណារសៀវភៅដែលកត់ទុំង គឺជាការប្រជុំដកពិសោធន៍ ។ ខ្ញុំកត់តាមគាត់ឧទ្ទេសនាម ហើយនិងការពាក់ព័ន្ធរបស់អ្នកសួរចម្លើយដទៃទៀត ។ តែត្រង់គេធ្វើទារុណកម្មយ៉ាងម៉េចអាហ្នឹងខ្ញុំអត់ដឹងដែរ ។

[១០:០៨:០៣]

**ស៖** លោក ម៉ម ណៃ តើលោកកាត់បន្ថយតួនាទីរបស់លោកនៅក្នុងស-២១ ទៅតាមអ្វីដែលលោកបានបញ្ជាក់ ដែលថាតាមដែលលោកដឹងនៅស-២១ សកម្មភាពរបស់អ្នកផ្សេងទៀតនៅស-២១ លោកចង់ដកខ្លួនចេញអំពីបទឧក្រិដ្ឋដ៏អាក្រក់នៅទីនោះ ឬយ៉ាងដូចម្តេច? តើលោកបានព្យាយាមដើម្បីលាក់កំបាំងដើម្បីដកខ្លួនឲ្យនៅឆ្ងាយចេញពីបទឧក្រិដ្ឋដែលកើតឡើងនៅស-២១ នោះឬ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំគ្មានគំនិតបែបនេះទេ ។ គឺខ្ញុំនិយាយតាមដែលសកម្មភាពដែលខ្ញុំធ្វើប៉ុណ្ណឹង។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះសូមអញ្ជើញលោកមេធាវី ហ្វ្រេងស្វ័រ រូ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមគោរពលោកប្រធាន! ខ្ញុំមានសេចក្តីសង្កេតមួយមកពីមេធាវីការពារ ដូចថានៅក្នុងដំណាក់កាលនីតិវិធីនេះលោក ម៉ម ណៃ គឺជាសាក្សីដែលបានកោះអញ្ជើញដោយសហព្រះរាជអាជ្ញា ហើយនៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះសូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សូមជម្រាបថាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមមានពេលវេលាក្នុងការសួរទៅ ដេញដោលទៅសាក្សីរូបនេះ មួយក្រុមម្ភៃនាទី ។ សូមអញ្ជើញ ។

**លោកស្រី ស៊ីលយ៉ីស្ទួត ហ្សីនស្តី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំចង់ជម្រាបអង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានមានការឯកភាពគ្នា ក្រុមទីបួននឹងចាប់ផ្តើមបន្ទាប់មកក្រុមផ្សេងៗ ក្រុមបី ក្រុមពីរ ហើយនិងក្រុមមួយ ជាអ្នកចែករំលែកពេលវេលាដែលសេសសល់ពីក្រុមបួននេះ ។ អ៊ីចឹង ខ្ញុំផ្តល់វេទិកានេះទៅឲ្យក្រុមបួនដើម្បីចាប់ផ្តើមមុន។ សូមអរគុណ ។

[១០:១០:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងក្រុមបួន។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសូមគោរពលោកប្រធានអង្គជំនុំជម្រះ លោកស្រី លោកចៅក្រម និងអង្គសវនាការជាទីគោរព ។ ខ្ញុំបាទសូមជម្រាបលោកប្រធានថា ដោយសារក្រុមទីបួនក៏មានពេលវេលាម្ភៃនាទីផងដែរនោះ ខ្ញុំបាទសូមអនុញ្ញាតប្តូររួមបញ្ចូលពីរក្រុម គឺក្រុមពីរនិងក្រុមបួនបញ្ចូលគ្នា ។ មានន័យថា បើសិនជាខ្ញុំបាទសួរមានពេលតិចខ្ញុំប្តូរចូលក្នុងក្រុមពីរវិញបាទ ។ សូមអរគុណ ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោក ម៉ម ណៃ បើសិនជាលោកស្តាប់សំណួរខ្ញុំមិនច្បាស់សូមលោកមានប្រសាសន៍មក

វិញថាមិនច្បាស់សួរម្តងទៀត ។ អ៊ីចឹង សំណួរខ្ញុំសួរលោកទាក់ទងជាមួយនឹងសៀវភៅកំណត់ត្រាប្រចាំថ្ងៃដែលលោកមានប្រសាសន៍ឆ្លើយជាមួយលោកសហព្រះរាជអាជ្ញាអម្បាញ់មិញ ។ អម្បាញ់មិញលោកបានជម្រាបអង្គសវនាការថា សៀវភៅកំណត់ត្រាមាន៣៩៦ ទំព័រនេះ លោកមិនមែនជាអ្នកតាក់តែងឬក៏មានគំនិតពីលោកទេ គឺលោកធ្វើ លោកកត់ទៅតាមការឧទ្ទេសនាមរបស់មិត្ត ឌុច គឺលោក កាំង ហ្គេកអ៊ាវ បើខ្ញុំស្តាប់មិនច្រឡំទេ គឺអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកគឺអ៊ីចឹង ។

**ស៖** បាទសូមអរគុណ ។ សំណួរទីពីរ អម្បាញ់មិញលោកបានជម្រាបអង្គសវនាការលោកប្រធានថា លោកបានចូលទៅក្នុងមន្ទីរស-២១ ដែលលោកសហព្រះរាជអាជ្ញាគាត់ជម្រាបថា សព្វថ្ងៃហៅថាមន្ទីរគុកទួលស្លែងនោះ អម្បាញ់មិញខ្ញុំបានឮថាលោកបានចូលតែម្តងទេ ដោយមើលទៅលើរូបផែនទីបង្ហាញ ហើយលោកថា ទៅជួបកូនសិស្សរបស់លោក អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ សំណួរបន្តកន្លែងនេះខ្ញុំចង់សួរលោកថា ដោយសារពេលវេលាវាវែងមានន័យថាចូលសាមសិបឆ្នាំមកហើយ លោកថាពេលខ្លះលោកចាំ ពេលខ្លះលោកមិនចាំ។ ដូច្នេះ សំណួរខ្ញុំខ្ញុំសួរថា ក្រៅពីកូនសិស្សរបស់លោកម្នាក់នេះ ចុះគ្រូរបស់លោកដែលលោកមានប្រសាសន៍អម្បាញ់មិញនិយាយអំពីឈ្មោះ ចៅ សេង នោះ តើត្រូវបានឃុំ នៅមន្ទីរម-២១ ដែរឬទេ? សុំទោស ស-២១?

[១០:១៣:៥៦]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គឺថាលោកគ្រូខ្ញុំឃុំនៅស-២១ មែន ។ ក៏ប៉ុន្តែ គេឃុំនៅផ្ទៃខាងត្បូងសាលាពញាយ៉ាតហ្នឹង ។

**ស៖** សូមអរគុណ ។ បន្តទៅទៀត ក្នុងនាមលោកជាបុគ្គលិករបស់មន្ទីរស-២១ ផងដែរ ហើយជាហូរហែមកលោក ឌុច តែងតែហៅលោកថាបង ម៉ម ណៃៗ ជានិច្ច ដូច្នេះស្តាប់ទៅហាក់ដូចជាលោកហ្នឹងមានកម្រិតខ្ពស់ជាងគាត់ នេះគ្រាន់តែជាការស្តាប់ ។ ខ្ញុំសួរលោកថា តើរាល់ការងារដែលលោកកត់ត្រាចូលទៅក្នុងសៀវភៅកំណត់ត្រារបស់លោកនោះមានតែលោក ឌុច មួយឬមានអ្នកដទៃដែរឬទេ ដែលឲ្យលោកកត់ត្រាទុក?

**ឆ៖** តាមខ្ញុំមើលឯកសារពីល្ងាចមិញឃើញថា នៅដើមដំបូងគឺមានការឧទ្ទេសនាមរបស់ ណាត ជាប្រធាន ដល់ក្រោយមកបានមាន មិត្តឌុច ជាអ្នកឧទ្ទេសនាមតទៅទៀត ។

**ស៖** សូមលោកពន្យល់នៅក្នុងអង្គសវនការឲ្យបានច្បាស់ជាសំរាយបន្ថិចមក ។ ថាតើពាក្យថា ឧទ្ទេសនាមមានន័យថា បង្គាប់ ឬយ៉ាងម៉េច បាទ?

**ឆ៖** សុំជម្រាបលោកឧទ្ទេសនាមបានសេចក្តីថា និយាយ និយាយប្រាប់ និយាយពន្យល់ និយាយរឿងរៀនសូត្រ យកឯកសាររៀនសូត្រមកអានឲ្យស្តាប់ទៅ គឺអាហ្នឹងគេហៅ ឧទ្ទេសនាមហើយ ។

**ស៖** សូមអរគុណ ។ ដូច្នេះ មានន័យថា ការកត់ត្រានេះ គឺលោកកត់តាមពាក្យនិយាយរបស់មេ ដែលថ្លែងនៅក្នុងប្រជុំ ឬការរៀនសូត្រ តើអ៊ីចឹងមែនទេ?

**ឆ៖** វាពិតជាអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ សំណួរបន្តទៅទៀត ក្រោយពេលឈ្មោះ ណាត ជាប្រធានមន្ទីរស-២១ ចាកចេញទៅ នៅក្នុងឯកសារគឺមានឈ្មោះលោកនៅក្នុងជាបុគ្គលិករបស់មន្ទីរ ស-២១ ដដែល ។ តើលោកធ្លាប់បានទៅចូលរួមប្រជុំ ឬធ្លាប់ទៅជួបជាមួយលោក សុន សេន ជាមេរបស់លោក ឌុច ដែរ ឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! មានពេលមួយនោះប្រជុំជីវភាពបក្ស ហើយដូចជាខ្ញុំបានជម្រាបមុននោះក៏មិនដឹង គឺប្រជុំជីវភាពបក្ស គឺនៅខាងក្រោមមន្ទីរស-២១ នៅខាងត្បូងវ៉ារទេះភ្លើង មិនទាន់ដឹងកន្លែងណាមួយទេ នៅពេលនោះខ្ញុំថា នែ៎បង សុន សេន គាត់បានចូលរួមធ្វើជាប្រធានអង្គប្រជុំ ប្រជុំនោះប្រជុំជីវភាព សូមជម្រាបលោកឲ្យច្បាស់ ។

**ស៖** សូមអរគុណ ។ ខ្ញុំសួរលោកជាចុងក្រោយ ដោយសារឯកសារនេះទាក់ទងជាមួយនឹងឯកសារ ហ្នឹងដែលមានការកត់ត្រាប្រចាំថ្ងៃមានតែមួយទេ នៅក្នុងចំណោមបុគ្គលិកស-២១ គឺលោក ម៉ម ណៃ ហៅ ចាន់ ដែលកត់ត្រាទុក ។ ឯកសារដែលលោកកត់ត្រានេះ តើលោក សុន សេន ដែលយកទៅត្រួតពិនិត្យមើលឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺគាត់មិនដែលទាមទារ ឬប៉ះពាល់សៀវភៅនែ៎ ខ្ញុំរៀនសូត្រនេះទេ ។

**ស៖** សូមសួរមួយទៀត ។ តើលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ឬមិត្ត និងមិត្តណាត ឬក៏មិត្ត ហ៊ី ដែលជាមនុស្សនៅក្នុងស-២១ ដែលយកសៀវភៅលោកនេះទៅត្រួតពិនិត្យ ឬបង្គាប់បញ្ជាឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! អ្នកទាំងបីនេះក៏មិនដែលយកសៀវភៅហ្នឹងទៅត្រួត ទៅពិនិត្យអីដែរ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន សូមបន្តពេលវេលាខ្ញុំបាទទៅក្រុមទីពីរខាង ស៊ីលឃិ បន្តទៀតបាទ ខ្ញុំបាទអស់សំណួរត្រឹមនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមជម្រាបសួរលោក ម៉ម ណៃ លោកប្រធានជាទីគោរព លោកចៅក្រមជាទីគោរព ហើយខ្ញុំចង់សួរសំណួរទៅលោក ម៉ម ណៃ ។

**ស៖** នៅពេលដែលលោកម-១៣ ថាលក្ខខណ្ឌនៃការឃុំខ្លួនរបស់អ្នកទោសនៅក្នុងរណ្ដៅនោះថាតើ ហើយស្រដៀងគ្នាទៅនឹងលក្ខខណ្ឌដែលគេឃុំខ្លួនរបស់លោកនៅក្នុងសង្គមចាស់ដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី! កាលៈទេសៈវាខុសគ្នា ដូច្នេះការឃុំអ្នកទោសក៏វាខុសគ្នាដែរ។ កាលៈទេសៈសម័យគេចាប់ខ្ញុំ គឺជាកាលៈទេសៈសន្តិភាពគ្មានចំបាំងរាំងជល់ គ្មានការទម្លាក់គ្រាប់បែកពីអាមេរិកាំងទេ ។ ក៏ប៉ុន្តែ ពេលដែលឃុំអ្នកជាប់ចោទនៅក្នុងសម័យបដិវត្តន៍ គឺអាមេរិកកាំងវាទម្លាក់គ្រាប់បែកពាសពេញវាលកាល ភូមិកររបស់ប្រជាជន ។ ដូច្នេះ គឺដើម្បីកុំឲ្យមានគ្រោះថ្នាក់ត្រូវតែធ្វើជីករណ្ដៅ ហើយទៅនៅ មិនថាតែអ្នកទោសទេ សូម្បីតែអ្នកដែលជាបុគ្គលិកមន្ទីរក៏នៅក្នុងរណ្ដៅដូចគ្នាដែរ ។

**ស៖** នៅពេលដែលគេឃុំខ្លួនលោកនៅក្នុងសង្គមចាស់នោះ តើលោកដែលនឹកឃើញថា គេនឹងសម្លាប់លោក ឬក៏ថ្ងៃណាមួយគេនឹងដោះលែងលោក តើលោកគិតអ៊ីចឹង ឬយ៉ាងម៉េច?

[១០:២១:៣៦]

**ឆ៖** នៅពេលនោះខ្ញុំអត់មានបានគិតអីទេ ពីព្រោះថាកាលណាគេចាប់ហើយ គេធ្វើអីខ្ញុំធ្វើទៅ ខ្ញុំគិតអ៊ីចឹង ហើយព្រោះសម័យនោះក៏មានដូចជាពួកខ្មែរសេរីគេយកទៅបាញ់ចោលដែរ ។ ដូច្នេះ ខ្ញុំអត់មាន គិតថាពីរឿងរស់ ឬពីរឿងស្លាប់ទេ ស្រេចតែនឹងគេ គេធ្វើអីគេធ្វើទៅ ។

**ស៖** លោកជឿជាក់ថា អ្នកទោសទាំងអស់នៅម-១៣ ត្រូវចាត់ទុកថា អាចនឹងមានពេលណាមួយគេដោះលែងដោយមានសេរីភាពរស់រានទេ?

**ឆ៖** កាលខ្ញុំនៅម-១៣ អង្កាល់ដំបូងឡើយខ្ញុំភ្លេចទៅ ខ្ញុំមិនដឹងថាមន្ទីរអី មន្ទីរសន្តិសុខ ប៉ុន្តែដល់ឥឡូវនេះ គឺថាលើកឡើងថាម-១៣ ខ្ញុំនឹកឃើញមកវិញ គឺថាខ្ញុំ កាលខ្ញុំរស់នៅនោះ ខ្ញុំកត់សម្គាល់ឃើញថាមានពីរនាក់ដែលត្រូវដោះលែង អាហ្នឹងឃើញនឹងភ្នែកខ្ញុំ ហើយក្រៅពីនោះទៀតខ្ញុំមិនដឹងទេ ។

**ស៖** លោក ម៉ម ណៃ អ្នកទោសទាំងអស់នៅម-១៣ ជាខ្មាំង តើពួកគេជាអាមេរិកាំង ពួកគេជាវៀតណាម ឬក៏ពួកគេជានរណា?

**ឆ៖** នៅម-១៣ ជម្រាបប្រសាសន៍លោកស្រី គឺថាគ្មានជនជាតិបរទេសទេ មានតែខ្មែរ ។

**ស៖** បន្តទៅទៀតលោកបាននិយាយថា ប្រពន្ធរបស់លោកបានទៅជាមួយលោក ហើយនិងកូនក៏បានទៅជួបលោកនៅទីនោះដែរ ហើយគាត់ប្រពន្ធរបស់លោកហ្នឹងទទួលបន្ទុកខាងដាំស្លនៅស-២១ ហើយលោកមានផ្ទះមួយមិនមែនជាកន្លែងធ្វើការទេ ហើយលោករស់នៅផ្ទះហ្នឹងជាមួយប្រពន្ធ និងកូនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! មកនៅភ្នំពេញនៅស-២១ ក្រោយពីខ្ញុំសុំ មិត្តឌុច យកប្រពន្ធខ្ញុំមកពីអគ្គីសនីពេទ្យលោកសង្ឃ គឺនៅផ្ទះមួយ ។ យើងរស់នៅជាមួយគ្នា នៅពេលយប់ដែលយើងមិនបានធ្វើការ នៅពេលថ្ងៃយើងទៅធ្វើការរៀងខ្លួនទៅ ។

**ស៖** នៅក្នុងពេលល្ងាចប្រពន្ធរបស់លោកដែលក៏ធ្វើការជាចុងភៅនៅស-២១ នោះ តើលោកធ្លាប់និយាយទៅគាត់ទេថា តើទីកន្លែងរបស់លោកនៅកន្លែងណា ហើយសួរគាត់ធ្វើអ្វី ហើយនៅស-២១ តើដែលថា លោកអាចដឹងពីការងារគ្នាទៅវិញទៅមកដែរឬទេ នៅពេលនោះ?

**ឆ៖** នៅស-២១ គ្រួសារខ្ញុំគេដឹងតែការងារគេ ហើយខ្ញុំដឹងជាតែការងារខ្ញុំ ខ្ញុំមិនដែលនិយាយពីការងារខ្ញុំប្រាប់ប្រពន្ធខ្ញុំ ហើយប្រពន្ធខ្ញុំក៏គេមិននិយាយអីពីការងារគេប្រាប់ខ្ញុំដែរ ។

[១០:២៦:២២]

**ស៖** លោកបាននិយាយថា លោកធ្វើគធ្វើថ្លង់មិន ហើយព្យាយាមមិនចង់ដឹងអ្វីៗទាំងអស់ ហេតុអ្វីបានជាចាំបាច់ត្រូវធ្វើបែបនោះ ថាមិនចង់ដឹងចង់ឮអ្វីនោះ?

**ឆ៖** ការដែលធ្វើគធ្វើថ្លង់មិនចង់ដឹងអ្វី គឺវាសមស្របនឹងលាក់ការណ៍របស់បក្ស គឺថាការងារគេៗដឹង ការងារយើងៗដឹង ហើយខ្ញុំនិយាយថា ធ្វើគធ្វើថ្លង់អាហ្នឹងតាមពាក្យបុរុមបុរាណខ្មែរយើង។

**ស៖** លោកក៏បាននិយាយប្រាប់យើងដែរថា លោកមានការភ័យខ្លាច ក្នុងការសួរសំណួរទៅ ឌុច តើលោកខ្លាចអ្វីដែរពេលនោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកស្រី ខ្ញុំមិនភ័យខ្លាចនឹងការសួរសំណួរទៅមិត្ត ឌុច ទេក៏ប៉ុន្តែនៅពេលខ្មាំងឆ្លើយថាមានរូបខ្ញុំទៅទាក់ទង ទៅលេងផ្ទះពួកវា ហើយមិត្ត ឌុច ប្រាប់ថាខ្មាំងឆ្លើយដាក់ ហើយគាត់ក៏ដក ភារកិច្ចខ្ញុំឲ្យឈប់សួរចម្លើយ ខ្ញុំមានការព្រួយបារម្ភ ខ្ញុំយល់ថា ប្រហែលជាគាត់លែងទុកចិត្តខ្ញុំ ខ្ញុំព្រួយបារម្ភខ្លាចគាត់រកលេសចាប់ខ្ញុំតែប៉ុណ្ណឹង ។

**ស៖** ប៉ុន្តែ លោក ម៉ម ណៃ ហេតុអ្វីបានលោកខ្លាចគេចាប់ខ្លួន ដោយហេតុថាលោកក៏ជា ជាជនបដិវត្តន៍ដែលគេជឿជាក់ ហើយលោកធ្វើការដោយមានការពលិកម្មច្រើនបែបនេះ ហេតុអ្វីបានមនុស្សគេមិនទុកចិត្តលោក ហើយហេតុអ្វីបានគេអាចនឹងចាប់ខ្លួនលោកកើត? ប្រសិនបើៗដឹងច្បាស់ហើយក្នុងចំណោមអ្នកទោសដែលលោកបានសួរចម្លើយនោះ គឺថាអ្នកខ្លះអាចនឹងមានស្ថិតនៅក្នុងស្ថានភាពដូចនឹងលោកដែរ អាចនឹងការឃុំខ្លួនរបស់គេ ថាវាមានហេតុផលសមស្របនឹងចាប់ខ្លួននិងឃុំខ្លួន?

**ឆ៖** ខ្ញុំព្រួយបារម្ភព្រោះថា គាត់ប្រាប់ខ្ញុំថា ខ្មាំងឆ្លើយដាក់ ហើយជាពិសេសនៅសម័យនោះតែកាលណាមានគេឆ្លើយដាក់ គឺថាវាត្រូវតែមានរឿងហើយ ។ អាហ្នឹងបានជាខ្ញុំមានការព្រួយបារម្ភ ។

**ស៖** ប៉ុន្តែលោក ម៉ម ណៃ តើអ្នកដែលគេឆ្លើយដាក់គេ ឬតើបើគេឆ្លើយដាក់គេ តើវាមានបញ្ហាអី ចំពោះអ្នកផ្សេងនោះ ហេតុអ្វីក៏លោកមានការភ័យខ្លាច កាលណាមានគេឆ្លើយដាក់ហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបលោក! តែកាលណាមានគេឆ្លើយដាក់ គឺយើងត្រូវតែភ័យខ្លាច បើយើងក្រៅពីគេឆ្លើយដាក់ហើយ យើងធ្វើអីខុស អាហ្នឹងប្រាកដជាមានរឿងត្រូវចាប់ខ្លួនហើយ ។

**ស៖** ហើយប្រសិនជនម្នាក់ត្រូវបានគេចាប់ខ្លួន តើមានរឿងអីកើតចំពោះអ្នកហ្នឹង? តើលោកមិនមានគំនិតអ្វីទាល់តែសោះ ដែលថាគ្រូរបស់លោកដែលលោកបានជួបហើយនោះ តើយ៉ាងដូចម្តេចដែរ ក្រោយមកនោះ?

**ឆ៖** ចំពោះគ្រូរបស់ខ្ញុំ ខ្ញុំភ្លាប់មិនបានពីវាសនាគាត់យ៉ាងម៉េចទេ ។ ក៏ប៉ុន្តែខ្ញុំ មិត្តឌុច ប្រគល់ភារកិច្ចឲ្យខ្ញុំទៅសួរគាត់ ខ្ញុំក៏ទៅសួរ គ្រាន់តែហុចក្រដាស់ជូនគាត់ទៅ ហើយជម្រាបគាត់ថា លោកគ្រូធ្វើអីខុសអីយ៉ាងម៉េច អាហ្នឹងលោកគ្រូសរសេរអ៊ីចឹងទៅ ។ ហើយក្រោយសរសេរមកចប់មក ខ្ញុំក៏អានចំណារនុំង ហើយក៏ជូនមក មិត្តឌុច ទៅ ។

**ស៖** លោក ម៉ម ណៃ ហេតុអ្វីបានជាលោកខ្លួនឯងមានការភ័យខ្លាចណាស់ ទោះបីជាវាពិតក៏ដោយថា បុគ្គលដែលគេចាប់ខ្លួនគេផ្តល់ក្រដាសមួយសន្លឹកឲ្យសារភាពទៅហើយនោះ លោកជាអ្នកបដិ-វត្តន៍ ហើយលោកស្ម័គ្រចិត្ត និងប្តេជ្ញា ហើយលោកធ្លាប់ជាប់គុកពីរឆ្នាំទៀត ។ ហេតុអ្វីបានជាលោក

ខ្លាចទៅលើចម្លើយសារភាពទាំងអស់នោះ?

**ឆ៖** សូមលោកស្រីលើកសំណួរម្ដងទៀត ។

**ស៖** ក្នុងករណីដែលលោកគ្រូរបស់លោក ប្រសិនបើគេចាប់ខ្លួនហើយនោះ បានន័យថា គេនឹងកោះមកសួរចម្លើយ ហើយលោកបានសុំឲ្យគេសរសេរចម្លើយសារភាព ហើយវាមិនជាការលំបាកទេលោកឲ្យគេធ្វើដូច្នោះ ។ ដូច្នេះហើយលោកជាអ្នកបដិវត្តន៍ តើលោកមានការភ័យខ្លាចយ៉ាងម៉េចនៅពេលដែលគេផ្ដល់ចម្លើយសារភាពបែបនោះ ក្នុងលក្ខខណ្ឌដែលលោកឲ្យគេសរសេរហើយនោះ?

**ឆ៖** ខ្ញុំនៅតែមិនយល់ពីការសួររបស់លោកស្រី ដូច្នេះ ខ្ញុំមិនឆ្លើយតបទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

[១០:៣៣:៣៦]

**លោក គង់ សំអុន៖**

ខ្ញុំគិតថា ប្រហែលជាមានការភាន់ច្រឡំចំពោះការបកប្រែក៏មិនដឹង អាចថាវាមិនមែនជាការសារភាពទេ ប៉ុន្តែវាជាការចោទប្រកាន់ ។ សូមអាចបញ្ជាក់ ពីព្រោះការចោទប្រកាន់ ខ្ញុំនិយាយថា ការឆ្លើយដាក់ពីបុគ្គលណាម្នាក់ មកចំពោះសាក្សីក្នុងសម័យនោះ ។ ដូច្នេះ បើនិយាយថា ជាការសារភាពអាហ្នឹងវាអត់មានទាក់ទងនឹងសាច់រឿងនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អំមិញ គាត់រក្សាសិទ្ធិមិនឆ្លើយតបហើយ អ៊ីចឹងគឺមេធាវីតសំណួរផ្សេងទៀត ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** សូមអរគុណលោកប្រធាន ។ នៅពេលដែលលោកសួរទាហានវៀតណាម គឺអ្នកជាប់ឃុំវៀតណាម គឺលោកឃើញទាហាន ហើយទាហាននេះ គឺទាក់ទងនឹងព័ត៌មានដែលលោកត្រូវការ បានន័យថា ទាហាននោះចាប់នៅពេលសង្គ្រាម ។ ថាតើប្រសិនបើទាហាននោះមិនផ្ដល់ចម្លើយឲ្យលោកតើលោកនឹងបញ្ឈប់ការសួរចម្លើយនោះ ឬក៏យ៉ាងម៉េច? ឬក៏លោកធ្វើអីទៀត ប្រសិនបើគេមិនព្រមផ្ដល់ចម្លើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! បើសិនជាគេមិនផ្ដល់ចម្លើយ យើងត្រូវតែជជីកសួរគេ ហើយពន្យល់គេ ពីព្រោះនៅសភាពការណ៍សមរភូមិគ្មានអីពិបាកទេ ដូច្នេះ គេមិនអាចលាក់លៀមយើងទេ ។

**ស៖** លោក ម៉ម ណៃ នៅក្នុងកំណត់ត្រារបស់លោកទំព័រទី ៧២ លោកបានសរសេរថា "ខ្លាំងដែលមិនឆ្លើយតប ដែលមិនសារភាព នេះគឺវាទាក់ទងទៅនឹងវិធីសាស្ត្រនៃការសួរចម្លើយ ។ ប្រសិនបើទាហានគាត់បដិសេធមិនឆ្លើយសារភាព លោកមិនព្យាយាមធ្វើយ៉ាងណាឲ្យគាត់ឆ្លើយទេ ឬយ៉ាងម៉េច? ខ្ញុំគិតថាវាប្រហែលជាអាចពាក់ព័ន្ធទៅនឹងការធ្វើការសួរចម្លើយ ដែលមានលក្ខណៈរឹងប៉ឹង និងជំរុញឲ្យឆ្លើយជាងមុន?

**ឆ៖** កាលណាវារឹងរុះអាហ្នឹងគេហៅថា សួរអង្កៀម សួរហើយសួរទៀត ហើយផ្អាកយកទៅឲ្យវាដេកគិតសិនទៅ ។

[១០:៣៦:៥៨]

**ស៖** លោក ម៉ម ណៃ ថាតើការិយាល័យរបស់លោកមិនមែននៅជិតផ្លូវ៣៦០ ដែរឬទេ? គឺជាទីកន្លែងដែលនៅជិតលូទឹកស្អុយដែរឬទេ ដែលលោកថាវាជាបឹងលូទឹកស្អុយនោះ?

**ឆ៖** សូមជម្រាបលោកស្រី! កាលផ្ទះដែលខ្ញុំសួរចម្លើយ គឺនៅនឹងលូទឹកស្អុយហ្នឹង ។

**ស៖** តើលោកមិនបានឃើញរថយន្ត ឬក៏រថយន្តធំៗ ដែលបើកកាត់ផ្ទះរបស់លោក ដោយដឹកមនុស្សទៅស-២១ ដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! អាផ្លូវដែលរថយន្តដឹកនៅឯត្បូងឆ្ងាយឯណោះ មិនដឹងជារំលងប៉ុន្មានម៉ែត្រកង់ផ្ទះ ។ ហើយអាពីក្រោយនេះ មកកន្លែងគុកទួលស្លែងនេះ ក៏នៅឆ្ងាយពីគ្នាដែរ ដូច្នេះ ខ្ញុំមិនដែលឃើញរថយន្តតូច ឬធំណា បើកតាមមុខផ្ទះហ្នឹងទេ ។

**ស៖** មុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ថាតើលោកជឿថាវៀតណាមគាត់ទទួលជោគជ័យក្នុងការក្តោបយកទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** សូមលោកស្រីតាំងសំណួរម្តងទៀត ខ្ញុំស្តាប់មិនទាន់ ។

**ស៖** តើលោកបានគិតទេថា មុនពេលដែលភ្នំពេញត្រូវបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ តើលោកជឿថា កងទ័ពវៀតណាមនោះអាចទទួលជោគជ័យ ហើយធ្វើការវាយប្រហារទៅលើកងទ័ពខ្មែរក្រហមដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក គង់ សំអុន៖**

សូមអរគុណ ។ ខ្ញុំបានស្តាប់សំណួរមួយចំនួន ដែលខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរ ហើយសំណួរនោះច្រើនតែផ្តោតទៅលើការគិត ដែលជាការសន្និដ្ឋានឲ្យសាក្សីធ្វើការសន្និដ្ឋាន ។ បើអ៊ីចឹង បើសិនជាគាត់ធ្វើការសន្និដ្ឋានវាមិនបានជាអង្គហេតុ បើសិនជាការតាំងសំណួររបស់មេធាវីគួរតែសំដៅទៅលើការបង្កើតចំណុចណាទាក់ទងទៅនឹងអង្គហេតុ រួចបង្ហាញពីព្រឹត្តការណ៍ដែលកើតឡើង ។ បើសិនជាឲ្យសាក្សីឆ្លើយគិត អ៊ីចឹងអ្នកណាក៏គិតគំនិតមនុស្សផ្សេងៗគ្នា ហើយចម្លើយហ្នឹងយកមកក៏មិនអាចធ្វើទៅធ្វើជាភស្តុតាង ជាបន្ទាល់អីបានល្អដែរ ។ សូមអរគុណ ។

[១០:៤០:៤៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីជំនួយរបស់សាក្សី ។ ប៉ុន្តែ ខ្ញុំសូមរំឭកលោកមេធាវីថា លោកមេធាវីដែលការិយាល័យគាំពារសាក្សី និងអ្នកជំនាញបានចាត់តាំងលោកមកនេះ គឺក្នុងន័យជំនួយដល់សាក្សី ដើម្បីពិគ្រោះប្រឹក្សាយោបល់នូវសំណួរ ឬក៏ការសុំឲ្យធ្វើនូវសេចក្តីអះអាងណាមួយដែលលោកពិចារណាទៅឃើញថា អាចមានលទ្ធភាពថា បើឆ្លើយ ឬក៏អះអាងតបទៅនឹងសំណួរនោះ វានាំកូនក្តីរបស់លោកមានពិរុទ្ធភាព ។ ចំណែក នីតិវិធីនៃរបៀបសួរយ៉ាងណានោះ មិនមែនជារឿងរបស់លោកទេពីព្រោះសាក្សីរូបនេះ គឺគាត់ចូលមកចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈសាក្សី មិនមែនជាជនជាប់ចោទទេ ។ សូមជ្រាបមិនមែនពាក់ព័ន្ធជាមួយនឹងរឿងផ្សេងទៀតទេ គឺពាក់ព័ន្ធជាមួយនឹងសំណួរ ឬការសុំឲ្យធ្វើការអះអាងណាមួយដែលនាំឲ្យមានពិរុទ្ធភាព ។ បើសង្ស័យថា សំណួរហ្នឹង លទ្ធផលដែលឆ្លើយបើគាត់ឆ្លើយអាចមានបញ្ហា មានពិរុទ្ធភាពលើកខ្លួនគាត់ នោះបានជាតួនាទីរបស់លោកដែលត្រូវប្រឹក្សាយោបល់ ។

សូមអញ្ជើញតទៀត ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមសួរសំណួរចុងក្រោយ ហើយបន្ទាប់មកខ្ញុំនឹងផ្តល់វេទិកាទៅដល់សហសេវិករបស់ខ្ញុំ ។

**ស៖** លោក ម៉ម ណៃ ខ្ញុំសូមសួរសំណួរនេះលក្ខណៈផ្សេងវិញ ។ នៅក្នុងកិច្ចប្រជុំនយោបាយដែលលោកបានជួបប្រជុំនោះ លោកគិតថា វានៅកើតឡើងជុំវិញឆ្នាំ១៩៧៨ ដែរឬទេ? ហើយលោកគិតថានៅពេលនោះ គឺវាមានការលើកឡើងអំពីការដកកម្លាំង ដកទ័ពថយ ដោយសារតែវៀតណាមនោះ

ទ័ពវៀតណាមបានចូលលុកលុយ និងចូលមកវាយប្រហារនៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺនៅពេលនោះ ពួកយើងខ្ញុំគឺអត់ដឹងអីទាំងអស់ អត់ដឹងសភាពការណ៍ថាទ័ពវៀតណាមមកដល់ណាទេ ។ ម្ល៉ោះហើយពួកខ្ញុំនៅជាធម្មតាអ៊ីចឹង ស្រាប់តែឮកាំភ្លើងផ្ទុះបានដឹងថា វៀតណាមចូលដល់ហើយបាននាំគ្នាប្រញាប់ប្រញាល់រត់តទល់ខ្លះ រត់ខ្លះប៉ុណ្ណឹង ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន ។ សហសេវិករបស់ខ្ញុំនៅពេលនេះ នឹងធ្វើការតាំងសំណួរបន្ត ។

**ប្រធានអង្គជំនុំ៖**

ពេលវេលាម្ភៃមីនុតសម្រាប់ក្រុមបីបានអស់ហើយ ។ លើកលែងតែក្រុមផ្សេងទៀត ចែករំលែកម៉ោង បើថាតាមការកំណត់ក្រុម៣ គឺថាអស់ម៉ោងហើយ មិនអនុញ្ញាតឲ្យសួរទៀតទេ ។

ឥឡូវនេះ ដល់ម៉ោងឈប់សម្រាក អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំបីនាទី រហូតដល់ម៉ោងដប់មួយសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោលចំពោះសាក្សីនេះបន្តទៅទៀត ។ មន្ត្រីតុលាការ សម្របសម្រួលរកកន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ។

*[សវនាការសម្រាកពីម៉ោង ១០:៤៥នាទី ដល់ម៉ោង ១១:០៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលស្តាប់សក្ខីកម្ម សាក្សីឈ្មោះ ម៉ម ណៃ ។ ហើយជាបន្តនេះផ្តល់ជូនវេទិកាទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីពីរ ។ សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ អរុណសួស្តីលោក ម៉ម ណៃ ខ្ញុំ ស៊ីលឃី ស្ទួតហ្សីនស្គី ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួន ។ តើលោកចាំទេ តើលោកនឹកឃើញទេ ប្រសិនបើអ្នកទោស--គេចាត់ឲ្យលោកសួរចម្លើយអ្នកទោស ថាតើ ឌុច បញ្ជូនអ្នកទោសនោះទៅឲ្យលោកសួរចម្លើយ បើសិនជាគាត់បញ្ជូនឲ្យលោកសួរចម្លើយមែននោះ តើគាត់បញ្ជូនតាមរយៈណា ដោយរបៀបណា?

**ឆ៖** មុននឹងឆ្លើយនឹងសំណួរលោកស្រី ខ្ញុំសូមអនុញ្ញាតពីលោកប្រធានបញ្ជាក់អំពីការដែលខ្ញុំថា ដែលលោកស្រីម្នាក់សួរថា ដែលខ្ញុំថា មិនឆ្លើយតបនោះ ។ សូមបញ្ជាក់មូលហេតុជូនលោកស្រីនោះឲ្យបានជ្រាប បើលោកអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។

**លោក ម៉ម ណៃ៖**

**ឆ៖** សូមជម្រាបថា មូលហេតុដែលខ្ញុំថាមិនឆ្លើយតបនោះ ពុំមានរឿងហេតុអ្វីទេ ព្រោះតែខ្ញុំមិនយល់សំណួររបស់លោកស្រីតែប៉ុណ្ណោះ ។ នេះសូមជ្រាប ។ ឯបញ្ហាសំណួរលោកស្រីមេធាវីសួរខាងក្រោយនេះ សូមលោកស្រីសួរខ្ញុំម្តងទៀតចុះ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** បើសិនជាលោកចង់ឲ្យខ្ញុំអានសួរសំណួរឡើងវិញ គឺខ្ញុំអាចសួរបាន គឺខ្ញុំនឹងសួរដោយងាយៗថាតើជនជាប់ចោទបានបញ្ជូនអ្នកទោសសួរចម្លើយ-- អ្នកទោសដែលត្រូវសួរចម្លើយមកឲ្យលោកសួរដែរឬទេ?

**ឆ៖** តាមខ្ញុំដឹង គឺថាប្រហែលជាគាត់ប្រាប់មក ពូហ៊ី ឬយ៉ាងណា ខ្ញុំក៏មិនដឹងដែរ ។

[១១:០៧:៣៨]

**ស៖** ខ្ញុំសូមបំភ្លឺ បានន័យថា គាត់មិនបាននិយាយជាមួយលោក ហើយប្រាប់លោកថា គាត់នឹងបញ្ជូនអ្នកទោសនេះ ឬក៏អ្នកទោសនោះឲ្យលោកសួរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គាត់មិនដែលនិយាយទេ ចំពោះអ្នកទោសខ្មែរ ឯយួនគាត់គ្រាន់តែប្រាប់ខ្ញុំថា ឲ្យសួរយួនគេចាប់មកពីសមរភូមិ ។

**ស៖** ថាតើលោកធ្លាប់សួរចម្លើយអ្នកទោសសំខាន់ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលសួរអ្នកទោសជាកម្មាភិបាលសំខាន់នោះទេ ។

**ស៖** តើវាមានលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យយ៉ាងម៉េច ដើម្បីគេចាត់ថ្នាក់ថា អ្នកគុកខ្លះជាកម្មា-ភិបាលសំខាន់ និងអ្នកជាប់គុកខ្លះជាកម្មាភិបាលមិនសំខាន់ ។ តើមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចក្នុងការធ្វើដូច្នោះ?

**ឆ៖** សូមលោកស្រីតាំងសំណួរម្តងទៀត ។

**ស៖** ខ្ញុំចង់ដឹងអំពីលក្ខណៈវិនិច្ឆ័យ ឬក៏លក្ខខណ្ឌដែលគេសម្រេចថា តើអ្នកទោសប្រភេទណាដែលជាអ្នកទោសកម្មាភិបាលសំខាន់ និងអ្នកជាប់ទោសណាដែលជាកម្មាភិបាលមិនសំខាន់?

**ឆ៖** សូមជម្រាបអ្នកស្រី អ្នកទោសដែលសំខាន់ គឺកម្មាភិបាលថ្នាក់ខ្ពស់ ។

**ស៖** បានន័យថា គេចាត់ប្រភេទអ្នកទោសទៅតាមកម្រិតដែលថា ពួកគេជាបញ្ញវន្ត និងមានឋានៈខ្ពស់ អ៊ីចឹងមែនដែរឬទេ?

**ឆ៖** គេមិនបានចាត់ទុកថា ជាបញ្ញវន្ត ឬមិនបញ្ញវន្ត ក៏ប៉ុន្តែឲ្យតែនៅក្នុងអង្គការបដិវត្តន៍មានឋានៈជាកម្មាភិបាលថ្នាក់ខ្ពស់ អាហ្នឹងគេចាត់ទុកជាសំខាន់ហើយ ។ ឧទាហរណ៍ ចាប់តាំងកម្មាភិបាលថ្នាក់ស្រុក ឬតំបន់ឡើងទៅ ។

**ស៖** នៅពេលដែលលោកធ្វើការងារនៅស-២១ តើលោកបានដឹងដែរឬទេ ថាតើលោកស្គាល់ឈ្មោះ ភឹង តុន ដែរឬទេ?

**ឆ៖** លោក ភឹង តុន ខ្ញុំធ្លាប់ស្គាល់ ធ្លាប់ឃើញគាត់ កាលនៅពីសង្គមចាស់ ដល់មកនៅគុក ស-២១ ខ្ញុំភ្លេច មិនដឹងជាក្នុងការសួរចម្លើយឃើញអក្សរខ្ញុំ ក៏ប៉ុន្តែ ខ្ញុំនឹកមិនឃើញទាំងរូបរាងគាត់ផង ខ្ញុំភ្លេចអស់ទៅ ។

[១១:១២:០៨]

**ស៖** ថាតើលោកដឹងអំពីលោកនោះយ៉ាងម៉េច? បានន័យថា តើលោកដឹងថា គាត់ធ្វើអីខ្លះនៅក្នុងសង្គមចាស់?

**ឆ៖** នៅក្នុងសង្គមចាស់ ខ្ញុំដឹងថា នៅពេលគេហៅថា ខ្ញុំនឹករកពាក្យខ្មែរ និងបារាំង មិនឃើញ គឺក្នុងពេលដែលគេប្រជុំសាស្ត្រាចារ្យ ធ្វើជាសន្និសិទ ធ្វើអីហ្នឹង គឺថាមានរូបគាត់ទៅនុំងហើយ គេហៅសន្និសិទគរុកោសល្យនោះ អាហ្នឹងមានរូបគាត់ ។ ហើយនិងបង សុន សេន ហ្នឹង គឺប្រកែកគ្នា ចោទសួរគ្នាពីរឿង នែ៎ គរុកោសល្យ-- ពីរឿងចិត្តសាស្ត្រកុមារ ។

**ស៖** វាត្រឹមត្រូវដែរឬទេ ដែលថាលោកចូលរួមសន្និសិទគរុកោសល្យ ដែលលោក ភឹង តុន នោះមានការជជែកវែកញែកទៅវិញ ទៅមក ជាមួយនិងលោក សុន សេន?

**ឆ៖** វាជាការត្រឹមត្រូវ សូមលោកស្រីជ្រាប ។

**ស៖** តើលោកបានចូលរួមសន្និសិទបែបនោះប៉ុន្មានដងដែរ ដែលពេលនោះមានលោក ភឹង តុន នោះ?

**ឆ៖** តាមខ្ញុំចាំ វាមានតែម្តង អាហ្នឹងតាមខ្ញុំចាំ ។

**ស៖** តើលោកដឹងអំពីតួនាទីរបស់លោក ភឹង តុន ដែរឬទេនៅពេលនោះ?

**ឆ៖** នៅពេលនោះ ខ្ញុំក្តាប់មិនបានទេ ដឹងតែគាត់នែ ដឹងថាជាទូទៅ គាត់ជាសាស្ត្រាចារ្យ ប៉ុន្តែតួនាទីគាត់ថា ជារដ្ឋលេខាធិការក្រសួងអប់រំ ក៏មិនដឹង ឬអីមិនដឹង ខ្ញុំក្តាប់មិនបានទេ ។

[១១:១៥:១៣]

**ស៖** ខ្ញុំសូមស្នើសុំលោកប្រធាន! ឲ្យបង្គាប់ខាងសោតទស្សន៍ បង្ហាញរូបថតនេះនៅលើអេក្រង់ គឺរូបថតរបស់លោក ភឹង តុន ។

**ប្រធានអង្គជំនុំ៖**

លេខ ERN ប៉ុន្មានទៅ?

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអភ័យទោស ខ្ញុំនិយាយខុស គឺខ្ញុំសូមឲ្យដាក់នៅលើម៉ាស៊ីនបញ្ចាំង ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

**ស៖** សំណួរ លោក ម៉ម ណៃ នេះគឺជារូបថតដែលថតនៅទួលស្លែង នៅពេលដែលគាត់នោះចូលទៅទួលស្លែង តើលោកស្គាល់គាត់ដែរឬទេ?

**ឆ៖** បើមើលតាមរូបថតនេះខ្ញុំស្គាល់គាត់ ក៏ប៉ុន្តែ ថាឲ្យខ្ញុំនឹកឃើញពេលនោះ កាលគាត់នៅទួលស្លែងខ្ញុំនឹកមិនឃើញថា រូបរាងគាត់យ៉ាងម៉េចទេ តែបើឃើញរូបថតអ៊ីចឹងខ្ញុំថា ហ្នឹងគឺរូបលោក ភឹង តុន ។

**ស៖** សូមលោកធ្វើការដកយករូបភាពនេះវិញចេញពីម៉ាស៊ីនបញ្ចាំង ។ សំណួរបន្ទាប់របស់ខ្ញុំជូនលោក ម៉ម ណៃ តើលោកចាំទេនៅពេលដែលលោក បន្ទាប់ពីលោកឃើញរូបថតនេះ? ថាតើលោកចាំអំពីស្ថានភាពផ្សេងៗ ដែលគាត់នឹងត្រូវបានសួរចម្លើយដោយលោកដែរឬទេ?

**ឆ៖** សូមជម្រាបលោកស្រី! ខ្ញុំមិនចាំទេ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

លោកប្រធាន សូមលោកប្រធានស្នើសុំឲ្យខាងសោតទស្សន៍ បញ្ចាំងឯកសារដែលសហព្រះរាជអាជ្ញាមានហើយ គឺមានលេខ ERN លេខ 00188839 រហូតដល់លេខ 00188843 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ សូមបញ្ចាំងនូវឯកសារដែលមានលេខ ERN ដូចមេធាវី ស្ទូតហ្សឺនស្តី បានលើកឡើងអំមិញនេះ នៅលើអេក្រង់ទូរទស្សន៍ចាប់ពី 00188839 ទៅ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សឺនស្តី៖**

ខ្ញុំក៏សូមផ្តល់ទៅដល់ការសង្ខេបទៅលើឯកសារនេះ ដែលខ្ញុំទទួលបានពីការបកប្រែជាភាសាអង់គ្លេស គឺមានលេខ ERN 00239011 រហូតដល់លេខ 00239012 ហើយនៅក្នុងភាសាបារាំង គឺលេខ 00188844 រហូតទៅសល់ 00188846 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍ សូមដាក់បង្ហាញនូវឯកសារដែលមានលេខ ERN ជាភាសាខ្មែរ 00188839 រហូតដល់ 00188843 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

[១១:២១:២០]

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សឺនស្តី៖**

**ស៖** សំណួររបស់ខ្ញុំជូនលោក ម៉ម ណៃ គឺយើងមើលនៅទំព័រដំបូងនេះ ។ ខ្ញុំផ្តល់ជូបឯកសារជាក្រដាសលោកផងដែរ ដើម្បីឲ្យលោកមានឯកសារនេះពិនិត្យមើល ។

លោក ម៉ម ណៃ តើលោកអាចពិនិត្យមើលទំព័រទី១ សុំឲ្យលោកធ្វើការពិនិត្យទំព័រទី១ ដែលមានក្រដាសតូចមួយនៅលើនុំង ។ ខ្ញុំចង់សួរថា ថាតើនេះជាការសរសេរ និងសំណេររបស់លោកដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី ចម្លើយលោក ភឹង តុន គឺខ្ញុំសរសេរអក្សរខ្ញុំ ។

**ស៖** ប្រហែលជាមានការយល់ច្រឡំ ខ្ញុំសូមឲ្យលោកមើលទៅលើទំព័រដំបូងតែប៉ុណ្ណោះ មិនមែនមើលទៅលើឯកសារចម្លើយសារភាពទេ គឺសុំឲ្យលោកមើលក្រដាសតូចមួយ ដែលនៅលើទំព័រទី១ គឺមានលេខ P376 ហើយនៅក្នុងនោះគឺមានអក្សរខ្មែរ ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថាលោកបានសរសេរអក្សរនេះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! មិនមែនអក្សរខ្ញុំទេ ។

**ស៖** តើលោកដឹងទេ អ្នកណាគេជាអ្នកសរសេរអក្សរនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំអត់ដឹងទេ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

ដូច្នេះ សូមអនុញ្ញាតឲ្យខាងសោតទស្សន៍ ធ្វើការបង្ហិលចុះទៅដល់ឯកសារហ្នឹង នៅចុងក្រោយ ហើយសុំឲ្យក្រឡាបញ្ជីអាននូវវាក្យខណ្ឌចុងក្រោយ ដែលចាប់ផ្ដើមភាសាអង់គ្លេសថា តាមរយៈការបកប្រែ តាមរយៈការសួរចម្លើយ ។ សូមឲ្យធ្វើការអានជាភាសាខ្មែរ ។

**ប្រធានអង្គជំនុំ៖**

ដូចជារកតាមរយៈការសួរចម្លើយហ្នឹងមិនឃើញទេ នៅកន្លែងណាទៅ? បើនៅពាក្យនេះគឺមានតែពាក្យធាតុពិតតាមអ្នកឆ្លើយ ។ ហ្នឹងបានមាន ។ ត្រឹមហ្នឹង ឬក៏យ៉ាងម៉េច?

[១១:២៤:៥៧]

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

ហ្នឹងហើយ នេះជាចំណុចដែលខ្ញុំចង់ឲ្យអាន ដែលខ្ញុំចង់ឲ្យអានលេខមួយ រហូតទៅដល់លេខប្រាំ ហើយអ្វីដែលលោកប្រធានបានលើកឡើងគ្រាន់តែចំណងជើងដែលគេសរសេរបញ្ជាក់នៅលើហ្នឹង។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី សែ កុលវុឌ្ឍី អានចាប់ពីបន្ទាត់ទីប្រាំមួយគឺ "ធាតុពិតតាមអ្នកឆ្លើយ" រហូតមកដល់ក្រោម។

**លោកស្រី សែ កុលវុឌ្ឍី៖**

ធាតុពិតតាមអ្នកឆ្លើយថា កុម្មុយនីស្ត ពីព្រោះ៖

១) ស្រឡាញ់យុត្តិធម៌ក្នុងសង្គម ។

២) ស្រឡាញ់សមភាពសុភមង្គលទាំងអស់គ្នា ។

៣) ស្រឡាញ់ចម្រើនល្អតលាស់ ។

៤) ស្រឡាញ់ការពារមាតុភូមិទឹកដីខ្មែរ ។

៥) ស្រឡាញ់កុម្មុយនីស្តរបៀបខ្មែរ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

**ស៖** លោក ម៉ម ណៃ តើនេះជាការសន្និដ្ឋានរបស់លោក ទៅលើចម្លើយសារភាពនេះលើចម្លើយសារភាពរបស់លោក ភឹង តុន ដែរឬទេ?

**ឆ៖** នេះជា-- សូមជម្រាបលោកស្រី នេះជាការសន្និដ្ឋានរបស់ខ្ញុំ ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? ថាតើនឹងមានអ្វីកើតឡើង តាមរយៈការសន្និដ្ឋានបែបនេះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី ខ្ញុំមិនអាចសន្និដ្ឋានថាយ៉ាងម៉េចទេ គឺថាចំពោះវាសនារបស់លោក ភឹង តុន តែខ្ញុំធ្វើសេចក្ដីសន្និដ្ឋាននេះ តាមចម្លើយរបស់គាត់តែប៉ុណ្ណោះ ។

**ស៖** ថាតើការសម្រេចធ្វើដូច្នេះ គឺអនុវត្តទៅតាមគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះក៏ខ្ញុំមិនយល់ដែរ ក៏ប៉ុន្តែខ្ញុំដឹងថា ការពិតយ៉ាងម៉េចខ្ញុំសរសេរអ៊ីចឹង ខ្ញុំវិភាគអ៊ីចឹង ។

[១១:២៨:១០]

**ស៖** ថាតើការសម្រេចនេះ គឺនាំឲ្យដល់ចំណុចចុងក្រោយដែលសន្និដ្ឋានថា គាត់ហ្នឹងគឺជាខ្មាំងប្រឆាំងបដិវត្តន៍ដែរឬទេ?

**ឆ៖** តាមសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ គឺថាវាដូចការដែលខ្ញុំសរសេរក្នុងចម្លើយអ៊ីចឹង ។

**ស៖** លោក ម៉ម ណៃ ប្រហែលជាលោកចង់និយាយថា លោកដឹងនៅទីនេះគឺ យើងមានប្រពន្ធនិងកូនស្រីរបស់លោក ភឹង តុន ដែលគាត់បានដឹងអំពីជោគវាសនា គាត់ចង់ដឹងអំពីជោគវាសនារបស់គាត់នោះ ។ ដូច្នេះហើយ គឺវាសំខាន់ណាស់ និងមានសារប្រយោជន៍ណាស់ ប្រសិនបើលោកជួយចូលរួមចំណែករៀបរាប់អំពីជោគវាសនារបស់គាត់ទាក់ទងទៅនឹងលោក ភឹង តុន ។ ប្រសិនបើលោកអាចធ្វើការផ្ដល់អត្ថាធិប្បាយបន្ថែម ឬក៏ផ្ដល់ជាចម្លើយបន្ថែមចំពោះអ្វីដែលខ្ញុំសួរលោកនោះ គឺជាការល្អណាស់ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! ខ្ញុំចង់ផ្ដល់ព័ត៌មានបន្ថែមណាស់ ក៏ប៉ុន្តែភារកិច្ចខ្ញុំដឹងត្រឹមប៉ុណ្ណឹង ខ្ញុំអាចជម្រាបតែត្រឹមប៉ុណ្ណឹង ឯហួសពីហ្នឹង ខ្ញុំមិនអាចជម្រាបបានទេ ព្រោះខ្ញុំអត់ដឹង ។

[១១:៣០:០០]

**លោកស្រី ស៊ីលយីស្វត ហ្សីនស្ដី៖**

សូមអរគុណលោក ម៉ម ណៃ ។ ខ្ញុំជូនវេទិកាទៅឲ្យសហសេវិកខ្ញុំ ដែលគាត់នឹងសួរតទៅទៀតពីក្រុមទីបួន ។ សូមអរគុណ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ លោកប្រធាន ។ សូមជម្រាបសួរលោកសាក្សី ។ ខ្ញុំឈ្មោះ អាឡាំង វ៉ែនណឺ ។ ខ្ញុំ និងសហសេវិករបស់ខ្ញុំ ទី ស្រ៊ុនណា តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោក ។

ចំណុចទីមួយ ដែលខ្ញុំចង់សួរនោះ គឺខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយ ខ្ញុំបានចែកជូនឯកសារហ្នឹងទៅខាងសហព្រះរាជអាជ្ញា ទៅខាងមេធាវី ហើយនិងសាក្សី ហើយនិងមេធាវីរបស់ជនជាប់ចោទផងដែរ ។ នេះជាឯកសារនៅក្នុង ERN លេខ 00279916 រហូតទៅដល់ 00279917 ។ ឯកសារទាំងអស់នេះ បានដាក់ដេញដោលផ្លូវតុលាការពីសប្ដាហ៍មុន ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ហើយជនជាប់ចោទបាននិយាយថា ឯកសារហ្នឹងបានរៀបចំដោយ-- ឯកសារខ្ញុំមិននិយាយអំពីខ្លឹមសារនៃឯកសារនេះ ខ្ញុំចង់គ្រាន់តែបង្ហាញឯកសារជូនសាក្សីដើម្បីឲ្យលោកបញ្ជាក់ ថាតើសាក្សីតាមពិតនោះ គាត់បានសរសេរឯកសារហ្នឹងដែរឬទេ?

សូមមន្ត្រីតុលាការផ្ដល់ឯកសារនេះជូនទៅសាក្សី ។

**ប្រធានអង្គជំនុំ៖**

ជូនសាក្សី ម៉ម ណៃ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** សូមលោកសាក្សីមើលឯកសារនេះ ហើយសូមលោកបញ្ជាក់ ឬក៏បដិសេធ ថាតើជាអក្សរផ្ទាល់ដៃរបស់លោកដែរ ឬក៏មិនមែន?

**ឆ៖** អក្សរសរសេរចម្លើយនេះ គឺជាអក្សរខ្ញុំ ក៏ប៉ុន្តែត្រង់កន្លែងសន្និដ្ឋាន គឺមិនមែនអក្សរខ្ញុំទេ ។

**ស៖** សូមអរគុណអរគុណលោកសាក្សី ។ លោកមន្ត្រីតុលាការសូមយកឯកសារនេះពីសាក្សី ។

អ្វីដែលខ្ញុំចង់បន្តជាមួយលោកនោះ ខ្ញុំអាននូវចម្លើយមួយចំនួនដែលលោកបានផ្ដល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ។ ហើយខ្ញុំចង់ដឹងថាតើលោកបានឆ្លើយអ៊ីចឹងមែនឬក៏មិនមែន ដើម្បីឲ្យលោកបញ្ជាក់អំពីចម្លើយមួយចំនួន ដែលលោកបានឆ្លើយ ខ្ញុំចាប់ផ្ដើមជាមួយចម្លើយមួយដែលលោកបានផ្ដល់ដែលបានផ្ដល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីជូនជាលេខយោងនោះ គឺលេខ D2216 ហើយលេខ ERN ជាភាសាបារាំងនោះគឺ 00165022 រហូតដល់ 00165023 ។ ខ្ញុំនឹងបញ្ជាក់ថាតើ ខ្ញុំនឹងអានសួរសំណួរ ហើយឲ្យលោកឆ្លើយបទសម្ភាសន៍នេះធ្វើឡើងនៅឆ្នាំ២០០៧ នៅថ្ងៃទី០៧ ខែកញ្ញា

សំណួរដែលគេសួរទៅលោក គឺដូចខាងក្រោមនេះ ។

[១១:៣៥:១៨]

បន្ទាប់ពី ឌុច មើលចម្លើយសារភាពមុននឹងផ្តល់យោបល់ទៅលើចម្លើយសារភាពនោះ តើ ឌុច ត្រូវសួរទៅថ្នាក់លើមុននឹងផ្តល់-- មុនសរសេរជាចម្លើយសារភាពដែរឬទេ ចម្លើយរបស់លោកហ្នឹង? តាមអ្វីដែលខ្ញុំសង្កេតនោះ ប្រហែលជាបន្ទាប់ពីគាត់មើលចម្លើយ គាត់ធ្វើការវិភាគចម្លើយនោះ ដើម្បីរកមើលថា តើត្រូវសួរបន្ត ឬក៏អត់? ថាតើចម្លើយនោះត្រូវបញ្ជូនទៅថ្នាក់ឬអត់? ហើយប្រសិនបើត្រូវសួរបន្ថែម ឌុច ធ្វើចំណារឲ្យធ្វើការសួរបន្ថែមទៀត ជាទូទៅតើ ឌុច ត្រូវប្រើពេលប៉ុន្មានដើម្បីធ្វើចំណារចម្លើយជួនកាលប្រើពេលវែង ប៉ុន្តែមិនខ្លី ប៉ុន្តែមិនលើសពីមួយអាទិត្យទេ ។ សំណួរតើនៅក្នុងករណីណាដែល ឌុច ប្រើជាចំណារចម្លើយសារភាពដែលមានចំណារទៅថ្នាក់លើ? លោកឆ្លើយថា ប្រហែលជាបន្ទាប់ពី ឌុច គិតថា វាមានលក្ខណៈគ្រប់គ្រាន់ហើយ ហើយចម្លើយសារភាពនោះគឺវាត្រឹមត្រូវ បន្ទាប់មកហើយគាត់នឹងបញ្ជូនទៅថ្នាក់លើ ។ លោកសាក្សី តើលោកនៅចាំទេ ពីការសម្ភាសន៍ ហើយនិងការឆ្លើយទៅចៅក្រម សហចៅក្រមស៊ើបអង្កេតពីរឿងនេះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកខ្ញុំនៅចាំបាន ។

**ស៖** តើអ្វីដែលលោកបានបញ្ជាក់នោះ សុទ្ធតែជាការពិតដែរឬទេលោកសាក្សី?

**ឆ៖** អ្វីដែលខ្ញុំនិយាយជាមួយនិងអ្នកស៊ើបអង្កេតរបស់លោកចៅក្រមស៊ើបអង្កេត គឺទីមួយ ខ្ញុំយល់ថាជាការពិត ដោយខ្ញុំវិភាគ ខ្ញុំមិនបានដឹងច្បាស់ទេ ក៏ប៉ុន្តែខ្ញុំវិភាគថាអ៊ីចឹង ។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំសូមបង្ហាញជូនលោកនូវសេចក្តីដកស្រង់ អំពីចម្លើយសារ-ភាពនៅ D52 ជាភាសាបារាំង 00164397 នេះជាចម្លើយដែលលោកនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ-- ខែកុម្ភៈ ឆ្នាំ២០០៨ ។ ខ្ញុំយល់-- លោកឆ្លើយថា ខ្ញុំយល់ថា ឌុច រាយការណ៍ទៅថ្នាក់លើគ្រប់សាច់រឿងតាមការសរសេរទាល់តែថ្នាក់លើសួរតាមទូរស័ព្ទ ទើបឆ្លើយតាមទូរស័ព្ទ ខ្ញុំដឹងថា បញ្ជីអ្នកទោសទាំងអស់ត្រូវបញ្ជូនទៅខាងមជ្ឈិមដែលជាអ្នកធ្វើការសម្រេច ហើយបញ្ជីនេះ គឺជាបញ្ជីអ្នកសួរចម្លើយបានធ្វើ ។ តាមខ្ញុំសន្និដ្ឋាន តាមច្បាប់គឺមជ្ឈិម ផ្ញើចម្លើយសារភាពទៅឲ្យខាងមូលដ្ឋាន ហើយមូលដ្ឋានតាមដាន រួចហើយធ្វើការចាប់អ្នកទោស ជួនកាលខាងមូលដ្ឋានយកមកជួនកាលខាងស-២១ ទៅយក ។ ហើយសំណួររបស់ខ្ញុំគឺ ដូចគ្នានឹងខាងដើមដែរ តើលោកនៅចាំបានថាលោកបានឆ្លើយចម្លើយនេះ ទៅសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងបញ្ជីអ្នកសួរចម្លើយបែបនេះដែរឬទេ?

[១១:៣៩:៣៤]

**ឆ៖** ខ្ញុំសុំជម្រាបលោកថា ដែលខ្ញុំនិយាយនោះ គឺវាជាការពិត បញ្ហើដែលអ្នកសួរចម្លើយធ្វើហ្នឹង គឺថា ពពួកដែលគេឆ្លើយដាក់ គេឆ្លើយដាក់អ្នកណាៗ ហ្នឹងអ្នកសួរចម្លើយសរសេរអ៊ីចឹង ។

**ស៖** ប្រសិនបើលោកនៅចាំថាតើការធ្វើបែបនេះកើតឡើងប៉ុន្មានដងដែរ?

**ឆ៖** សូមជម្រាបលោកខ្ញុំមិនដឹងជាកើតឡើងប៉ុន្មានដងទេ ។

**ស៖** តាមដែលការចងចាំរបស់លោកថាតើមានតែម្តង ឬមួយយ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនចាំដែរ មិនដឹងប៉ុន្មាន ។

**ស៖** ខ្ញុំចង់បង្ហាញជូនអំពីចម្លើយដែលលោកបានផ្តល់សហចៅក្រមស៊ើបអង្កេត គឺនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ គឺនៅក្នុងឯកសារភាសាបារាំង 0016033 ហើយនិង 00165034 អ៊ីចឹងខ្ញុំនឹងសួរផ្អែកទៅតាមហ្នឹង ។ ដូច្នេះហើយ គឺមានការចាប់ខ្លួននៅស-២១ ដែលបានផ្តួចផ្តើមដោយ ឌុច ហើយអនុញ្ញាតដោយថ្នាក់លើ ។ ចម្លើយ វាត្រូវតែធ្វើបានតាមបែបនោះ សំណួរចំពោះមនុស្សដែលលោកចង់ជួយ តើមានអ្នកណាម្នាក់ដែលលោកចង់ជួយនោះ ហើយមិនអាចជួយបាន? លោកបានឆ្លើយថា ក្រៅពីអ្នកទាំងអស់ដែលនៅក្នុងអង្គភាពដែលបានចូលបដិវត្តន៍ជាមួយខ្ញុំនោះនៅពេលដែល ឌុច បានឲ្យខ្ញុំដឹង ខ្ញុំអាចការពារបាន ពីព្រោះ ឌុច ស្តាប់គំនិតខ្ញុំ ប្រសិនបើមិនបានចូលបដិវត្តន៍ជាមួយខ្ញុំទេ ខ្ញុំមិនអាចហ៊ានការពារអ្នកទាំងនោះទេ ។ សំណួរគេសួរទៀត នៅពេលចុងក្រោយដែលលោកនិយាយបានឃើញ សិស្សម្នាក់ដែលគេចាប់មកនោះ ហើយលោកមិនអាចជួយបាន តើមានហេតុការណ៍អីកើតឡើង លោកបានឆ្លើយថា កូនសិស្សរបស់ខ្ញុំ ដែលខ្ញុំមិនអាចហ៊ានជួយនោះ ត្រូវបានចាប់ខ្លួនដោយពីមូលដ្ឋាន ចាប់ដោយមូលដ្ឋានហើយបញ្ជូនមក ហើយខ្ញុំបានជួបគាត់ ហើយខ្ញុំមិនអាចជួយបបាន បើសិនជាខ្ញុំបានដឹងមុន ហើយគេបានប្រាប់ខ្ញុំថា គាត់មានបញ្ហា ខ្ញុំអាចធានាថា គាត់ជា អ្នកនោះជាសិស្សរបស់ខ្ញុំ ហ្នឹងលោកឆ្លើយអ៊ីចឹង ។ តើលោកចាំទេ ថាលោកបានឆ្លើយបែបនោះ ចំពោះសហចៅក្រមស៊ើបអង្កេតនោះលោកសក្សី?

[១១:៤៣:០០]

**ឆ៖** ខ្ញុំសុំជម្រាបលោក ខ្ញុំបានឆ្លើយអ៊ីចឹមែន ។ មូលហេតុដែលនាំឲ្យខ្ញុំហ៊ានការពារ ពីព្រោះខ្ញុំស្រលាញ់យុត្តិធម៌ ហើយអ្នកនោះវាអត់មានខុសអី ។ ដូច្នេះ ក៏ត្រូវតែការពារយុត្តិធម៌ហើយ ។ ហើយជាអ្នកស្គាល់គ្នាអ្នកអីគ្នា តែអ្នកមិនស្គាល់គ្នា អាហ្នឹងវាមិនដឹងរកខុសត្រូវល្អអាក្រក់អីឲ្យបានទេ ។

**ស៖** សូមលោកបញ្ជាក់ថាតើអ្វីដែលខ្ញុំបានអានជូនលោកនោះ តើជាការពិតដែរឬទេ?

**ឆ៖** វាជាការពិត ។

**ស៖** ខ្ញុំបន្តទៅមុខទៀតភ្លាមៗបន្ទាប់ពីនោះមក គឺបន្ទាប់ពីសេចក្តីដកស្រង់នោះមកគឺបន្តទៅទៀត ហើយលោកបាននិយាយតទៅទៀតថា ដូចជាលោក ឆាយ គឹមហួ ហៅថា ហុក ដែលនិយាយអំពីអ្វីៗ ដែលនិយាយថា អាមេរិកាំង ហើយនិងចិន ឌុច បានប្រាប់ខ្ញុំថា គាត់បានរាយការណ៍រឿងនេះទៅគណៈ មជ្ឈិម តើមានមនុស្សប៉ុន្មាននាក់ដែលឆ្លើយដាក់គេ? ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំគិតថា ប្រហែលជារួមជាមួយ គាត់ដែលថា មានការឆ្លើយដាក់មុននឹងធ្វើការចាប់ខ្លួនគាត់នោះ ។ សំណួរគឺសួរទៀត ដូច្នេះ នៅពេល នោះតើឌុចមានសិទ្ធិស្នើទៅអង្គការដើម្បីចាប់ខ្លួនអ្នកណានៅឯក្រៅពីស-២១ទេ?លោកឆ្លើយថា ឌុច អាច រាយការណ៍ ដែលគាត់ដឹងដោយផ្ទាល់ ។ សួរតទៅទៀត តើមានរឿងអ្វីកើតឡើងដែលថា ឌុច បាន ស្គាល់ៗ ហុក និយាយអំពីរឿងប្រេងនោះ ។ ឆ្លើយ ឌុច បានទៅផ្ទះរបស់ ហុកហើយ ហុក នោះក៏មាន អំនួតហើយបាននិយាយដោយត្រង់ជាមួយនឹង ឌុច ហើយ ឌុច នោះបានរាយការណ៍យ៉ាងឆាប់ទៅថ្នាក់ លើ ហើយដូច្នេះគឺថាថ្នាក់លើ ឬក៏ប្រធានវរសេនាតូចបានរាយការណ៍មកវិញថា អង្គការបានជូនចោទ ថាជាខ្មែរសេរីនោះ ។ ដូច្នេះហើយដែលថា ឌុច បានដឹងរឿងហើយរាយការណ៍ទៅថ្នាក់លើយ៉ាងឆាប់ ។ តើលោកបានឆ្លើយបែបនេះទេ ទៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោក! ខ្ញុំនិយាយអ៊ីចឹងមែន ។

**ស៖** តើអ្វីស្របតាមការពិតដែរទេ លោកសាក្សី?

**ឆ៖** ជម្រាបលោកមេធាវី កាលដែល មិត្តឌុច រាយការណ៍ពីខ្ញុំថា ខ្លាំងឆ្លើយដាក់ កាលដែលមិត្ត ឌុច រាយការណ៍ថា មិត្តហុក និយាយពីប្រេងចិនវាអន់ជាងប្រេងអាមេរិកាំង អាហ្នឹងគឺវាជាការពិត ពីព្រោះគាត់គ្មានគោលបំណងអីទេ គាត់គ្រាន់តែចង់ឲ្យខាងលើវិភាគសភាពការណ៍ប៉ុណ្ណឹង ហើយត្រង់ ថាមានចម្លើយអ្នកណាឆ្លើយដាក់ មិត្តហុក តទៅទៀត អាហ្នឹងវាជារឿងផ្សេង ដែលខ្ញុំមិនដឹងទេ ។

**ស៖** នៅពេលដែលបញ្ជាក់ថា ឌុច រាយការណ៍ឆាប់រាយការណ៍ តើជាការពិតទេថាឆាប់រាយ-ការណ៍ទៅថ្នាក់លើនោះ?

**ឆ៖** តាមខ្ញុំយល់គឺថាវាជាការពិត គាត់ឆាប់ ។

**ស៖** សូមអរគុណលោកសាក្សី ។ គឺថាបីខែកន្លងទៅនេះ យោងទៅចំណុចមួយនៅ ម-១៣ ដែលលោកចៅក្រម ឡាវែន៍ បានសួរសំណួរទៅជនជាប់ចោទ ហើយខ្ញុំសួរ ហើយនៅក្នុងបារាំងគឺថា

0081569 នោះគឺនិយាយអំពីម-១៣ ។ អ្នកយាមមានអាវុធនៅពេលអ្នកណាម្នាក់រត់គេចខ្លួនហើយគឺ អ្នកយាមត្រូវបាញ់ទៅអ្នករត់គេចខ្លួននោះ តើត្រូវដែរឬទេ? ជនជាប់ចោទឆ្លើយថាកងការពារមាន កាំភ្លើងហើយកាលណាមានអ្នកណារត់ហើយត្រូវតែបាញ់ នេះគឺជារឿងពិត ។ ខ្ញុំសូមនិយាយបញ្ហាមួយ ព្រឹត្តិការណ៍ហ្នឹងវាកើតឡើងហើយ ដើម្បីជាឧទាហរណ៍អ្នករត់ហើយគឺ ត្រូវតែបាញ់ ។ នៅពេលនោះ ខ្ញុំមិនបាននៅ ខ្ញុំទៅធ្វើការគឺលោក ម៉ម ណៃ ដែលជាអ្នករត់ដេញបាញ់អ្នករត់នោះ ហើយទាញកាំភ្លើង បាញ់ ហើយ សារុន គឺជាអ្នកយាមដែលបាញ់ត្រង់ណាស់ ហើយលើកកាំភ្លើងឡើងច្រឡំចំលោក ម៉ម ណៃ នេះគឺអ្នកយាមយល់ថាលោក ម៉ម ណៃ ជាអ្នករត់ ។ អ៊ីចឹងហើយ ដូច្នេះអារឿងដេញបាញ់អ្នករត់ ដែលជារងគ្រោះមកជាប់ទោសនោះ វាច្រឡំគ្នាឯងនេះ ជាគោលការណ៍ដែលខ្ញុំលើកឡើងដើម្បីជម្រាប ថា វាជាការពិតមានបញ្ហាមួយថា ត្រូវតែបាញ់ ។ តើនេះជាការពិតទេដោយមិនបាច់និយាយទៅដល់ រឿងលម្អិតនោះ ដែលលើកខាងដើមនោះជារឿងពិតដែរឬទេ?

[១១:៤៩:២១]

**ឆ៖** សូមជម្រាបលោកមេធាវី! វាជាការពិតខ្ញុំត្រូវអ្នករត់ពីក្រោយបាញ់ខ្ញុំ ព្រោះខ្ញុំរត់លឿនជាង គេជាងក្មេងៗបន្តិច ពីព្រោះខ្ញុំតាមផ្លូវកាត់ ។ អាហ្នឹងគឺអ្នកនៅពីក្រោយបាញ់ត្រូវខ្ញុំប្អូនគ្រាប់ ។

**ស៖** សូមអរគុណលោកសាក្សី គឺថាមានប្រធានបទមួយទៀតដែលខ្ញុំនឹងលើកឡើង គឺថា បញ្ហា នេះបានលើកឡើងជាច្រើន ហើយខ្ញុំចង់សួរសំណួរនេះបន្ថែមគឺអ្វីដែលលោកបាននិយាយចំពោះមុខសហ ចៅក្រមស៊ើបអង្កេតចំពោះបញ្ហាមួយចំនួន គឺថា លោកហើយនិងអ្នកផ្សេងទៀតបានចូលរួមនៅក្នុងការ សម្តែងឡើងវិញ លោកបានទៅទួលស្លែងតាមការអញ្ជើញដោយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំបាន យោងទៅរកកំណត់ត្រានៃការសម្តែងឡើងវិញ ចាប់ពីលេខERN ភាសាបារាំងលេខ00181347 ហើយ ខ្ញុំយោងជាពិសេសយោងទៅទំព័រលេខ 00181353 ហើយគឺថា មានសហចៅក្រមស៊ើបអង្កេត ហើយ មានជនតំណាងខាងសហព្រះរាជអាជ្ញា មានជនជាប់ចោទ ហើយគឺមានមនុស្សមួយចំនួនដែលនិយាយ ជាសាធារណៈដែលថាមានប្រតិចារឹកនៅក្នុងឯកសារនេះ ។ ហើយឯកសារដែលខ្ញុំបានយោងអម្បាញ់ មិញនេះ ក្នុងពេលការសម្តែងឡើងវិញនោះ លោកហើយនិងអ្នកចូលរួមផ្សេងទៀតបានទៅបន្ទប់ទីបីនៅ ក្នុងអគារ “D” បន្ទប់មួយ បន្ទប់ទីបីដែលមានឧបករណ៍ធ្វើទារុណកម្មផ្សេងៗដែលគេដាក់តាំងនៅកន្លែង នោះ ។ ហើយនៅពេលនៅទីនោះ ជនជាប់ចោទពន្យល់ថា ការជ្រើសរើសឧបករណ៍សម្រាប់ធ្វើទារុណ កម្ម គឺអាស្រ័យទៅលើអ្នកសួរចម្លើយម្នាក់ៗ ហើយសាក្សីបាននិយាយថា អ្វីដែលបានគេនិយាយនោះ គឺ

គេនិយាយថាសាក្សី ម៉ម ណៃ ប្រកាសថា គាត់ធ្លាប់ប្រើតែរំពាត់និងខ្សែភ្លើងតែប៉ុណ្ណោះ ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ។

តើពិតដែរទេថា ចំពោះមុខសហចៅក្រមស៊ើបអង្កេតហើយនិងមេធាវីការពារនៅក្នុងបន្ទប់ទីបីជាន់ក្រោមនៃអគារ “D” ខាងក្រោយ លោកបាននិយាយការពិតទេនៅពេលនោះៗ?

[១១:៥២:២៣]

**ឆ៖** សូមជម្រាបលោកមេធាវី ខ្ញុំមិនឆ្លើយតបទេ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកសាក្សី ដែលបានឆ្លើយសំណួររបស់ខ្ញុំ ខ្ញុំមិនមានសំណួរអ្វីតទៅទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹងវេទិកាសម្រាប់សួរសំណួរដល់សាក្សីរូបនេះ ដោយមេធាវីតំណាងដើមរដ្ឋប្បវេណីឃើញថាដល់ទីបញ្ចប់ហើយ ហើយពេលវេលាសល់តិចតួចទេដែលត្រូវសម្រាក ។ ដូច្នេះ ដោយពេលវេលានេះ គឺដល់ពេលត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ ។ ហើយអង្គជំនុំជម្រះនឹងបន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយកន្លះទៅ ហើយមន្ត្រីតុលាការជួយសម្របសម្រួលដើម្បីឲ្យសាក្សីរូបនេះបានទទួលកន្លែងសម្រាកសមរម្យ ។

អនុរក្សមន្ត្រីមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំគាត់ត្រលប់មកវិញឲ្យបានមុនម៉ោងប្រាំមួយសាមសិបនាទី ។

*[សវនាការសម្រាកនៅម៉ោង ១១:៥៦នាទី ដល់ម៉ោង ១៣:៣២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោល ចំពោះសាក្សីឈ្មោះ ម៉ម ណៃ ហៅចាន់ ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តី បើសិនជាមានសំណួរត្រូវសួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ មេធាវីការពារក្តី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។

**ស៖** លោក ម៉ម ណៃ នៅម-១៣ លោកថា លោកមានភារកិច្ចពីរ ។ មួយគឺដាំដំឡូង ។ ទីពីរ អង្គុយស្ដាប់សមមិត្ត ឌុច សួរចម្លើយ គឺបានសេចក្ដីថាលោករៀនសូត្រសួរចម្លើយ ។ អ៊ីចឹងតើនៅម-១៣ លោកសួរចម្លើយបានប្រហែលប៉ុន្មាននាក់? លោកអាចស្មានបានទេ?

**ឆ៖** សូមជម្រាបលោកមេធាវី! នៅម-១៣ ខ្ញុំសួរចម្លើយបានប្រហែលជាដប់នាក់ អីប៉ុណ្ណឹងទេ ។

**ស៖** សូមអរគុណ ។ ព្រឹកមិញនៅម-១៣ លោកបានមានប្រសាសន៍ថា លោកឃើញលែងអ្នកទោសពីរនាក់ ។ តើអ្នកទោសពីរនាក់នោះលោកស្គាល់ឈ្មោះទេ? ឈ្មោះអីខ្លះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! បើតាមខ្ញុំចាំ ចាំច្បាស់ម្នាក់ ម្នាក់ទៀតមិនច្បាស់ទេ ។ ម្នាក់ដែលចាំច្បាស់ គឺឈ្មោះសុខ ហើយម្នាក់ទៀត ដែលចាំមិនច្បាស់ប្រហែលជាឈ្មោះ ហេង ។

**ស៖** សូមអរគុណ ។ លោកមានដឹងទេ តើគាត់ ដូចជាលែងគាត់ទៅវិញហ្នឹង គាត់ដោយមូល-ហេតុអីបានជាគេលែងទៅវិញ?

**ឆ៖** បញ្ហានឹងខ្ញុំក៏មិនដឹងច្បាស់ដែរ អាហ្នឹងគឺថាជាភារកិច្ចដែលមិត្ត ឌុច គាត់ទទួលការណែនាំពីខាងលើយ៉ាងម៉េច ខ្ញុំមិនដឹងទេ ។

**ស៖** សូមអរគុណ ។ នៅម-១៣ ហ្នឹង គេចែកជាពីរកន្លែង ។ មានមួយ គេហៅថា ម-១៣ "ក" ។ មួយទៀត ម-១៣ "ខ" ។ តើលោកដែលទៅម-១៣ "ខ" ដែរឬទេ?

**ឆ៖** ខ្ញុំកាលមុន ខ្ញុំក្ដាប់មិនបានថាម-១៣ "ក" ឬ ម-១៣ "ខ" ទេ ។ តែក្រោយមកបានដឹង គឺខ្ញុំបានមុននឹងនែ៎ ខ្ញុំទៅដល់អមលាំងហ្នឹង មិត្តឌុច បាននាំខ្ញុំចូលអើតម-១៣ "ខ" ហ្នឹងមួយភ្លែត ហើយបានហួស នែ៎អមលាំងទៅ ។

[១៣:៣៥:៣២]

**ស៖** សូមអរគុណ ។ អ៊ីចឹង នៅម-១៣ "ខ" ហ្នឹង លោកអត់បានដឹងថាគេឲ្យអ្នកទោសធ្វើអីខ្លះ? លោកបានដឹងទេ?

**ឆ៖** ខ្ញុំអត់បានដឹងរឿងគេឲ្យធ្វើអីខ្លះទេ ។

**ស៖** សូមអរគុណ ។ នៅម-១៣ ដដែលនេះ នៅពេលដែលគេដោះលែងលោក ហ្វ្រង់ស័រ ប៊ីហ្សូ លោកដឹងដែរទេ? ហើយលោកនៅទីនោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី គេដោះលែង ប៊ីហ្សូ ហ្នឹង ខ្ញុំមិនទាន់បានទៅដល់ផង ។ មិនទាន់បានទៅទីនោះផង ហើយខ្ញុំក៏មិនដឹងថាមានអ្នកទោស នែ៎ ប៊ីហ្សូ ហ្នឹងដែរ ។

**ស៖** សូមអរគុណ ។ អំពីជម្លោះប្រដាប់អាវុធ លោកបានជម្រាបប្រាប់អង្គសវនាការថា យួនដែលចាប់បាន រួចបញ្ជូនមកស-២១ ។ លោកបានកំណត់ថា ជាយួនឈ្លានពានលេបទឹកដីកម្ពុជាអ៊ីចឹងមែនទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នេះជាការពិត ។

**ស៖** សូមអរគុណ ។ ចុះយោធារបស់កម្ពុជាប្រជាធិបតេយ្យដែលចូលទឹកដីយួនពេលនោះ តើលោកបានដឹងទេ?

**ឆ៖** ពេលនោះខ្ញុំមិនដឹងទេ ក៏ប៉ុន្តែតាមខ្ញុំសន្និដ្ឋានថា ការវ៉ៃគ្នាទៅវិញទៅមកតែងតែដេញគ្នាចុះឡើងហើយ ។

**ស៖** សូមអរគុណ ។ នៅស-២១ និង ជើងឯក លោកមានស្គាល់បុគ្គលិកពេទ្យស-២១ ទេ?

**ឆ៖** នៅស-២១ ចំពោះពួកពេទ្យ ខ្ញុំមិនបានស្គាល់ច្បាស់ទេ គ្រាន់តែឮឈ្មោះ ទ្រី មួយប៉ុណ្ណឹង ។

**ស៖** បើលោកស្គាល់មិនច្បាស់ តើលោកមានដឹងថា បុគ្គលិកពេទ្យនៅស-២១ ហ្នឹង មានភេទជាស្រីទេ?

**ឆ៖** សុំអត់ទោស ខ្ញុំមិនដឹងដែរ ។

**ស៖** សូមអរគុណ ។ លោកជាអ្នកសួរចម្លើយ លោកដែលប្រទះឃើញវិន័យសន្តិបាលទាំង១០ "ខ" ដែរឬទេ?

[១៣:៣៩:០០]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! មិនដែលឃើញទេ ។

**ស៖** សូមអរគុណ។ សូមលោកបញ្ជាក់ឲ្យបានច្បាស់ តើចម្លើយសារភាពរបស់លោកសាស្ត្រាចារ្យមហាបរិញ្ញា ភីង តុន គាត់សរសេរដោយខ្លួនផ្ទាល់ចេញពីសុទ្ធចិត្តគាត់ណោះ ដោយផ្ទាល់ដៃគាត់ ឬក៏មានគេបង្ខិតបង្ខំគាត់ ហើយលោកសង្ខេបចម្លើយនេះទៅឲ្យ ច ឬយ៉ាងម៉េច? សូមលោកបញ្ជាក់?

**ឆ៖** បញ្ហាសួរចម្លើយលោក ភឹង តុន ប្រាកដជាខ្ញុំសួរ ហើយគ្មានការបង្ខិតបង្ខំអីគាត់ទេ ។ ដូចជាលោកគ្រូខ្ញុំ ចៅ សេង អ៊ីចឹង គឺថាឲ្យគាត់និយាយតាមសេរីទៅ ។

**ស៖** សូមអរគុណ ។ នៅស-២១ របៀបរបបគ្រប់គ្រងចាត់ចែងការងារកាល អ៊ិន លន ហៅ ណាត ជាប្រធាន ហើយដល់ ឌុច ឡើងជាប្រធាន ។ តើមានការប្រែប្រួលរបៀបគ្រប់គ្រងចាត់ចែងការងារដែរឬទេ? ឬក៏ទុកនៅដដែល?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! របៀបរបបខ្ញុំវិភាគទៅគឺប្រហាក់ប្រហែលគ្នាទេ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណតុលាការ។ ខ្ញុំអស់សំណួរ សូមឲ្យលោកមេធាវីអន្តរជាតិសួរបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ សូមសួរស្តី លោក ម៉ម ណៃ ខ្ញុំមានឈ្មោះ ហ្វ្រង់ស្វ័រ រូ ។ ខ្ញុំជាមេធាវីការពារក្តី ឌុច ។ ខ្ញុំចង់សួរសំណួរជូនលោកមួយចំនួន ប៉ុន្តែខ្ញុំមានបំណងនិយាយដោយស្មោះត្រង់ជាមួយនឹងលោក ។ ដូចដែលលោក វ៉ែនណឺ បានបញ្ជាក់ប្រាប់លោកហើយកាលពីម្សិលមិញ ។ នៅពេលដែលលោកបានឆ្លើយតបទៅនឹងសំណួរទាំងឡាយនោះ លោកមានកាតព្វកិច្ចក្នុងការនិយាយតែការពិត ។ ប៉ុន្តែ ប្រសិនបើលោកមានបំណងមិនឆ្លើយតបទៅនឹងសំណួរ លោកមានសិទ្ធិមាននៅស្ងៀមមិននិយាយស្តី ដូចដែលលោកបានធ្វើព្រឹកមិញ ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ដើម្បីខ្ញុំបញ្ជាក់ត្រង់ជូនលោក លោកមិនគួរជឿសហព្រះរាជអាជ្ញានៅពេលដែលសហព្រះរាជអាជ្ញាប្រាប់លោកថា គាត់មិនអាចធ្វើការចោទប្រកាន់រូបលោកនោះទេ ។ មេធាវីការពារក្តី ទើបតែទទួលបាននៅពេលដែលញុាំអាហារថ្ងៃត្រង់ ទទួលបានឯកសារមួយដែលមានចំណងជើងថា ចម្លើយជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា ចំពោះបញ្ហាអញ្ញត្រកម្មដែលលើកឡើងដោយមេធាវីការពារក្តី ។ នៅក្នុងនោះ សហព្រះរាជអាជ្ញាបានតវ៉ាទៅលើការអនុវត្តទៅបាននៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ កថាខណ្ឌលេខ២០ នៃឯកសារនោះ វាក្យខណ្ឌ២១ នៃឯកសារនេះ សហព្រះរាជអាជ្ញា បានលើកឡើង ដោយលើកឡើងអំពីអនុសញ្ញាលើបញ្ហាទារុណកម្ម ។ ហើយដែលប្រទេសកម្ពុជាទទួលបន្ទុកក្នុងការចោទប្រកាន់ទៅលើបុគ្គលទាំងឡាយណា ដែលគេសន្និដ្ឋានថា ទទួលខុសត្រូវ

ចំពោះអំពើទារុណកម្ម ។

ដូច្នេះ អ្វីដែលគាត់បានលើកឡើងផ្ទាល់មាត់ព្រឹកនោះ គឺវាមិនដូចនឹងអ្វី ដែលគាត់សរសេរក្នុងឯកសារជាលាយលក្ខណ៍អក្សររបស់គាត់នោះទេ ។ ដូច្នេះ ចំពោះខ្ញុំ ខ្ញុំមានសំណួរមួយចំនួន ហើយខ្ញុំនឹងសួរលោកដោយត្រង់ៗតែម្តង ។ លោកបានពន្យល់ប្រាប់អង្គសវនាការ--

[១៣:៤៤:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

លោក លោកស្រីចៅក្រម! ដូចដែលខ្ញុំបានរំឭកមេធាវីការពារក្តីកាលពីម្សិលមិញ បញ្ហាទាក់ទងទៅនឹងវិធាន២៨ គួរតែពិភាក្សាអសាធារណៈ ។ ហើយនេះលើកទីពីរហើយ ដែលមេធាវីការពារក្តីបានលើកឡើងជាសាធារណៈ មិនមែនជាអសាធារណៈនោះទេ ។ ប៉ុន្តែ វាអាចជាបញ្ហាការបកប្រែ ហើយយើងបានបញ្ជាក់ហើយកាលម្សិលមិញថា មិនមានការចោទប្រកាន់ណាមួយនោះទេ ។ ដូច្នេះហើយគាត់នៅដាច់ឆ្ងាយណាស់ ។ ដូច្នេះ ខ្ញុំស្នើសុំថាប្រសិនបើមេធាវីការពារក្តីលើកបញ្ហានេះ ដែលវាជាបញ្ហារសើបនោះ គឺគាត់ធ្វើយ៉ាងណាលើកឡើងឲ្យបានសមស្របតាមវិធាន២៨.៨ ។ ហើយគាត់គួរតែសួរសំណួរទៅកាន់សាក្សី ដោយមិនចាំបាច់លើកអំពីបញ្ហានេះក្នុងពេលដែលមិនស្របនោះទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ តំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបទៅលោក ហ្វ្រង់ស្វ័រ រូ ដែលជាមេធាវីការពារក្តី ថានាទីដែលអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី គឺឲ្យមេធាវីតាំងសំណួរសួរពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ទៅលើរឿងក្តីរបស់លោក ។ អង្គជំនុំជម្រះមិនបានប្រគល់វេទិកានេះទៅឲ្យលោកធ្វើសេចក្តីថ្លែងការណ៍ផ្សេងពីការតាំងសំណួរទេ ។ បញ្ហាទីពីរ អំពីសិទ្ធិនិងករណីកិច្ចនេះ អង្គជំនុំជម្រះមានតួនាទីក្នុងការជម្រាប និងប្រាប់ដល់សាក្សីរួចហើយ ។ មិនមែនជាមុខងាររបស់មេធាវី ដែលត្រូវរំឭក ឬក៏បង្កើបបញ្ហានោះទេ ។ ហើយអង្គជំនុំជម្រះក៏បានរៀបចំចាត់ចែងចាត់តាំងមេធាវីមួយរូបជំនួយ ដើម្បីពិគ្រោះពិភាក្សាយោបល់ចំពោះសំណួរ ឬក៏សូមឲ្យសាក្សីរូបនេះធ្វើអះអាងណាមួយ ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនគាត់រួចហើយដែរ ។

ដូច្នេះ វេទិកានេះជម្រាបមេធាវីការពារក្តីថា លោកមានប្រើសិទ្ធិក្នុងការសួរសាក្សីរូបនេះនូវអ្វី

ដែលបំណងស្វែងរកការពិត មិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍ក្រៅផ្សេងពីការតាំងសំណួរចំពោះសាក្សីរូបនេះឡើយ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន គឺខ្ញុំសូមរំឭកអង្គសវនាការដោយគោរពថា សហព្រះរាជអាជ្ញាជាតិគាត់បានចាប់ផ្តើមលើកឡើងបញ្ហានេះព្រឹកមិញ ដោយបញ្ជាក់ជូនសាក្សីថា គាត់មិនទទួលគ្រោះថ្នាក់ក្នុងទទួលការចោទប្រកាន់នោះទេ ។

**ប្រធានអង្គជំនុំ៖**

អត់មានអនុញ្ញាតឲ្យលោកលើពីបញ្ហានេះទេ លោកអាចសួរឬក៏អត់ បើអត់ យើងនឹងបិទការសួរដេញដោលចំពោះសាក្សីរូបនេះ ហើយយើងនឹងអញ្ជើញសាក្សីថ្មីមក។ បើលោកអត់មានសំណួរអីសួរទេច្បាស់លាស់ គឺអង្គជំនុំជម្រះនឹងបញ្ចប់ការសួរដេញដោលចំពោះសាក្សីរូបនេះ ហើយបន្តទៅសាក្សីមួយទៀត ។

[១៣:៤៨:១៩]

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** ខ្ញុំហៀបនឹងលើកឡើងហើយមុនពេលដែលសហព្រះរាជអាជ្ញាបានកាត់សម្តីខ្ញុំ ។ ហើយគឺគាត់បានលើកឡើងជូនអង្គសវនាការ ដែលលើកឡើងអំពីបញ្ហាចូលរួមក្នុងបដិវត្តន៍ ។ ហើយខ្ញុំចង់ជម្រាបអំពី ថាតើលោកអាចជម្រាបជូនអង្គសវនាការទេ ថាមូលហេតុផ្ទាល់ខ្លួនអ្វីបានជាលោកចូលរួមក្នុងនៅបដិវត្តន៍លោកសាក្សី?

**ឆ៖** សូមជម្រាបលោកមេធាវី! មូលហេតុដែលខ្ញុំចូលរួមក្នុងបដិវត្តន៍ ព្រោះកាលខ្ញុំរៀននៅថ្នាក់ទី៣ រៀនប្រវត្តិសាស្ត្រសូវៀត ហើយនិងប្រវត្តិសាស្ត្រចិន ទៅឃើញបញ្ហាកុម្មុយនីស្ត ។ ខ្ញុំក៏ស្រឡាញ់លទ្ធិកុម្មុយនីស្ត ដោយលើកស្ទួយវណ្ណៈអធន គឺពួកអ្នកក្រីក្រ។ ដូច្នេះ ខ្ញុំក៏ចូលធ្វើបដិវត្តន៍ទៅ ។

**ស៖** នៅពេលដែលលោកចូលរួមក្នុងបដិវត្តន៍ លោកបានជម្រាបជូនអង្គសវនាការថា គេប្រាប់យើងឲ្យយើងកសាងខ្លួន ដោយដើរតាមមាគ៌ានយោបាយ ។ ថាតើចំណុចនេះវាមានន័យយ៉ាងម៉េចចំពោះលោក? ថាតើកសាងខ្លួនឯងនោះ គឺមានន័យយ៉ាងម៉េច? ដោយសារតែលោកប្តេជ្ញាទៅក្នុងជួរបក្សកុម្មុយនីស្តហើយ ថាតើលោកលើកឡើងថា ប្តេជ្ញាកសាងខ្លួននេះ គឺមានន័យយ៉ាងម៉េចដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ប្ដេជ្ញាកសាងខ្លួន គឺកសាងសតិអារម្មណ៍ ទស្សនៈ និងគោលជំហរឲ្យទៅជាវណ្ណៈអធន គឺឲ្យមានតែបាតដៃទទេ គ្មានជាប់ជំពាក់ជំពិននឹងទ្រព្យសម្បត្តិអីផ្សេងទៀតទេ គឺមួយរស់ ។

**ស៖** តើលោកជឿទេថា លោកទទួលបានជោគជ័យក្នុងការកសាងខ្លួនលោក?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំជឿ ពីព្រោះអីខ្ញុំកសាងខ្លួនខ្ញុំ ខ្ញុំជាអ្នករដ្ឋការ ជាសាស្ត្រាចារ្យ ជាវណ្ណៈអនុធនថ្នាក់លើ ដល់ខ្ញុំខំកសាងខ្លួនឲ្យទៅជាកសិករ ទៅជាមានឋានៈវណ្ណៈជាកម្មករបាន ។ អាហ្នឹងបានជាបដិវត្តន៍អនុញ្ញាតឲ្យខ្ញុំចូលជាបក្ខជននោះ ។

[១៣:៥២:២៨]

**ស៖** ក្នុងពេលដែលការប្រជុំជីវភាព ដែលយើងហៅថា ការប្រជុំស្វ័យតិទៀន និងតិទៀនផងដែរនោះ ។ ថាតើលោកឃើញគុណវិបត្តិយ៉ាងណាខ្លះ? គុណវិបត្តិដែលលោកមានអ្វីខ្លះ នៅពេលដែលលោកប្រជុំតិទៀនគ្នានោះ?

**ឆ៖** សូមជម្រាបសាសន៍លោក! នៅក្នុងការប្រជុំជីវភាព ខ្ញុំសង្កេតឃើញខ្លួនខ្ញុំវាមានវិបត្តិខ្លះ គឺវានៅជាប់កម្អែលនៃសង្គមចាស់ខ្លះ ដែលកម្ចាត់មិនទាន់អស់នៅឡើយ ។

**ស៖** នៅថ្ងៃនេះលោក ម៉ម ណៃ បានន័យថាសាមសិបឆ្នាំមកហើយ ថាតើលោកយល់អំពីរបបនោះយ៉ាងម៉េចនៅក្នុងជីវិតរបស់លោក?

**ឆ៖** សូមលោកមេធាវីបញ្ជាក់យល់អំពីរបបនោះ របបឥឡូវនេះ ឬក៏របបសម័យនោះ?

**ស៖** ខ្ញុំសួរលោកអំពីនៅថ្ងៃនេះ តើលោកយល់យ៉ាងម៉េចអំពីរបបកម្ពុជាប្រជាធិបតេយ្យ? តើលោកយល់យ៉ាងម៉េចដែរ ចំពោះរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅសម័យនោះចំពោះការរស់នៅវាទទួលនូវការអត់ឃ្លានអីចឹងហើយ គឺក្រោយពីធ្វើសង្គ្រាមហើយដែលខ្ញុំឃើញថា វាល្អមួយមកគំនិតមួយ គឺឯករាជ្យ ម្ចាស់ការ សមស្របនឹងខាងព្រះពុទ្ធសាសនាថា អត្តនោហិ និងអត្តាហិ អត្តនោនាថោ គឺខ្លួនទីពឹងខ្លួន ។ នេះជាទស្សនៈដែលល្អដែរ ។

**ស៖** តើលោកដឹងទេលោក ម៉ម ណៃ ថាតើមានមនុស្សប៉ុន្មានដែរ ដែលគេបានសម្លាប់ចោលនៅស-២១?

**ឆ៖** សូមជម្រាបលោកមេធាវី! ខ្ញុំគ្មានភារកិច្ច តួនាទីអីដឹងរឿងអស់នេះទេ ។

**ស៖** តើលោក ម៉ម ណៃ ដឹងដែរឬទេ មនុស្សប៉ុន្មាននាក់ដែរ ដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បញ្ហានេះក៏ខ្ញុំរឹតតែមិនដឹងតទៅទៀត ។

**ស៖** តើលោកមានការសោកស្ដាយដែរឬទេ ដែលលោកធ្លាប់ធ្វើជាអ្នកសួរចម្លើយនៅស-២១នោះ?

**ឆ៖** ខ្ញុំមិនយល់បញ្ហានេះទេ សូមលោកមេធាវីបញ្ជាក់ ។

**ស៖** ថាតើលោកមានការសោកស្ដាយ ឬក៏វិប្បដិសារីដែរឬទេ នៅថ្ងៃនេះ ដែលលោកធ្លាប់ជាអ្នកសួរចម្លើយនៅមន្ទីរស-២១?

[១៣:៥៨:០៩]

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ការមានការសោកស្ដាយនោះ វាមានការសោកស្ដាយខ្លះហើយ គឺមិនមែនអត់ទេ ។

**ស៖** តើលោកអាចបញ្ជាក់បន្ថែមទៅចំណុច ដែលលោកថាសោកស្ដាយនេះដែរឬទេ?

**ឆ៖** បញ្ហានេះខ្ញុំជឿជាក់ថា វាអាចមានអ្នកល្អខ្លះ ហើយក៏មានខុសខ្លះដែរ ក៏ប៉ុន្តែអ្នកល្អ តាមខ្ញុំវិភាគមានភាគតិចទេ មិនជាភាគច្រើនទេ ។ ដូច្នេះ ខ្ញុំសោកស្ដាយចំពោះអ្នកដែលភាគល្អ ភាគតិចនោះ ។ សូមជម្រាបលោកមេធាវី ។

**ស៖** បានន័យថា លោកមិនមានការសោកស្ដាយទេឬក៏យ៉ាងម៉េចចំពោះបុគ្គលដែលថា គេមិនសូវជាល្អ មិនមានកំហុសធ្ងន់ធ្ងរ ហើយត្រូវបានកម្ទេចចោលនោះ? តើនេះជាអ្វីដែលខ្ញុំយល់ពីលោក ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសោកស្ដាយចំពោះបុគ្គលល្អ ហើយនិងបុគ្គលមិនសូវល្អ ។ ឯបុគ្គលអាក្រក់ខ្ញុំមិនសោកស្ដាយទេ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកសាក្សី ។

សហព្រះរាជអាជ្ញា ខ្ញុំសូមអរគុណលោក ហើយបើសិនជាលោកមានសាក្សីប្រភេទនេះទៀតនោះខ្ញុំរីករាយណាស់ ដែលឲ្យលោកអញ្ជើញកោះមក ។

**ប្រធានអង្គជំនុំ៖**

ដំណើរការនៃការស្ដាប់សក្ខីកម្មសាក្សីឈ្មោះ ម៉ម ណៃ ហៅ ចាន់ ឃើញថាដល់ទីបំផុតហើយ។

ហើយភាគីមេធាវីការពារគាត់មានពេលនៅច្រើន ប៉ុន្តែគាត់អត់មានសំណួរសួរទៀតទេ។ ដូច្នេះ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោក ម៉ម ណៃ ដែលលោកបានចំណាយពេលវេលាអញ្ជើញចូលរួមនៅក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមការស្នើសុំរបស់--

ឥឡូវនេះ ដោយសារមានមតិយោបល់ថា អនុវត្តទៅតាមនីតិវិធីដែលធ្លាប់បានអនុវត្តមកហើយនូវការផ្តល់ការសង្កេត ឬការកត់សម្គាល់ពីជនជាប់ចោទនូវសក្ខីកម្ម ដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី ។

ដូច្នេះ ពេលនេះគឺខ្ញុំក៏យល់ស្របតាមយោបល់របស់ចៅក្រមមួយចំនួនដែលបានលើកឡើងពីបញ្ហានេះ ។ ទុកលទ្ធភាពជូនទៅជនជាប់ចោទដើម្បីធ្វើការសង្កេត ឬក៏កត់សម្គាល់ទៅលើសក្ខី កម្មដែលបានផ្តល់ដោយសាក្សី ម៉ម ណៃ កន្លងមកនេះ ។ ប្រសិនបើជនជាប់ចោទមាន អង្គជំនុំជម្រះអនុញ្ញាត។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ដំបូងខ្ញុំសូមជូនការចាប់អារម្មណ៍អំពីជីវិតឯកជនរបស់ខ្ញុំចំពោះ បង ម៉ម ណៃ ហើយនិងចំពោះមិត្ត ប៉ុន ដោយប្រៀបធៀបគ្នា ។ ខ្ញុំពិតជាធ្ងន់ទៅខាងមិត្ត ប៉ុន មែន ។ នេះជារឿងពិត។ សូមជូនឧទាហរណ៍ពីរ ។ ឧទាហរណ៍ទីមួយ គឺមុននឹងខ្ញុំសម្រេចដណ្តឹង មិត្តរុំ ជាប្រពន្ធខ្ញុំ ខ្ញុំសួរយោបល់មិត្ត ប៉ុន អត់មានបានសួរយោបល់បង ម៉ម ណៃ ទេ ។ ទីពីរក្រោយ ១៧ មេសា មួយរយៈខ្ញុំស្នើសុំ មិត្តរុំ រៀបការ ។ មិត្តរុំ គាត់មិនព្រម គាត់ចង់ពន្យារពេលម្ល៉ោះហើយមានការជជែកវែករវាងខ្ញុំទាំងពីរនាក់គូដណ្តឹងធ្វើឲ្យខ្ញុំអស់សង្ឃឹម បង ម៉ម ណៃ អត់ប៊ានថាអីឲ្យខ្ញុំទេ មានតែមិត្តប៉ុន ទេ ប៊ានចូលទៅជិតខ្ញុំ ហើយស្តីឲ្យខ្ញុំ ។ ថាបង ឌុច អើយឲ្យល្មម បងរុំ គាត់ជាកម្មាភិបាលម្នាក់ដែរ បងឯង មិនមើល មន្ទីរភូមិភាគពិសេសគេទៅភ្នំពេញអស់ហើយនៅតែយើងប៉ុន្មាននាក់ក្បាលមីងម៉ង់ៗ ហើយមិនជាស្លាប់ ឬរស់ ដោយអង្គការចាប់ ឬមិនចាប់? ឥឡូវបើ បងរុំ គាត់រៀបការជាមួយបងឯង លោតែគាត់មេម៉ាយ ឬក៏ស្លាប់ទាំងគាត់ទៀត បងឯងគិតយ៉ាងម៉េច? នេះបញ្ជាក់ឲ្យឃើញថាមិត្ត ប៉ុន គេប៊ានជាមួយនឹងខ្ញុំ ព្រោះខ្ញុំ គេស្គាល់ចិត្តខ្ញុំ ។ ឯចំណែក ខ្ញុំអត់បានជឿទុកចិត្តបង ម៉ម ណៃ ដល់ថ្នាក់បង ម៉ម ណៃ ប៊ានស្តីឲ្យខ្ញុំប៉ុណ្ណឹងទេ ។ មូលហេតុអី? សូមជម្រាបអង្គជំនុំជម្រះថា ខ្ញុំហើយនិង មិត្តប៉ុន ម្យ៉ាងកូនសិស្សកុដិលេខបីជាមួយគ្នា ម្យ៉ាងទៀតផ្ទះកំណើតខ្ញុំ ហើយនិងផ្ទះកំណើត មិត្តប៉ុន ចម្ងាយតែ២៥គីឡូពីគ្នាទេ ។ ហើយចេញទៅធ្វើបដិវត្តន៍ចុងក្រោយនេះ គឺចេញទៅនៅខាងតំបន់២៥ ខាងស្អាងកោះធំកំសត់កម្រជាមួយគ្នា ប៊ិះតែនឹងងាប់ទាំងពីរនាក់ ។

ហើយពេលចាប់ផ្តើមកសាងមន្ទីរ១៣ ខ្ញុំទាំងពីរនាក់ មិត្តប៉ុន ខំណាស់ ខ្ញុំឲ្យធ្វើអីក៏ធ្វើនុ៎ងដែរ ខំសួរខំអី ។ ឯចំណែកបង ម៉ម ណៃ ដូចគាត់បានបញ្ជាក់ជូនអង្គសវនាការហើយ ឆ្នាំ១៩៧៣ បានគាត់ទៅដល់នោះ ។ ខ្ញុំរុញការងារសួរឲ្យគាត់ ។ ខ្ញុំឃើញមិនជឿនលឿន ។ នេះមនោសញ្ចេតនាការងារក៏ធ្វើឲ្យខ្ញុំនេះដែរ ។ នេះខ្ញុំជម្រាបឲ្យត្រង់ ខ្ញុំពិតជាលម្អៀងទៅខាងមិត្ត ប៉ុន មែន ។ អត់ប្រកែកទេ ក៏ប៉ុន្តែក្រោយមកការអសមត្ថភាពរបស់ខ្ញុំធ្វើឲ្យគ្រួសារពីរគ្រួនេះស្លាប់អស់រលីង មិត្តប៉ុន ស្លាប់ទាំងខ្លួន ស្លាប់ទាំងប្រពន្ធ ស្លាប់ទាំងកូនពីរនាក់ បងម៉ម ណៃ អស់ប្រពន្ធ អស់កូនបួននាក់ ។ អាហ្នឹងវាទៅរឿងផ្សេងមួយទៀតទៅហើយ ។ ក៏ប៉ុន្តែសតិអារម្មណ៍មុនថ្ងៃ៧ មករា ជាពិសេសមុនឆ្នាំ១៩៧៩ ខ្ញុំធ្ងន់មិត្ត ប៉ុនជាង ។ ឥឡូវមិត្ត ប៉ុន គ្នាស្លាប់បាត់ទៅហើយ។ ដូច្នេះ គឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

បន្តទៅទៀតខ្ញុំសូមបញ្ជាក់ពីឯកសាររបស់បង ម៉ម ណៃ ដែលសល់ទុក ។ ខ្ញុំប្រើឯកសារនេះគ្រប់បែបយ៉ាង ។ ដំបូង គឺខ្ញុំឃើញនៅទំព័រមួយ គឺទំព័រ លេខ ERN00078012 វគ្គដែលខ្ញុំហើយនិងបងម៉ម ណៃ ទៅរៀននៅស្ពាតជាមួយលោកគ្រូ សុន សេន ទាំងពីរនាក់ គឺចាប់ផ្តើមនៅថ្ងៃទី២៤ ខែ៦ឆ្នាំ១៩៧៥ ។

ដូច្នេះ គ្រាន់តែឃើញពាក្យហ្នឹងវាកែអារម្មណ៍ខ្ញុំ ពីលើកមុនអារម្មណ៍ខ្ញុំ ខ្ញុំគិតថា ខ្ញុំមកភ្នំពេញថ្ងៃ២០ កក្កដា ដល់ឃើញវគ្គហ្នឹង ខ្ញុំកែអារម្មណ៍ខ្ញុំអស់រលីងទៅតាមឯកសារដែលមាន ។ ច្បាស់ណាស់ឯកសារវាបញ្ជាក់ស្អីៗច្បាស់ទាំងអស់ ។

ដូច្នេះបានឯកសារបង ម៉ម ណៃ មួយនេះ ខ្ញុំពន្យល់ស្អីៗបាន ច្រើនណាស់ ។ មាគ៌ាបក្សដែលបង សុន សេន ឧទ្ទេសនាមក៏នៅនុ៎ង មាគ៌ាបក្សដែលខ្ញុំឧទ្ទេសនាមនៅស-២១ ក៏នៅនុ៎ង ។ ដូច្នេះ នេះវាបញ្ជាក់ឲ្យឃើញថា យើងប្រើឯកសារនេះទៅតាម-- វាៗ-- តម្លៃឯកសារនេះវាមានតម្លៃជាប្រវត្តិសាស្ត្រសម្រាប់ ស-២១ យើងផង ហើយជាផ្នែកមួយនៃការងារបក្សផង ដើម្បីឲ្យយើងយល់បញ្ហានេះ ។

[១៤:០៨:៥៧]

បានថា ឯកសារនេះព្រឹកមិញបង មានប្រសាសន៍ថាមានតែអក្សរបង សុទ្ធសាធ តែតាមពិតមិនមែនទេ ។ នៅទំព័រ 00077978 មានអក្សរ ណាត នៅនុ៎ង ហើយប៉ុន្មានទំព័រតទៅទៀត មានអក្សរខ្ញុំពីរឿងសួរចម្លើយបន្តិច ។

សរុបមក គោលជំហរធ្វើការងាររបស់ខ្ញុំឥឡូវ ឲ្យតែឃើញអក្សរខ្ញុំ ឲ្យតែឃើញអក្សរបង ឲ្យតែឃើញអក្សរមិត្ត ហ៊ី ឲ្យតែឃើញអក្សរមិត្ត ប៉ុន ឲ្យតែឃើញអក្សរមិត្ត ហ៊ុយ ស្រែ ខ្ញុំទទួលស្គាល់ភ្លាម

ថា ឯកសារ ស-២១ ឥតប្រកែកទេ ក្រៅពីនោះយើងគិតគួរតទៅទៀត ។

ដូច្នេះ ជំហរដែលបងមានប្រសាសន៍ថា ហាក់ដូចជាអក្សរខ្ញុំ ជំហរនេះធ្វើឱ្យជាតិ ប្រជាជនកម្ពុជា យើងគេរើតម្លៃស្រាលចំពោះបង សូមបងរក្សាជំហរនេះឱ្យច្បាស់ ។ ស្អីដែលយើងធ្វើប៉ុន្មាននិយាយកុំខ្លាចងាប់ ងាប់ចោល ។ ទោសឧក្រិដ្ឋរបស់ខ្ញុំចំពោះជាតិប្រជាជនកម្ពុជាធំ ខ្ញុំទទួលទាំងអស់ក្នុង ស-២១ បងមានប្រសាសន៍ចុះកុំខ្លាច ។ យើងកែមិនបានទេ ដំរីស្លាប់កុំយកចង្អេរទៅបាំង នេះយើងយកសន្លឹកអំពិលពីរកូនសន្លឹកទៅបាំងម៉េចបាន កុំបាំង ឧក្រិដ្ឋកម្មរបស់ខ្ញុំទទួលបងមានប្រសាសន៍ចុះ ។

នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។ ទីមួយ អំពីស្មារតីមនុស្សធម៌ ដែលយើងត្រូវតែខំបំពាក់ឡើងវិញ ។ ខ្ញុំមិននិយាយវែងឆ្ងាយអំពី ស្មារតីមនុស្សធម៌ស្អីទេ យើងគិតមើលប្រជាជនកម្ពុជា ដែលបាត់បង់ជីវិតអស់ជាងមួយលាននាក់ តើស្នាដៃអ្នកណា? សតិអារម្មណ៍របស់ខ្ញុំឥឡូវ ខ្ញុំបញ្ចាំងទៅឃើញស្នាដៃរបស់បក្សកុម្មុយនីស្តកម្ពុជា ។ តើបក្សកុម្មុយនីស្តកម្ពុជាអ្នកណា? មានខ្ញុំ។ តាមពិតបងក៏ត្រូវទទួលស្គាល់ថាមានបងខ្លួនឯងដែរ យើងទទួលខុសត្រូវទាំងអស់គ្នាតាមផ្លូវចិត្តចំពោះការបាត់បង់អាយុជីវិតប្រជាជនយើង ទម្លាក់ទៅលើអ្នកណាអត់បានទេ ។ ហើយយើងអត់មានសិទ្ធិកែថា មាគ៌ានេះវាត្រូវទេ ។ មាគ៌ានេះយើងចម្លង បក្សយើង បងប៉ុល គាត់ចម្លងតាមអាក្រុមបួននាក់ យើងត្រូវទទួលស្គាល់បញ្ហានេះ ។ យកបញ្ហាចាស់មកនិយាយមិនបានទេ ខុសនឹងលោកទស្សនៈ យើងពីរនាក់មានលោកទស្សនៈមិនត្រូវគ្នាទេ ។ សូមបងពិនិត្យបញ្ហាលោកទស្សនៈនេះឡើងវិញ ។

ដោយឡែកចំពោះបុគ្គលម្នាក់ ខ្ញុំទទួលស្គាល់ហើយថា ការចងចាំរបស់បងអត់ជាងការចងចាំរបស់ខ្ញុំ ដូចពីរឿង ចៅ សេង ។ ចៅ សេង ខ្ញុំបានប្រាប់ មិត្តហ៊ី ឱ្យយកទៅនៅជាមួយនឹងបងកន្លែងស្នួរចម្លើយវៀតណាម ដើម្បីឱ្យគាត់មានឱកាសធាតុ មានអី យើងបានឧបត្ថម្ភ ។ ខ្ញុំច្បាស់ណាស់រឿងនេះ ខ្ញុំសូមលើកឧទាហរណ៍ ។ ថ្ងៃមួយនោះ ខ្ញុំនឹក ចៅ សេង ខ្ញុំទៅលេង ដល់ខ្ញុំទៅលេង ចៅ សេង គាត់ប្រាប្ធពីនរោត្តមសីហនុចេះបារាំងតិចជាងស្តេចនៅ បើតាមខ្ញុំចាំដូចអារ៉ាប៊ីសាអូឌីត ។ បង ចៅ សេង គាត់មានប្រសាសន៍ថា អ៊ូ! ស្តេចអារ៉ាប៊ីសាអូឌីត គេនិយាយមានបារាំង ហើយលាយឡាតាំងខ្លះ ស្អាតណាស់ ។ បងមានប្រសាសន៍ភ្លាម អ្ហឺ! ល្បល់យឯងឱ្យតែឡាតាំង ថាឱ្យលោក ចៅ សេង ល្បល់យឯង ។ អានេះវាជារឿងបង និងគ្រូរបស់បងទេ ប៉ុន្តែខ្ញុំរំឭករឿងនេះឡើងដើម្បីឱ្យដឹងថា ចៅ សេង ខ្ញុំពិតជាទុកនៅទុំង ។ ដល់ក្រោយមក ចៅ សេង ខាងលើគេឱ្យកម្ទេច ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេកម្ទេច ។ នេះរឿងដែលបងភ្លេច ។

[១៤:១២:៤០]

ក៏ប៉ុន្តែព្រឹកមិញ បងត្រូវមើលស្មារតីមនុស្សធម៌ ដែលយើងត្រូវបណ្តុះឲ្យមាននៅក្នុងខ្លួនយើង ។ និយាយពីសាស្ត្រាចារ្យ ភីង តុន យើងទាំងពីរនាក់សុទ្ធតែទទួលស្គាល់ថាសាស្ត្រាចារ្យ ភីង តុន ជាគ្រូរបស់យើង ។ ខ្ញុំអត់ទាន់និយាយអីវែងឆ្ងាយថាម៉េចបានជា ខ្ញុំស្រលាញ់សាស្ត្រាចារ្យ ភីង តុន ទេ ក៏ប៉ុន្តែខ្ញុំបានសរសេរជម្រាបអ្នកបងនេះ ដែលមានមុខនៅទីនេះ ហើយជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាបុត្រីច្បងរបស់លោកគ្រូ រឿងរ៉ាវហួរហែហើយខ្ញុំមិននិយាយទេ ។ ក៏ប៉ុន្តែ យើងធ្វើម៉េចខំបណ្តុះបណ្តាលមនោសញ្ចេតនារបស់យើងជួយរុករក តើយើងដឹងពីរឿងគាត់កម្រិតណា? សព្វថ្ងៃនេះសាកលលោកក៏ដូចប្រជាជនកម្ពុជា ជាពិសេសភាគីដើមបណ្តឹងរដ្ឋប្បវេណីវា ហាក់ដូចជាយើងឆ្លើយដាក់គ្នាទៅវិញទៅមក ។ ឥឡូវនេះ យើងខំគិតទាំងអស់គ្នាដើម្បីរកការពិតឲ្យឃើញថាយ៉ាងម៉េចរឿងគាត់? ខ្ញុំសូមបងរំឭកឡើងវិញមេត្តាជួយរករឿងគាត់ឲ្យច្បាស់ ។ នេះឥឡូវ ដើមបណ្តឹងរដ្ឋប្បវេណីនៅសង្ស័យយើង តើលោកគ្រូស្លាប់នៅឯណា? អត់ទាន់ច្បាស់ គាត់ចង់បានដឹងថា អដ្ឋិធាតុនៅឯណា? យើងជួយគាត់ទៅខ្ញុំបានជួយគាត់ខ្លះហើយ ឥឡូវយើងនាំគ្នាជួយគាត់តទៅទៀតទៅ រកឲ្យឃើញបញ្ហានេះ។ នេះហៅថាបណ្តុះមនោសញ្ចេតនាមនុស្សធម៌ឡើង ឲ្យឃើញថា យើងបានគិតគូរដល់ ខុសនិងត្រូវជាមនុស្សធម៌។ យើងយកលោកទស្សនៈកុម្មុយនីស្តមកបាំងមុខទៅមិនបានទេ ។ ជាតិប្រជាជនមិនអនុគ្រោះឲ្យយើងទេនេះសូមជម្រាប ។ បើថាជាតិប្រជាជនកម្ពុជាមិនអនុគ្រោះឲ្យយើងហើយ អង្គសវនាការនេះក៏គេអត់អនុគ្រោះឲ្យបងដែរ ។ សូមបងមានប្រសាសន៍ទៅ កុំខ្លាច ឲ្យបានត្រង់ ស្តាប់ចោល នេះឧត្តមគតិរបស់ខ្ញុំនៅពេលនេះ ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ សូមគោរពបង សូមគោរពអង្គសវនាការ។

**ប្រធានអង្គជំនុំ៖**

ចង់មានបញ្ហាអីទៅមេធាវី?

[១៤:១៥:០០]

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមៗចាត់ទុកថា សេចក្តីសង្កេតរបស់ជនជាប់ចោទ សូមឲ្យអនុញ្ញាតឲ្យប្រគល់ឲ្យសាក្សីគាត់ស្តាប់សម្តី ហើយតើសាក្សីគាត់មតិម៉េច? ហើយៗទាក់ទងទៅនឹងប្រពន្ធនិងកូនរបស់លោកគ្រូ ភីង តុន ប្រហែលជាសាក្សីអាចនឹងកែប្រែចិត្ត អាចនឹងៗឆ្លើយដោយស្មោះត្រង់ចំពោះលោកសាស្ត្រាចារ្យ ភីង តុន ដូចដែលខុសពីមុន ដែលគាត់ឆ្លើយ ។ អ៊ីចឹងដែលថាលោកនៅចំពោះ

មុខអង្គជំនុំជម្រះហើយ ដូច្នេះហើយសូមឲ្យអង្គជំនុំជម្រះផ្តល់ឱកាសបន្តិចជូនសាក្សី បើសិនជាគាត់ចង់សម្តែងមតិត្រង់ចំណុចនេះ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោក ម៉ម ណៃ បន្ទាប់ពីស្តាប់នូវការកំណត់សម្គាល់របស់ជនជាប់ចោទនូវការផ្តល់សក្ខីកម្មរបស់លោកចំពោះមុខអង្គជំនុំជម្រះដែលលោកបានស្តាប់រួចហើយនេះ សួរថាតើលោកចង់មានយោបល់អ្វីផ្សេងទៀតទេ ពាក់ព័ន្ធជាមួយនឹងអង្គហេតុទូទៅដែលកើតឡើងនៅមន្ទីរសន្តិសុខស-២១ និយាយរួមហើយដោយឡែក គឺមានការពាក់ព័ន្ធជាមួយសាស្ត្រាចារ្យមហាបរិញ្ញាឈ្មោះ ភឹង តុន នោះដែលសវនាការលើកនេះ គឺមានការសង្កត់ធ្ងន់ពាក់ព័ន្ធទៅនឹងរូបខ្លួនគាត់ គឺសាស្ត្រាចារ្យមហាបរិញ្ញា ភឹង តុន ។

**លោក ម៉ម ណៃ៖**

សូមគោរពលោកប្រធាន ខ្ញុំសូមមានមតិដូចតទៅ៖ ខ្ញុំសូមថ្លែងនូវសេចក្តីសោកស្តាយចំពោះគ្រួសារលោក ភឹង តុន ជាពន្លឹក ហើយបើតាមខ្ញុំដឹង គឺគ្រួសារលោក ភឹង តុន គឺជាកូនធម៌ គឺជាកូនបង្កើតរបស់ឪពុកធម៌ខ្ញុំ គឺលោក តាទុយ ។

**លោក គង់ សំអុន៖**

លោកប្រធានសូមអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក គង់ សំអុន៖**

លោកប្រធានសូមអនុញ្ញាតឲ្យសាក្សីសម្រាកបានបន្តិច ដើម្បីសម្រួលអារម្មណ៍ ។

សូមអរគុណ ។

[១៤:១៨:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រាក ហើយកំពុងតែអង្គុយស្តាប់មើលគាត់ហ្នឹងហើយ អត់ប៉ានប្រកាសសម្រាក ។ សម្រាកទៅវាទៅអស់ពេលជាច្រើន បង្អង់ដើម្បីឲ្យគាត់មានលទ្ធភាពអាចបន្តបានអត់ ព្រោះនេះជាការក្តុកក្តួលអារម្មណ៍របស់គាត់ ។

**លោក ម៉ម ណៃ៖**

សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តទៅទៀត! បញ្ហានេះខ្ញុំសោកស្តាយ នេះម្យ៉ាង ។ ម្យ៉ាងទៀតគឺជាទូទៅក៏ខ្ញុំសោកស្តាយដែរ សូម្បីតែបងប្អូនបង្កើតរបស់ខ្ញុំក៏ស្លាប់ដែរ ។ បងប្អូនប្រុសៗ ក៏ត្រូវរងគ្រោះនៅពេលនោះដែរ រងទាំងកូន ទាំងប្រពន្ធ នេះជា គេហៅថា កោលាហល អាពេលហ្នឹងវាអ៊ីចឹងយើងគ្រាន់តែមានសេចក្តីសោកស្តាយតែប៉ុណ្ណឹងទេ មិនដឹងទៅធ្វើម៉េចទៀត ។ ទាំងរូបខ្ញុំ ទាំងគាត់ហ្នឹងចំពោះប្រជាជនទូទៅក៏វាមានការបាត់បង់ ដូច្នេះវាមានការសោកស្តាយទាំងអស់គ្នាទេ ហើយបើនិយាយតាមសាសនាវិញ គឺថាធ្វើម៉េចផលកម្មយើង វាអ៊ីចឹង ។ នេះខ្ញុំផ្អែកទៅលើ សព្វថ្ងៃអាកាត់ចិត្ត គឺផ្អែកទៅលើសាសនា ទៅលើផលកម្ម ការសោកស្តាយចេះតែមានហើយ នេះសូមលោកប្រធានជ្រាប ហើយសុំលោកស្រីរបស់លោក ភឹង តុន សូមជ្រាប ។

**ប្រធានអង្គជំនុំ៖**

បញ្ហាដែលមានការបន្តឆ្លល់នេះ តាមខ្ញុំស្តាប់ទៅ គឺសំណួរហ្នឹងចង់សួរថាតើលោកម៉ម ណៃ មានព័ត៌មានអ្វី ច្រើនជាងអ្វីដែលលោកបានផ្តល់រួចហើយ ពាក់ព័ន្ធជាមួយនឹងបុគ្គលរបស់ឈ្មោះ ភឹង តុន នៃជោគវាសនារបស់គាត់នៅក្នុងមន្ទីរស-២១ នោះដែរឬទេ? បានន័យថា ដឹងលើសពីអ្វីដែលលោកបានធ្វើសក្ខីកម្មនូវច្រើនសំណួរដែលពាក់ព័ន្ធជាមួយនឹង ភឹង តុន នេះ សួរថា តើមានតែប៉ុណ្ណឹងទេ ឬក៏មានព័ត៌មានអាចលើសពីនេះ? ក្រែងលោលោកលាក់ក្នុងចិត្ត ហើយនិយាយមិនទាន់បាននិយាយមកអស់ ក្រោយពេលដែលលោកបានស្តាប់នូវការកត់សម្គាល់នូវសម្តីរបស់ជនជាប់ចោទ តើលោកមានអ្វីដែលចង់និយាយបន្ថែមទៀតទេ ឬក៏មានអ្វីប្រហែល-- ប្រហាក់ប្រហែលនឹងអ្វីដែលលោកបាននិយាយរួចហើយ តែប៉ុណ្ណោះទេ?

**លោក ម៉ម ណៃ៖**

សូមជម្រាបលោកប្រធាន! ខ្ញុំមានតែដូចធាតុពិតនៃការសន្និដ្ឋានរបស់ខ្ញុំពេលនោះអ៊ីចឹង ខ្ញុំសន្និដ្ឋានប៉ុណ្ណឹង គឺខ្ញុំប៉ានណាស់ហើយ ដើម្បីរកយុត្តិធម៌នៅពេលនោះ ។ ឯការដែលដឹងស៊ីតទៅ ទៀតហ្នឹងគឺខ្ញុំបាទដូចយប់អ៊ីចឹង វាចប់ត្រឹមពីក្រោយសន្និដ្ឋានហ្នឹង គឺគ្មានអីដឹងតទៅទៀតទេ សូមលោកជ្រាប ។

**ប្រធានអង្គជំនុំ៖**

អរគុណ អ៊ំ ម៉ម ណៃ ជាថ្មីម្តងទៀត ដែលអ៊ំបានលះបង់ពេលវេលាមកចូលរួមផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏បានដឹងផងដែរថា វាជាការលំបាកណាស់

សម្រាប់ខ្លួនអ៊ំផ្ទាល់ដែលមកធ្វើសក្ខីកម្មនេះ ដោយប្រឈមទៅនឹងសំណួរជាច្រើនពីអង្គជំនុំជម្រះ និងភាគីនានា ហើយក្រៅពីនោះ គឺនៅមានបញ្ហាលំបាកជាច្រើនទៀតដូចជាពេលវេលានៃហេតុការណ៍នោះវាកើតឡើង បើគិតទៅជាងសាមសិបឆ្នាំហើយ ។ បើគិតត្រឹម១៩៧៩ សាមសិបឆ្នាំ បើគិតតាំងពី១៩៧៥ មកវា សាមសិបបួនឆ្នាំ សាមសិបបីឆ្នាំមកហើយ ហើយជាការចងចាំរបស់មនុស្សមានកម្រិត ហើយមិនបានល្អិតល្អន់ សូម្បីតែភ្លាមៗហ្នឹង បើសិនជាយើងនិយាយឲ្យបានល្អិតល្អន់នោះក៏ជាការលំបាកផង វាអាស្រ័យទៅលើសមត្ថភាពយល់ដឹងរបស់មនុស្សផងដែរ ។ ហើយមួយទៀត គឺការលំបាកផងដែរនោះ គឺអ៊ំមានវ័យចំណាស់រហូតដល់៧៦ឆ្នាំ អ៊ីចឹងការចង់ចាំរបស់មនុស្សហ្នឹង គឺកាលបើវ័យកាន់តែចាស់ ក៏បញ្ហាការចងចាំក៏កាន់តែមានការបាត់បង់ដែរ ។ ទោះបីយ៉ាងណាក៏ដោយ គឺអង្គជំនុំជម្រះនៅតែអរគុណរបស់អ៊ំដែលបានអញ្ជើញមកនេះ ។

ហើយឥឡូវនេះការសួរដេញដោលចំពោះអ៊ំ ក្នុងនាមអ៊ំជាសាក្សីនៅក្នុងរឿងក្ដីនេះ គឺបានទីបញ្ចប់ហើយ ។ សុំអ៊ំត្រឡប់ទៅវិញ ទៅផ្ទះវិញចុះ មន្ត្រីតុលាការសម្របសម្រួលជូនលោក ម៉ម ណៃ ទៅទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សីជំនាញ-- សាក្សី និងអ្នកជំនាញ ដើម្បីឲ្យសម្របសម្រួលរៀបចំជូនគាត់ទៅកាន់លំនៅស្ថានរបស់គាត់វិញ ហើយឲ្យអញ្ជើញសាក្សី ហ៊ឹម ហ៊ុយ ចូលមកកាន់សាលសវនាការ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ក្នុងករណីដែលសាក្សីកំពុងក្នុងអន្តរកាល ខ្ញុំសូមជូនមតិដោយសង្ខេប គឺថាអាចនឹងៗធ្វើឲ្យសាធារណជនយល់ច្រឡំពីនីតិវិធីរបស់អ.វ.ត.ក មេធាវីបានបញ្ជាក់ពីខាងដើមថា ស្នើសុំឲ្យសហព្រះរាជអាជ្ញាអញ្ជើញសាក្សី ប៉ុន្តែការពិតសហព្រះរាជអាជ្ញាមិនមែនជាអ្នកកោះហៅសាក្សីទេ គឺអង្គជំនុំជម្រះជាអ្នកកោះហៅសាក្សីតាមវិធាន១៨០ស្ទួន ។ នេះហើយជាការគ្រប់គ្រងដោយយុត្តិធម៌ដែលត្រឹមត្រូវ នេះគឺមិនមែនជាប្រព័ន្ធខំមិនឡូទេ ជាប្រព័ន្ធស៊ីវិលឡហើយខាងមេធាវីការពារយល់ច្បាស់ណាស់ ដែលថាសេចក្ដីសម្រេច នេះជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទេ ក្នុងការកោះអញ្ជើញសាក្សី ដើម្បីឲ្យសាធារណជនយល់ផង ។ ប៉ុន្តែ យើងនៅក្នុងសាលសវនាការ យើងយល់ទាំងអស់គ្នា ប៉ុន្តែសាធារណជនមិនទាន់ជ្រាបបញ្ហានោះទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់របស់លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ សូមអញ្ជើញ

លោកមេធាវី ហ្រ្វង់ស្វ័រ រូ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ដែលបានផ្ដល់ព័ត៌មានបន្ថែម ។ សហព្រះរាជអាជ្ញាបានផ្ដល់ព័ត៌មានដល់សាធារណជន លោកគួរតែបន្ថែមថាអង្គជំនុំជម្រះកោះអញ្ជើញសាក្សីតាមសំណើរបស់ភាគីនីមួយៗ។ លោកបានរៀបចំបញ្ជីសាក្សីនោះ ហើយលោកបានដាក់ជូនទៅអង្គជំនុំជម្រះ ហើយមេធាវីការពារក៏បានបញ្ជីរាយឈ្មោះសាក្សីក៏បានដាក់ជូនទៅអង្គជំនុំជម្រះ ។ នេះជាការត្រឹមត្រូវដើម្បីនិយាយថា តាមសំណើរបស់ភាគីនីមួយៗអង្គជំនុំជម្រះកោះអញ្ជើញសាក្សី ប៉ុន្តែលោកបានស្នើបញ្ជីសាក្សីដែរ ហើយដែលសាក្សីដែលទើបតែបានបង្ហាញខ្លួនមកនេះ ។

ហើយលោកប្រធាន ដោយថាយើងមានសាក្សី ពីរនៅក្នុងចន្លោះពេលហ្នឹង ខ្ញុំសុំសម្ដែងការព្រួយបារម្ភខ្ញុំជាបន្តទៅទៀត ពីព្រោះថា យើងបានព័ត៌មានមួយដែលថាសាក្សី ដែលនឹងមកបន្ទាប់នេះ ដោយមានព័ត៌មានថា ផ្ដល់ព័ត៌មាននេះរួចទៅហើយ ។ ហើយខ្ញុំចង់លើកពីបញ្ហាមួយ អំពីការឆ្លើយដាក់បន្ទុកដោយខ្លួនឯង គឺថាមិនមែនត្រឹមតែប៉ុណ្ណឹងទេ ទាក់ទងតែនឹងបញ្ហាសហកម្ម ឧក្រិដ្ឋកម្មរួមប៉ុណ្ណោះទេ ។ ប៉ុន្តែ ខ្ញុំយល់ថា ខ្ញុំឃើញថាវាមានការលំបាកណាស់នៅពេលសាក្សីមិនបានផ្ដល់ព័ត៌មានអំពីស្ថានភាពនោះ។ អ៊ីចឹងអង្គជំនុំជម្រះនឹងពិចារណាបញ្ហានេះ ហើយមេធាវីក៏មានការទទួលខុសត្រូវគប្បីតែណែនាំដល់សាក្សីនេះ ហើយសហព្រះរាជអាជ្ញាបានលើកឡើងថា គប្បីតែកែតម្រូវ ហើយក៏មិនមែនជាការត្រឹមត្រូវនិយាយដូច្នោះទេ ដែលថា ដោយការរៀបរាប់បែបនោះ គឺមិនពិតទេ ។ លោកមិនគប្បីអនុញ្ញាតឲ្យមានវិមតិសង្ស័យ ការសង្ស័យជាបន្តនោះទេ ហើយមិនអាចនិយាយរឿងពីរដែលផ្ទុយគ្នាក្នុងពេលតែមួយនោះបានទេ ។

[១៤:២៩:៥៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ វេទិកានេះអង្គជំនុំជម្រះស្ដាប់ចម្លើយសាក្សី មិនមែនវេទិកាអង្គជំនុំជម្រះឲ្យភាគីមកតតាំងគ្នាហ្នឹងគ្នាទេ ។ ក្នុងករណី ភាគីដែលចង់មានបំណងជាក់លាក់ណាមួយអំពីនីតិវិធីនៃការស្ដាប់សាក្សីពិសេសរបៀបនេះ សុំភាគីដាក់សំណើជាក់លាក់មកអង្គជំនុំជម្រះជាមុន ដើម្បីអង្គជំនុំជម្រះពិចារណាមើល ថាតើគួរដោះស្រាយនីតិវិធីនៃការអនុវត្តវិធាន២៨ នោះតាមរបៀបណា? ត្រូវបើកកិច្ចប្រជុំជាសម្ងាត់និយាយរបៀបណា? ដើម្បីជាប្រយោជន៍នៅក្នុងការអនុវត្តវិធាន២៨ ក្នុងការស្ដាប់នូវ

ចម្លើយសាក្សីនោះឲ្យបានច្បាស់លាស់ ។ យើងមិនយល់ច្រឡំទេ ជាបុគ្គលយើងកត់សម្គាល់ឃើញថា មេធាវីសុទ្ធតែកេងចំណេញអំពីវេទិកានេះ ។ ចង់បានព័ត៌មានពិតត្រឹមត្រូវពីសាក្សី ប៉ុន្តែបង្ហើប និងលើកម្តងហើយម្តងទៀត នូវសិទ្ធិមិនឆ្លើយនឹងសំណួរទាំងឡាយដែលនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង វាផ្ទុយគ្នា បើកសិទ្ធិក្នុងការមិនឆ្លើយពិរុទ្ធភាពលើខ្លួនឯងកាន់តែច្រើន ការនិយាយពិតរបស់សាក្សីក៏ថយទៅតាមនោះដែរ ។ បើសិទ្ធិនោះមែនទែនអស់ គឺសាក្សីមានសិទ្ធិមិនឆ្លើយបាន ។

អ៊ីចឹង ពេលនេះសាក្សីមិនទាន់បានកោះហៅចូលទេ ភាគីអាចដាក់សំណើជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់ ពីព្រោះការប្រជុំត្រៀមរៀបចំសវនាការភាគីមិនបានលើកអំពីបញ្ហានេះមកដល់អង្គជំនុំជម្រះ ដើម្បីធ្វើការបើកកិច្ចប្រជុំពិភាក្សានោះទេ ។ កិច្ចការនេះ គឺជាកិច្ចការត្រៀមរៀបចំសវនាការដែលត្រូវធ្វើជាសម្ងាត់ មិនមែនធ្វើជាសាធារណៈ ឲ្យសាធារណជនស្តាប់អំពីបញ្ហាបច្ចេកទេសក្នុងការប្រព្រឹត្តិទៅនោះឡើយ ។

ឥឡូវសួរថាតើ ភាគីតំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីនៅតែប៉ុនប៉ងលើបញ្ហានេះទេ ឬក៏គ្រាន់តែជាកេងចំណេញនៅក្នុងដំណើរការនីតិវិធីសវនាការតែប៉ុណ្ណោះ នេះនិយាយគ្នាឲ្យច្បាស់។

**លោក វីលៀម ស្មឹត៖**

សូមគោរពលោកប្រធាន លោកចៅក្រម គឺថាមានចំណុចមួយដែលជាការព្រួយបារម្ភរបស់លោកចៅក្រម ដូចជាការព្រួយបារម្ភរបស់សហព្រះរាជអាជ្ញាដែរ ប្រសិនបើបញ្ហានេះលើកឡើងម្តងហើយម្តងទៀត បើសិនជាគាត់លើក លើកឡើងតាមវិធាន២៨.៨ ហើយគប្បីតែលើកបញ្ហានោះក្នុងសវនាការអសាធារណៈ មិនគប្បីមេធាវីការពារលើកឡើងជាលើកទីពីរ ទីបីនោះទេ ហើយបើសិនជាចង់លើកបញ្ហានោះ គឺគប្បីលើកក្នុងសវនាការអសាធារណៈ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីមានអីទេ ឥឡូវហ្នឹងនិយាយគ្នាឲ្យអស់កុំឲ្យវាមានបញ្ហាទៀត ពីព្រោះវាត្រូវធ្វើដំណើរទៅច្រើននាក់ទៀតណ៎ា មិនមែនធ្វើម្នាក់ហើយបង្កើតបញ្ហា ម្នាក់ហើយបង្កើតបញ្ហានោះទេ និយាយឲ្យច្បាស់លាស់ ។

[១៤:៣៣:៤៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំបាននិយាយហើយអ្វីដែលខ្ញុំបាននិយាយ ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជ

អាជ្ញាជាតិបានលើកឡើងជាសាធារណៈព្រឹកមិញនេះ ហើយក៏ខ្ញុំបានឆ្លើយតបជូនគាត់ជាសាធារណៈនោះដែរ ហើយប្រសិនបើអង្គជំនុំជម្រះមានបំណងធ្វើដូច្នោះ គឺយើងខ្ញុំក៏ចង់ចូលរួមនៅក្នុងសវនាការដេញដោលជាអសាធារណៈផងដែរ ដោយសារតែបញ្ហានេះវាផ្អែកទៅលើជំហររបស់សហព្រះរាជអាជ្ញាថាតើសហព្រះរាជអាជ្ញានៅតែរក្សាជំហរទៅលើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមដែរ ឬក៏យ៉ាងម៉េច?

**លោក វីលៀម ស្មឺត៖**

សាជាថ្មីម្តងទៀត លោក លោកស្រីចៅក្រម មេធាវីការពារក្តី គាត់យល់ច្រឡំហើយ គឺទាក់ទងសហកម្មឧក្រិដ្ឋកម្ម គឺគ្មានអ្វីពាក់ព័ន្ធទៅនឹងការឆ្លើយដាក់បន្ទុកខ្លួនឯងនោះទេ ។ ដូច្នេះហើយ គឺខ្ញុំសូមបញ្ជាក់ត្រឹមនេះ ចំពោះសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចនីតិវិធីសវនាការលើសាក្សី KW-09 ហើយមន្ត្រីតុលាការកុំអាលឲ្យគាត់អញ្ជើញមកដល់ពេលម៉ោងចាំ រង់ចាំបញ្ជាពីខ្ញុំសឹមអញ្ជើញគាត់ចូលបន្ទប់សវនាការ ។

*[សវនាការសម្រាកពីម៉ោង ១៤:៣៧នាទី ដល់ម៉ោង ១៥:១០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះគម្រោងនឹងស្តាប់សក្ខីកម្មសាក្សី KW-09 ឈ្មោះ ហ៊ឹម ហ៊ុយ ។ មុននឹងកោះអញ្ជើញសាក្សីចូលក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសូមជម្រាបដល់ភាគី និងសាធារណជនឲ្យបានជ្រាបអំពីបញ្ហាដែលកើតមានកន្លងមកនេះ ។ ទីមួយ កិច្ចធានាដែលបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាជាតិកាលពីព្រឹកមិញ គឺវាមិនមែនជាការត្រឹមត្រូវទេ ដោយហេតុការលើកឡើងនូវកិច្ចធានានោះមិនត្រូវកាលៈទេសៈ និងមិនទាន់មានការស្នើសុំពីសាក្សីដែលត្រូវផ្តល់សក្ខីកម្ម និងការស្នើសុំពីអង្គជំនុំជម្រះឲ្យសហព្រះរាជអាជ្ញាធ្វើកិច្ចធានាមុននឹងសាក្សីឡើងផ្តល់សក្ខីកម្ម ។

ទីពីរ ការឆ្លើយតបរបស់មេធាវីការពារអន្តរជាតិ ហ្វ្រង់ស្វ័រ រូ ជាមេធាវីការពារក្តី និងកិច្ចធានា

តំណាងដោយសហព្រះរាជអាជ្ញាជាតិ របស់តំណាងសហព្រះរាជអាជ្ញា ដែលបានលើកឡើងពាក់ព័ន្ធនឹងបញ្ហានោះក៏ជាការមិនត្រឹមត្រូវដែរ ។ បញ្ហាមួយទៀត ដែលមេធាវីការពារក្តីអន្តរជាតិតែងតែលើកឡើងភ្ជាប់នឹងបញ្ហានៅក្នុងដំណើរការនៃសវនាការនេះ គឺសហកម្មឧក្រិដ្ឋកម្មរួម ដែលសហព្រះរាជអាជ្ញាបានលើកឡើង ក៏មិនទាន់មានការពាក់ព័ន្ធនឹងបញ្ហាសវនាការស្តាប់សាក្សីនេះដែរ ។ ដូច្នេះ អង្គជំនុំជម្រះសូមជម្រាបសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីថា មិនឲ្យលើកបញ្ហានេះទៀតទេនៅក្នុងអំឡុងពេលស្តាប់ចម្លើយសាក្សីនេះ ។

ចំណុចទីបី ចំពោះសាក្សីឈ្មោះ ម៉ម ណៃ ហៅ ចាន់ ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់គាត់កន្លងមកនេះ អង្គជំនុំជម្រះសូមជម្រាបដល់សាធារណជនថា សាក្សីរូបនេះ គឺអង្គជំនុំជម្រះបានសម្រេចកោះហៅគាត់មកផ្តល់សក្ខីកម្ម គាត់មិនមែនជាសាក្សីរបស់ភាគីណាមួយនៃរឿងក្តីនេះឡើយ ។

មន្ត្រីតុលាការអញ្ជើញសាក្សី ហ៊ឹម ហ៊ុយ ចូលមកកាន់សាលសវនាការ ។

*[សាក្សីចូលមកកាន់សវនាការ]*

[១៥:១៧:២៣]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី តើលោកឈ្មោះអ្វី?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ, ខ្ញុំឈ្មោះ ហ៊ឹម ហ៊ុយ ។

**ស៖** ហ៊ុម ហ៊ុយ ឬក៏ ហ៊ឹម ហ៊ុយ?

លោករង់ចាំៗឲ្យមានភ្លើងក្រហមនៅក្បាលមេក្រូនេះ ក្បាលមេក្រូភ្លើងនេះ សឹមលោកចាប់ផ្តើមនិយាយ ដើម្បីឲ្យបានស្តាប់ឮទាំងអស់គ្នា និងមានការបកប្រែ និងកត់ត្រាក្នុងប្រតិចារឹក ក្នុងកំណត់ហេតុសវនាការផង ។ លោកឈ្មោះ ហ៊ុម ហ៊ុយ ឬក៏ឈ្មោះ ហ៊ឹម ហ៊ុយ?

**ឆ៖** បាទ, ខ្ញុំឈ្មោះ ហ៊ឹម ហ៊ុយ ។

**ស៖** លោកមានឈ្មោះហៅក្រៅដែរឬទេ ក្រៅពីឈ្មោះ ហ៊ុយ?

**ឆ៖** បាទ, ខ្ញុំមានឈ្មោះ ពីមុនមកដាក់ គេឲ្យដាក់ជីតាឈ្មោះ យូ ហ៊ុយ ។

**ស៖** ឈ្មោះ យូ ហ៊ុយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ៥៤ឆ្នាំ ។

**ស៖** លោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំនៅភូមិអន្លង់សាន ឃុំព្រែកស្តី ស្រុកកោះធំ ។ របររកស៊ីធ្វើស្រែចម្ការ ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានជាប់ចំណងជាញាតិលោហិត ញាតិព័ន្ធ ឬក៏សហព័ទ្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ហើយលោកមុននឹងចូលបន្ទប់សវនាការនេះ បានស្បថចំពោះមុខអ្នកតានៅទីនេះរួចហើយ ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ,ជាការពិត ។

**ស៖** នៅក្នុងនីតិវិធីនៃការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញនាពេលនេះ លោក ហ៊ីម ហ៊ុយ លោកមានករណីកិច្ចនិយាយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ ។ អំពីសិទ្ធិក្នុងនាមលោកជាសាក្សីលោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យធ្វើអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើកខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ មានន័យថា ដោយសារតែចម្លើយ ឬសេចក្តីអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់ តើលោកយល់អំពីសិទ្ធិនេះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំយល់ ។

[១៥:២១:៣៦]

**ស៖** នៅក្នុងវិធាន២៨.៩ ប្រសិនបើបញ្ហាណាមួយនៃការដាក់ពិរុទ្ធភាពដែលអាចកើតមាននោះ គឺសាក្សីអាចស្នើមេធាវីមួយរូបឲ្យជួយប្រឹក្សាយោបល់ ។ សំណួរនាពេលនេះសួរថា តើលោកត្រូវការសាក្សីក្នុងការប្រឹក្សាយោបល់របស់លោក ក្នុងករណីជួបប្រទះទៅនឹងសំណួរណាមួយដែលលោកមានការបារម្ភមុននឹងឆ្លើយក្រែងលោថា អាចដាក់ពិរុទ្ធភាពលើកខ្លួនឯងដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ។

**ស៖** តាមវិធានច្បាប់នេះ គឺក្នុងករណីដែលលោកជួបប្រទះនឹងបញ្ហាណាមួយដែលអាចនាំឲ្យចម្លើយរបស់លោក ឬសេចក្តីអះអាងរបស់លោកហ្នឹង ដាក់ពិរុទ្ធភាពលើខ្លួនឯង នោះលោកអាចស្នើសុំឲ្យមានមេធាវីជំនួយប្រឹក្សារបស់លោកក្នុងបញ្ហានេះ ។ សួរថា តើលោកត្រូវការមេធាវីដែរឬទេ? ឬក៏លោកមានមេធាវីរួចហើយសម្រាប់ការឆ្លើយ-- ការផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ, ខ្ញុំអត់ទាន់មានមេធាវី ដើម្បីជួយខ្ញុំនៅឡើយទេ ។

**ស៖** តើលោកត្រូវការមេធាវីដើម្បីជួយលោកនៅក្នុងការប្រឹក្សាយោបល់នៅក្នុងអំឡុងពេលដែលលោកនឹងឆ្លើយនឹងសំណួរផ្សេងៗ ដោយអង្គជំនុំជម្រះ ឬក៏ដោយភាគីនៅក្នុងការសួរ-- ស្តាប់សក្ខីកម្មរបស់លោកនៅក្នុងអំឡុងពេលថ្ងៃនេះ និងថ្ងៃស្អែកដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមធ្វើការពិភាក្សាជាមួយមេធាវីសិន បានខ្ញុំនិយាយបាន ។

**ស៖** អ៊ីចឹងបានន័យថា លោកមិនមានមេធាវីទេ ហើយលោកសុំឱ្យអង្គជំនុំជម្រះចាត់តាំងមេធាវីមួយរូបឱ្យលោក ដើម្បីជួយលោកនៅក្នុងការប្រឹក្សាយោបល់នៅក្នុងអំឡុងពេលដែលលោកនឹងធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរហូតដល់ពេលចប់ ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** ខ្ញុំបានទទួលព័ត៌មានពីលោកស្រីចៅក្រមថា តាមគាត់ក្តាប់លោកមានមេធាវី-- លោកធ្លាប់បានប្រឹក្សាយោបល់ជាមួយនឹងមេធាវីរួចហើយកន្លងមកនេះ នៅពេលដែលលោកដឹងថា លោកត្រូវបានអង្គជំនុំជម្រះកោះហៅលោកមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ តើរឿងនេះពិតទេ? តើលោកធ្លាប់បានប្រឹក្សាយោបល់ជាមួយនឹងមេធាវីហើយឬនៅ? ហើយមេធាវីដែលលោកប្រឹក្សានោះឈ្មោះអ្វីដែរ? ហើយប្រឹក្សាពីពេលណាមក?

**ឆ៖** បាទ, ខ្ញុំជួបជាមួយគាត់ ឈ្មោះលោក គង់ សំអុន នោះ ។ គ្រាន់តែបានជួបតែមួយភ្លែតទេ ។

[១៥:២៦:00]

**ស៖** អ៊ីចឹងបានន័យថា លោកបានជួបលោកមេធាវី គង់ សំអុន រួចហើយ ហើយបានមានការទំនាក់ទំនងគ្នាថា លោកពឹងគាត់ ដើម្បីឱ្យគាត់ធ្វើជាមេធាវីជួយលោកក្នុងការប្រឹក្សាយោបល់នៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មនៅចំពោះមុខ-- ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះទេ?

**ឆ៖** ខ្ញុំមិនទាន់និយាយកើតទេ ។

**ស៖** អ៊ីចឹងលោកសំណូមពរយ៉ាងម៉េចទៅឥឡូវនេះ?

**ឆ៖** ខ្ញុំសូមទំនាក់ទំនងជាមួយគាត់សិន ។

**ប្រធានអង្គជំនុំ៖**

ដោយសារនៅថ្ងៃនេះ កាលវិភាគនៃដំណើរការសវនាការត្រូវស្តាប់សក្ខីកម្មសាក្សីឈ្មោះ ហ៊ឹម ហ៊ុយ ប៉ុន្តែនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ គាត់ត្រូវការមេធាវី ហើយមេធាវីដែលជួយគាត់ ជួយ

ប្រឹក្សាយោបល់គាត់នោះ គឺគាត់ទើបតែបានជួប ហើយមិនទាន់ប្រឹក្សាយោបល់ឲ្យបានស៊ីជម្រៅ ថាគាត់ត្រូវធ្វើរបៀបណានៅឡើយទេ ។ ហើយចំពោះមុខអង្គជំនុំជម្រះនេះ សាក្សីរូបនេះក៏បានស្នើសុំថា ជួបមេធាវីគាត់សិន ប្រឹក្សាយោបល់ជាមុនសិន មុននឹងផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចដំណើរការស្តាប់សក្ខីកម្មរបស់សាក្សីនេះតទៅទៀតបានទេ ។ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ដេញដោលសាក្សីរូបនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ ។

មន្ត្រីតុលាការសម្របសម្រួលសាក្សីរូបនេះជាមួយនឹងមេធាវីដែលគាត់បានប្រាប់ឈ្មោះអម្បាញ់មិញនេះ ដើម្បីឲ្យគាត់ធ្វើការប្រាស្រ័យទាក់ទង និងបានឱកាសក្នុងការប្រឹក្សាយោបល់ដើម្បីត្រៀមជាមុន ហើយចៀសវាងស្អែក ថ្ងៃស្អែកមានការអាក់ខាន ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៥:៣០នាទី]*